**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាសិក្សាបញ្ចប់ការសិក្សា

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ
# របស់ក្រុមហ៊ុន STARBUCKS CORPORATION

ស្រាវជ្រាវ ពីថ្ងៃទី១៨ មិនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ម៉ក់ វ៉ានីន**
**ចាន់ ធីតា**

សាស្ត្រាចារ្យណែនាំ
លោក **ព្រំ សុគុណា**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ក់ វ៉ានីន** និង **ចាន់ ធីតា** ជានិស្សិតនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផ្នែកសេដ្ឋកិច្ច ជំនាញ ធនាគារហិរញ្ញវត្ថុក្រុម B4C1 និង B4C4 ជំនាន់ទី ១២ ឆ្នាំសិក្សា ២០១៨-២០១៩ ដែលបានសិក្សាស្រាវជ្រាវលើប្រធានបទការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks Corporation។

សូមសម្តែងនូវសេចក្តីគោរព និងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ទាំងបួនរូបដែលបានផ្តល់កំណើតបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅព្រមទាំងផ្គត់ផ្គង់ការសិក្សាដល់រូបកូនៗគ្រប់បែបយ៉ាងទាំងស្មារតី និងទាំងហិរញ្ញវត្ថុទាំងពីទារកភាពរហូតដល់ធំពេញវ័យនិងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកលោក-ស្រី សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត នៅក្នុងការរៀបចំកម្មវិធីសិក្សាបង្រៀនយើងខ្ញុំ និងនិស្សិតទាំងអស់ក្នុងសាកលវិទ្យាល័យ។

លោកសាស្ត្រាចារ្យ **ព្រុំ សុគុណា** ដែលជាសាស្ត្រាចារ្យណែនាំដោយបានចំណាយពេលវេលាយ៉ាងច្រើន ព្រមទាំងកម្លាំងកាយ កម្លាំងចិត្តនិងចំណេះដឹងដោយមិនគិតពីការនឿយហត់ក្នុងការណែនាំនិងការបង្ហាត់បង្រៀនដល់រូបយើងខ្ញុំព្រមទាំងនិស្សិតទាំងអស់គ្នារហូតដល់ទីបញ្ចប់។

មិត្តរួមក្រុមដែលបានចូលរួមយ៉ាងសកម្មចែករំលែកសាមគ្គីភាព និងចាំផ្តល់កម្លាំងកាយចិត្តក្នុងការធ្វើកិច្ចការស្រាវជ្រាវនេះ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរ ចំពោះលោកអ្នកមានគុណទាំងអស់ឲ្យជួបតែសុភមង្គល ទទួលបាននូវសុខភាពល្អ កម្លាំងមាំមួន និង ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ឆ្លងកាត់ការសិក្សាអស់រយៈពេលបួនឆ្នាំនៅ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រ សេដ្ឋកិច្ច កន្លងមកយើងខ្ញុំទទួលបាននូវចំណេះដឹងតាមរយៈការបង្ហាត់បង្រៀន បណ្តុះបណ្តាល ដោយយកចិត្តទុកដាក់ពីលោក លោកស្រីសាស្ត្រាចារ្យ និងលោកគ្រូអ្នកគ្រូ តាមមុខវិជ្ជាទាំងចំណេះដឹង និងបទពិសោធន៍ទាំងឡាយដែលពួកគាត់បានជួបប្រទះកន្លងមក។ ជាក់ស្តែង ដើម្បីបញ្ចប់ការសិក្សាបានដោយជោគជ័យសាកលវិទ្យាល័យតម្រូវឲ្យនិស្សិតធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសរសេររបាយការណ៍ឬសារណា បញ្ចប់ការសិក្សារបស់ខ្លួនក៏ដូចជាផ្តល់ឱកាសឲ្យនិស្សិតយកទ្រឹស្តី ទៅអនុវត្តផ្ទាល់ក្នុងការងារជាក់ស្តែងផងដែរ។ដោយឡែកយើងខ្ញុំបានសិក្សាលើមុខជំនាញធនាគារ និងហិរញ្ញវត្ថុ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ "ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ" សម្រាប់យកមក សរសេរជាសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ។ ចំពោះប្រធានបទនេះយើងខ្ញុំជ្រើសរើសយកក្រុមហ៊ុន Starbucks Corporation ដែលជាក្រុមហ៊ុនមួយកំពុងមានការគាំទ្រខ្លាំងពីសំណាក់អតិថិជន និងកំពុងមានការរីចម្រើនខ្លាំងឥតឈប់ឈរ។ ហើយយើងខ្ញុំមានការចាប់អារម្មណ៍ចង់ដឹងពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន លទ្ធភាពទូទាត់បំណុល លទ្ធភាពស្វែងប្រាក់ចំណេញមានស្ថានភាពបែបណា។

យើងខ្ញុំសង្ឃឹមថាសៀវភៅសារណាបញ្ចប់ការសិក្សាមួយក្បាលរបស់យើងខ្ញុំនេះ នឹងក្លាយជាឯកសារអាចជួយដល់ប្អូនៗជំនាន់ក្រោយដែលសិក្សាលើមុខជំនាញនេះ សំរាប់ស្រាវជ្រាវ និងស្វែងយល់បន្ថែមទុកគោលគំនិតមតិ និងយល់ដឹងឲ្យកាន់តែប្រសើរជាងមុនពីការអនុវត្តជាក់ស្តែងលើវិធី សាស្ត្រវិភាគរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន។ ក្នុងសៀវភៅនេះបានលើកយកនូវទ្រឹស្តីដែលត្រូវយកមកវិភាគរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងបង្ហាញស្ថានភាពទូទៅរបស់ក្រុមហ៊ុន Starbucks Corporation និងការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក៏ដូចជាការផ្តល់មតិយោបល់យើងខ្ញុំចំពោះសារណានេះ។

យើងខ្ញុំជឿជាក់ថាសៀវភៅសារណាមួយក្បាលនេះពិតជាមានចំណុចខ្វះខាត និងមានការប្រើប្រាស់ពេចន៍ត្រង់ចំណុចណាមួយជាក់ជាពុំខាន។ ហេតុនេះហើយយើងខ្ញុំរីករាយរង់ចាំទទួលជានិច្ចរាល់គំនិត និងការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងឡាយក្នុងការកែលម្អរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា ត្រង់ផ្នែកណាមួយនោះ ដើម្បីឲ្យសារណាមួយក្បាលនេះកាន់តែល្អប្រសើរឡើង។

# មាតិកា

ទំព័រ


បញ្ជីតារាង ....... iv
បញ្ជីរូបភាព ....... vi
បញ្ជីឧបសម្ព័ន្ធ ....... vii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ....... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ....... ១
៣. គោលបំណងនៃការស្រាវជ្រាវ ....... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....... ២
៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ ....... ២
៦. សារៈប្រយោជន៍នៃការស្រាវជ្រាវ ....... ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... ៣


## ជំពូកទី១

## រំលឹកទ្រឹស្តី


១.១. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ....... ៤
  ១.១.១. គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ....... ៤
  ១.១.២. បំរើបំរាស់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុ ....... ៥
១.២. របាយការណ៍ហិរញ្ញវត្ថុ ....... ៧
  ១.២.១. និយមន័យរបាយការណ៍ហិរញ្ញវត្ថុ ....... ៧
  ១.២.២. ទម្រង់របាយការណ៍ហិរញ្ញវត្ថុ ....... ៨
    ១.២.២.១. របាយការណ៍លទ្ធផល ....... ៨
    ១.២.២.២. របាយការណ៍បម្រែបម្រួលមូលធន ....... ១០
    ១.២.២.៣. តារាងតុល្យការ ....... ១១
    ១.២.២.៤. របាយការណ៍ចលនាលំហូរសាច់ប្រាក់ ....... ១៥
១.៣. ប្រភេទនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ....... ១៧
  ១.៣.១. ការវិភាគតាមជួរឈរ ....... ១៧

១.៣.២. ការវិភាគតាមជួរដេក ............................................................ ១៨
១.៣.៣. ការវិភាគដោយប្រើប្រាស់រូបមន្តអនុបាត ............................................ ១៩
១.៣.៤. ការវិភាគតាម Du Pont Identify ................................................ ២៨

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ក្រុមហ៊ុន Starbucks Corporation

២.១. ស្ថានភាពទូទៅ ............................................................ ៣០
២.១.១. ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Starbucks ........................................ ៣០
២.១.២. ប្រវត្តិសង្ខេបនៃក្រុមហ៊ុន Starbucks Corporation ................................ ៣០
២.១.៣. និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ............................................ ៣២
២.២. ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ................................................ ៣៥
២.២.១. ការលក់ផលិតផល ............................................................ ៣៥
២.២.២. ការចែកចាយ Franchising ...................................................... ៣៧
២.៣. ផលិតផល ................................................................ ៣៩
២.៣.១. ផលិតផលរបស់ Starbucks ...................................................... ៣៩
២.៣.២. ផលិតផលសម្រេចរបស់ Starbucks ................................................ ៣៩
២.៣.៣. ការផ្គត់ផ្គង់ផលិតផលរបស់ Starbucks ............................................ ៤០

## ជំពូកទី៣

## ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ Starbucks Corporation

៣.១. របាយការណ៍ហិរញ្ញវត្ថុ ........................................................ ៤២
៣.១.១. របាយការណ៍លទ្ធផល ........................................................ ៤២
៣.១.២. តារាងតុល្យការ ............................................................ ៤៥
៣.២. ការវិភាគតាមអនុបាត ........................................................ ៥០
៣.២.១. អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី ........................................ ៥០
៣.២.២. អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង ........................................ ៥៣
៣.២.៣. អនុបាតនៃប្រសិទ្ធភាពក្នុងការប្រើប្រាស់ទ្រព្យសកម្ម .................................... ៥៦
៣.២.៤. អនុបាតនៃលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញ ...................................... ៦១
៣.២.៥. អនុបាតនៃតម្លៃទីផ្សារភាគហ៊ុន .................................................. ៦៤

៣.៣. ការវិភាគតាម Du Pont Identity ..... ៦៦
៣.៤. លទ្ធផលនៃការវិភាគ ..... ៦៧

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..... ៦៩
២. ការផ្តល់អនុសាសន៍ ..... ៧០

# បញ្ជីគំនូសតារាង

ទំព័រ

គំនូសតារាងទី១ ទម្រង់ទូទៅនៃរបាយការណ៍លទ្ធផល ........................................................... ៩
គំនូសតារាងទី២ ទម្រង់ទូទៅនៃរបាយការណ៍បម្រែបម្រួលមូលធន........................................ ១០
គំនូសតារាងទី៣ ទម្រង់ទូទៅនៃតារាងតុល្យការ....................................................................... ១២
គំនូសតារាងទី៤ ទម្រង់ទូទៅនៃរបាយការណ៍លំហូរសាច់ប្រាក់ ................................................ ១៥

# បញ្ជីតារាង

តារាងទី១ ការវិភាគតាមជួរដេកទៅលើ របាយការណ៍លទ្ធផល .............................................. ១៩
តារាងទី២ ការវិភាគតាមជួរដេកទៅលើ តារាងតុល្យការ ........................................................ ១៩
តារាងទី៣ អនុបាតចរន្តរបស់ក្រុមហ៊ុន Starbucks ឆ្នាំ ២០១៧-២០១៨.................................. ៥១
តារាងទី៤ អនុបាតរហ័សរបស់ក្រុមហ៊ុន Starbucks ឆ្នាំ ២០១៧-២០១៨.................................. ៥២
តារាងទី៥ អនុបាតសាច់ប្រាក់របស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ ............................ ៥២
តារាងទី៦ អនុបាតបំណុលសរុបរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ ...................... ៥៣
តារាងទី៧ បំណុលធៀបនឹងមូលធនរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ .................. ៥៤
តារាងទី៨ មេគុណមូលធនរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ ............................... ៥៥
តារាងទី៩ អនុបាតនៃសមត្ថភាពទូទាត់ការប្រាក់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ .......... ៥៥
តារាងទី១០ ចំនួនដងនៃការបង្វិលសន្និធិរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨............. ៥៦
តារាងទី១១ ចំនួនថ្ងៃក្នុងការបង្វិលសន្និធិរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨............ ៥៧
តារាងទី១២ ការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ ...................... ៥៨
តារាងទី១៣ ចំនួនថ្ងៃក្នុងការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨..... ៥៨
តារាងទី១៤ការប្រើប្រាស់ទុនបង្វិលរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨.................... ៥៩
តារាងទី១៥ ការបង្វិលទ្រព្យសកម្មរយៈពេលវែងរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨.. ៦០
តារាងទី១៦ ចំណូលពីការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨.. ៦០
តារាងទី១៧ អនុបាតប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨............. ៦១
តារាងទី១៨ អនុបាតផលចំណេញពីទ្រព្យសកម្មរបស់ Starbucks ឆ្នាំ២០១៧-២០១៨................ ៦២
តារាងទី១៩ អនុបាតផលចំណេញពីមូលធនម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨.................................................................................................................... ៦៣
តារាងទី២០ ប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ ....... ៦៤

តារាងទី២១ អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញរបស់ Starbucks ឆ្នាំ២០១៧-២០១៨............. ៦៤
តារាងទី២២ តម្លៃភាគហ៊ុននៅក្នុងបញ្ជីរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨................. ៦៥
តារាងទី២៣ អនុបាតទីផ្សាររបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨ ................................ ៦៥
តារាងទី២៤ ការវិភាគតាម Du Pont Identity របស់ក្រុមហ៊ុន Starbucks ឆ្នាំ ២០១៧-២០១៨...... ៦៦

# បញ្ជីរូបភាព

ទំព័រ

រូបភាពទី១ បង្ហាញពីទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Starbucks........................................ ៣០
រូបភាពទី២ បង្ហាញពីនិមិត្តសញ្ញារបស់ក្រុមហ៊ុន Stabucks ឆ្នាំ១៩៧១-១៩៨៧.........................៣៣
រូបភាពទី៣ បង្ហាញពីនិមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ឆ្នាំ១៩៨៧-១៩៩២........................ ៣៤
រូពភាពទី៤ បង្ហាញពីនិមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ឆ្នាំ១៩៩២-២០១១......................... ៣៤
រូបភាពទី៥ បង្ហាញពីនិមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ឆ្នាំ ២០១១-បច្ចុប្បន្ន..................... ៣៥
រូបភាពទី៦ របាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន Starbucks ................................................... ៤២
រូបភាពទី៧ តារាងតុល្យការរបស់ក្រុមហ៊ុន Starbucks............................................................. ៤៥

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks

ឧបសម្ព័ន្ធទី២៖ តម្លៃភាគហ៊ុន និងចំនួនភាគហ៊ុនដែលបានបោះផ្សាយរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧ និង ២០១៨

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្នវិស័យសេដ្ឋកិច្ចនៅលើពិភពលោកកំពុងមានការរីកចម្រើន យ៉ាងខ្លាំង ហើយតាមរយៈនេះហើយ ក៏ធ្វើអោយមានការរីកដុះដាលនូវសហគ្រាសអាជីវកម្មជាច្រើនប្រភេទ កំពុងមានការលូតលាស់គួរអោយកត់សម្គាល់ផងដែរនៅទូទាំងពិភពលោក។ បើយើងក្រឡេក ទៅមើលក្រុមហ៊ុនបែបលក្ខណៈជាភេសជ្ជៈ និងបែបអាហាររហ័សវិញក៏មានការរីកចម្រើន និងលូតលាស់ទៅមុខជាលំដាប់ផងដែរ។ ដោយសារមានការរីកចម្រើនទៅមុខជាលំដាប់ និងមានការនិយមគាំទ្រពីសំណាក់អតិថិជនកាន់តែខ្លាំង ក្រុមហ៊ុនទាំងនោះព្យាយាមរិះរកវិធីសាស្ត្រ ក្នុងការបម្រើជូនសេវាកម្មដល់អតិថិជនអោយកាន់តែល្អប្រសើរឡើង ក៏ដូចជាបង្កើតបញ្ជីមុខម្ហូបថ្មីដល់អតិថិជនរបស់ខ្លួនជានិច្ច។មួយវិញទៀតក្រុមហ៊ុនទាំងនោះក៏បានពង្រីកសាខា និងទីតាំងអាជីវកម្មរបស់ខ្លួនទាំងក្នុងស្រុក និងក្រៅស្រុកដើម្បីផ្គត់ផ្គង់ជូនដល់អតិថិជន។ ទន្ទឹមនោះផងដែរការគ្រប់គ្រង ហិរញ្ញវត្ថុ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរមួយចំពោះអ្នកគ្រប់គ្រងមិនថាចំពោះក្រុមហ៊ុនបម្រើសេវាកម្ម ឬផលិតកម្មនោះទេ ពីព្រោះបើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនបានល្អនោះធ្វើឲ្យដំណើរការអាជីវកម្ម ទទួលបានជោគជ័យ។ ផ្ទុយទៅវិញវាអាចធ្វើអោយអង្គភាពរបស់ខ្លួនជួបបញ្ហាប្រចាំថ្ងៃរហូតឈានដល់ការក្ស័យធន ប្រសិនបើការគ្រប់គ្រងនោះគ្មានប្រសិទ្ធភាពហើយមិនរកវិធីសាស្ត្រដោះស្រាយបាន។ ដោយមើលឃើញពីសារៈសំខាន់ និងការរីកចម្រើនរបស់ក្រុមហ៊ុនអាហារនិងភេសជ្ជៈ ក៏ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុ ហេតុដូច្នេះហើយទើបយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវលើ ប្រធានបទ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks ដើម្បីចង់ដឹងពីប្រសិទ្ធិភាពនៃការគ្រប់គ្រងរបស់ក្រុមហ៊ុន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

Starbucks Corporation បានប្រែក្លាយជាក្រុមហ៊ុនដ៏ល្បីមួយនៅក្នុងសហរដ្ឋអាមេរិក និងប្រទេសជាច្រើននៅក្នុពិភពលោក និងមានការនិយមចូលចិត្តពីសំណាក់អតិថិជន តាមរយៈការផ្តល់ជូននូវសេវាកម្ម និងផលិតផលដ៏សំបូរបែបជូនដល់អតិថិជនរបស់ខ្លួន និងតាមដានរាល់ស្ថានភាពប្រតិបត្តិការនិងប្រសិទ្ធភាពអាជីវកម្ម មួយវិញទៀតក្រុមហ៊ុនធ្វើតាមការតាមដាន និងវិភាគលើរបាយការណ៍ហិរញ្ញវត្ថុជាអចិន្ត្រៃយ៍។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងចង់ដឹងថាតើក្រុមហ៊ុន Starbucks គ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនមានប្រសិទ្ធភាពកម្រិតណានៅឆ្នាំ២០១៨ បើធៀបនឹងឆ្នាំ ២០១៧?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេ គឺដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់លាស់អំពី៖

- ស្ថានភាពទូទៅនៃក្រុមហ៊ុន Starbucks Corporation
- ស្វែងយល់អោយបានស៊ីជម្រៅទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដូចជាលទ្ធភាពទូទាត់ភាពទូទាត់បំណុល គុណភាពទ្រព្យសកម្ម លទ្ធភាពស្វែងរកប្រាក់ចំណេញ។
- សន្និដ្ឋានពីប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks Corporation។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ក្រុមហ៊ុន Starbucks Corporation មានផលិតផលនិងសេវាកម្មជាច្រើនហើយមានទីតាំងជាច្រើនកន្លែងប៉ុន្តែនៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើតែការវិភាគរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០១៨ របស់ក្រុមហ៊ុន Starbucks ស្នាក់ការកណ្តាលនៅសហរដ្ឋអាមេរិកដោយធៀបនឹងឆ្នាំ ២០១៧ តែប៉ុណ្ណោះ។ ម្យ៉ាងទៀត មានវិធីសាស្ត្រជាច្រើនដែលត្រូវបានប្រើប្រាស់សម្រាប់វិភាគរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែនៅក្នុងការសិក្សានេះ យើងខ្ញុំវិភាគតាមអនុបាត (Ratio Analysis) តែប៉ុណ្ណោះ។

## ៥. អត្ថប្រយោជន៍នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវតែងតែផ្តល់នៅអត្ថប្រយោជន៍ទោះបីតិចក្តីច្រើនក្តីដល់បុគ្គលដែលគ្រប់រូបដែលចង់យល់ដឹងពីអ្វីមួយ។ដោយឡែកចំពោះសារណាមួយនេះយើងខ្ញុំសង្ឃឹមថាវានឹងអាចផ្តល់សារៈប្រយោជន៍ជាច្រើនដូចជា៖

- ជាឯកសារសម្រាប់ទុកសម្រាប់និស្សិតជំនាន់ក្រោយៗអាចធ្វើការស្វែងយល់បន្ថែមលើការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។
- ងាយស្រួលអ្នកវិនិយោគក្នុងការវិភាគពីភាគហ៊ុនអោយកាន់ប្រសើរជាង មុននឹងសម្រេចចិត្តវិនិយោគ។
- ជាពិសេសការសិក្សាស្រាវជ្រាវមួយនេះផ្តល់នៅចំណេះដឹងទាក់ទិននឹងការអនុវត្ត ជាក់ស្តែងបន្ថែមទៅលើការសិក្សាលើផ្នែកទ្រឹស្តីកន្លងមក។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការសិក្សានេះត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ រីឯទិន្និន័យសម្រាប់យកមកវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks គឺជាទិន្នន័យបន្ទាប់បន្សំ (Secondary data) ដែលប្រមូលបានពីគេហទំព័ររបស់ក្រុមហ៊ុន Starbucks និង Internet។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះត្រូវបានបែងចែកជាបីជំពូកធំៗ៖

- សេចក្តីផ្តើម
- ជំពូកទី១ រំលឹកទ្រឹស្តី (ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ និងប្រភេទនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ)
- ជំពូកទី២ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន Starbucks
- ជំពូកទី៣ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ រួមមានការប្រើប្រាស់ឧបករណ៍វិភាគនិងបច្ចេកទេសនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុនោះ ក៏ដូចជាបណ្តាទិន្នន័យទំនាក់ទំនងផ្សេងៗទៀតដើម្បីទទួលបាននូវព័ត៌មានសំខាន់ៗ។ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាការត្រួតពិនិត្យទៅលើផ្នែកផ្សេងៗនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលផ្នែកទាំងនោះមានទំនាក់ទំនងគ្នាទៅវិញទៅមក និងឆ្លុះបញ្ចាំងពីទិដ្ឋភាពរបស់អង្គភាពអាជីវកម្មទាំងមូល[1]។ ដើម្បីវិភាគរបាយការណ៍ហិរញ្ញវត្ថុ យើងត្រូវវិភាគទៅលើគោលបំណង ទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយវិភាគថាវាមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយ និងទិន្នន័យសម្រាប់ការសម្រេចចិត្តរបស់អាជីវកម្មទាំងមូលផងដែរ។

### ១.១.១. គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាការវិភាគព័ត៌មានហិរញ្ញវត្ថុដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុពីអតីតកាល និងពេលបច្ចុប្បន្ន ដេម្បីចង់ដឹងពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាតើក្រុមហ៊ុនមានដំណើរការអាជីវកម្មល្អ ឬមិនល្អ ទាំងផ្នែកគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម និងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ។ ជាទូទៅគោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីធ្វើការវិនិច្ឆ័យទៅលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយប្រើប្រាស់វិធីសាស្ត្រជាក់លាក់ដើម្បីរកមើលកំហុសដែលកើតមានឡើងនៅក្នុងសកម្មភាពអាជីវកម្ម ហើយកំហុសទាំងនោះនឹងត្រូវបានកែតម្រូវដោយគ្មានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយដល់ដំណើរការអាជីវកម្ម និងដើម្បីបង្ហាញពីភាពខ្លាំងដែលក្រុមហ៊ុនអាចប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួនបន្ថែមទៀត។ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានគាំទ្រដោយលទ្ធផលនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុដោយសារតែ តាមរយៈការវាយតម្លៃល្អិតល្អន់នៃលទ្ធផលការវិភាគ គឺកំណត់បានបរិមាណនៃមូលហេតុនៅក្នុងលទ្ធផលទាំងនេះនិងការវាយតម្លៃជាប្រព័ន្ធនៅក្នុងបរិបទ គឺចាំបាច់ដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដរបស់ក្រុមហ៊ុន ដែលបម្រើក្នុងការសំរេចចិត្តជាក់លាក់ទាក់ទងនឹងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការសំរេចចិត្តជាការពិត។ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាការ

[1] Martin G.Jagels et al.,Economic and Finance Analysis (ការវិភាគពីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ), បោះពុម្ពលើកទី៣ (២០០៩), ១២។

អនុវត្តមួយនៃការយល់ដឹងអំពីអ្វីដែលត្រូវស្វែងរកដូចជា ការពណ៌នាការវិវឌ្ឍន៍ស្ថានភាពហិរញ្ញវត្ថុនៅអតីតកាល និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរបៀបនៃការបកស្រាយទិន្នន័យ បន្ទាប់មកទៀតធ្វើការជ្រើសរើសទំនាក់ទំនង និងការវាយតម្លៃ។

ការយល់ដឹងជាអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាចឲ្យអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្តបានត្រឹមត្រូវនៅពេលទទួលបានធនធានហិរញ្ញវត្ថុ ផ្តល់ឥណទានអាជីកម្ម បែងចែកធនធានហិរញ្ញវត្ថុ និងការជ្រើសរើសគោលនយោបាយភាគលាភ។ចំណេះដឹងពីស្ថានភាពហិរញ្ញវត្ថុ គឺចាំបាច់ ដើម្បីយើងអាចប៉ាន់ប្រមាណ និងព្យាករណ៍ពីការអភិវឌ្ឍនាពេលអនាគត។ ហើយការវិភាគរបាយការណ៍ហិរញ្ញវត្ថុគឺតំណាងឲ្យទ្រព្យសម្បត្តិសម្រាប់ក្រុមហ៊ុនគ្រប់ប្រភេទ ពីព្រោះវាអាចប្រាប់ឲ្យដឹងអំពីបញ្ហាដែលទាក់ទងការគ្រប់គ្រងរបស់ក្រុមហ៊ុនជាមុន។ ទោះជាយ៉ាងណាក៏ដោយការពិតដែលថាការវិភាគហិរញ្ញវត្ថុ គឺជាឧបករណ៍មួយដើម្បីរៀនសូត្រពីស្ថានភាពរបស់ក្រុមហ៊ុន មិនមែនដើម្បីផ្លាស់ប្តូរស្ថានភាពរបស់ ក្រុមហ៊ុននោះទេ។ ការអនុវត្តវិធីសាស្ត្រវិភាគហិរញ្ញវត្ថុ គឺមិនរំពឹងគិតថានឹងអាចនាំមកនូវលទ្ធផលដែលក្រុមហ៊ុនចង់បានទាំងស្រុងនោះទេ ប៉ុន្តែគឺត្រូវគួបផ្សំជាមួយការវាយតម្លៃនៃស្ថានភាពសេដ្ឋកិច្ច និងការបកស្រាយត្រឹមត្រូវ នៃលទ្ធផលការវិភាគរបាយការណ៍ហិរញ្ញវត្ថុផងដែរ។ ការសម្រេចចិត្តខុសទាក់ទងទៅនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាចត្រូវបានកើតឡើងដោយសារការបកស្រាយលទ្ធផលនៃការវិភាគមិនត្រឹមត្រូវ ហើយបញ្ហាហិរញ្ញវត្ថុក៏អាចនឹងកាន់តែអាក្រក់ឡើងតាមរយៈនេះផងដែរ[2]។

### ១.១.២. បម្រើបម្រាស់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុ

ព័ត៌មានហិរញ្ញវត្ថុត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលដៅខុសៗគ្នាអាស្រ័យទៅលើការ អនុវត្តប្រតិបត្តិការអាជីវកម្ម និងព្រឹត្តិការណ៍ផ្សេងៗដែលមានឥទ្ធិពលទៅលើអង្គភាពអាជីវកម្មទាំងមូល។ អ្នកគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុទាំងអស់ តែងតែយកចិត្តទុកដាក់ និងធ្វើការតាមដានចំពោះស្ថានភាពហិរញ្ញវត្ថុ អង្គភាពអាជីវកម្មរបស់ខ្លួនទាំងនៅពេលបច្ចុប្បន្ន និងនាពេលអនាគត។ ជាទូទៅអ្នកប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុត្រូវបានបែងចែកជាពីរគឺ អ្នកប្រើប្រាស់ផ្ទៃក្នុង (Internal Users) និងអ្នកប្រើប្រាស់ផ្ទៃក្រៅ (External Users)[3]។

---

[2] ដកស្រង់ចេញពីគេហទំព័រ https://is.mendelu.cz/eknihovna/opory/zobraz_cast.pl?cast=59743 (ចូលទស្សនាថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៩)

[3] Ross Westerfield Jordan., Fundamentals Of Corporate Finance, បោះពុម្ពលើកទី៨, ទំព័រ ៧១

- **ការប្រើប្រាស់ផ្ទៃក្នុង**

អ្នកប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ គឺជាបុគ្គលដែលចូលរួមក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់អាជីវកម្មដូចជា អ្នកគ្រប់គ្រង អ្នកប្រឹក្សាយោបល់ សវនករផ្ទៃក្នុង អ្នកគ្រប់គ្រងកញ្ចប់ថវិការ និងអ្នកស្រាវជ្រាវ និងអភិវឌ្ឍន៍ជាដើម។ ជាក់ស្តែង ចំពោះអ្នកគ្រប់គ្រងត្រូវបានប្រើប្រាស់វាក្នុងការវាយតម្លៃ និងទូទាត់សងតាមមូលដ្ឋាននៃគោលការណ៍គណនេយ្យដូចជាប្រាក់ចំណេញ និងប្រាក់ចំណេញសុទ្ធ។ ក្នុងនោះផងដែរសារៈសំខាន់ក្នុងការប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុផ្ទៃក្នុងមួយទៀតគឺសម្រាប់ងាយស្រួលរៀបចំផែនការអាជីវកម្មនាពេលអនាគត និងសម្រាប់ពិនិត្យមើល realism នៃការសន្មត់ដែលបានធ្វើនៅក្នុងគម្រោងនោះ។

- **ការប្រើប្រាស់ខាងក្រៅ**

របាយការណ៍ហិរញ្ញវត្ថុ ក៏ត្រូវបានយកទៅប្រើប្រាស់ដោយភាគីនៅក្រៅក្រុមហ៊ុនដែលរួមមានដូចជា ម្ចាស់ឥណទានរយៈពេលខ្លី និងរយៈពេលវែង អ្នកវិនិយោគទុន អ្នកផ្គត់ផ្គង់ ដៃគូប្រកួតប្រជែង អតិថិជន ភ្នាក់ងារពន្ធដារ និងអ្នកដែលជាប់ពាក់ព័ន្ធផ្សេងៗទៀតជាដើម ហើយព័ត៌មានហិរញ្ញវត្ថុត្រូវបានពួកគេយកទៅប្រើប្រាស់ក្នុងគោលបំណងមួយចំនួនដូចខាងក្រោម៖

**ម្ចាស់ឥណទានៈ** ប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ ដើម្បីវិភាគទៅលើដំណើរការអាជីវកម្មនិងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមុនពេលសម្រេចចិត្តផ្តល់ ឬក៏បដិសេធមិនផ្តល់ឥណទាន និងដើម្បីចង់ដឹងពីលទ្ធភាពសងបំណុលរបស់ក្រុមហ៊ុន។

**អ្នកវិនិយោគៈ** ត្រូវការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុ ដើម្បីថ្លឹងថ្លែងពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន មុនពេលសម្រេចចិត្តវិនិយោគ ឬក៏បន្តការវិនិយោគបន្តទៅទៀត។

**អ្នកផ្គត់ផ្គង់ៈ** អ្នកផ្គត់ផ្គង់ត្រូវការប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ ស្រដៀងគ្នាទៅនឹងម្ចាស់ឥណទានដែរ អ្នកផ្គត់ផ្គង់ត្រូវការព័ត៌មានហិរញ្ញវត្ថុមុនពេលសម្រេចចិត្តផ្គត់ផ្គង់ដោយជំពាក់ទៅឲ្យក្រុមហ៊ុន។

**ដៃគូប្រកួតប្រជែងៈ** ដៃគូប្រកួតប្រជែងប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ ដើម្បីចង់ដឹងស្ថានភាពហិរញ្ញវត្ថុ និងដើម្បីចង់ដឹងពីភាពខ្លាំងនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដទៃទៀត ក៏ដូចជាដើម្បីដឹងពីស្ថានភាពដំណើរការអាជីវកម្មរបស់ដៃគូប្រកួតប្រជែងរបស់ខ្លួន។

**អតិថិជនៈ** អតិជនធំៗប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្ត វាយតម្លៃពីប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ដើម្បីកំណត់នូវជំនឿទុកចិត្តរបស់ខ្លួនមកលើក្រុមហ៊ុននាពេលអនាគត។

**ភ្នាក់ងារពន្ធដារ:** ធ្វើការត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងគោលបំណងកំណត់ទំហំទឹកប្រាក់ក្នុងការបង់ពន្ធជាដើម។

**រាជរដ្ឋាភិបាល:** គោលបំណងក្នុងការព័ត៌មានហិរញ្ញវត្ថុ គឺដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យពីសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនអាជីវកម្មទាំងអស់ ដើម្បីពិនិត្យទៅលើស្ថានភាពរួមនៃសេដ្ឋកិច្ចជាតិទាំងមូល។

## ១.២. របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ រៀបចំឡើងតាមទម្រង់ដែលបានបង្កើតបានរបាយការណ៍ហិរញ្ញវត្ថុនេះបង្ហាញពីប្រាក់ចំណេញ និងស្ថានភាពហិរញ្ញវត្ថុរបស់អាជីវកម្មណាមួយ។ របាយកាណ៍ទាំងនេះត្រូវបានប្រើប្រាស់ក្នុងផ្នែកផ្សេងៗ។ ម្ចាស់អាជីវកម្ម និងម្ចាស់ភាគហ៊ុន និងត្រូវបានប្រើប្រាស់នូវរបាយការណ៍ទាំងនេះក្នុងការសម្រេចចិត្តវិនិយោគជាមួយក្រុមហ៊ុនមួយ និងភាគហ៊ុនរបស់ក្រុមហ៊ុនសាជីវកម្មណាមួយ។ គោលបំណងដ៏សំខាន់នៅក្នុងការបង្កើតរបាយការណ៍ហិរញ្ញវត្ថុទាំងនេះគឺដើម្បីផ្តល់ព័ត៌មានពិតជាក់ស្តែងជូនដល់ដៃអ្នកប្រើប្រាស់។

### ១.២.១. និយមន័យរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយគណនេយ្យករនៅរៀងរាល់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយរបាយការណ៍ហិរញ្ញវត្ថុជាមធ្យោបាយទំនាក់ទំនងព័ត៌មានគណនេយ្យចំពោះអ្នកដែលត្រូវការប្រើប្រាស់វា (ទាំងខាងក្នុង និងខាងក្រៅក្រុមហ៊ុន)។ តាមរយៈរបាយការណ៍ហិរញ្ញវត្ថុនេះគេអាចដឹងពីស្ថានភាពរបស់ក្រុមហ៊ុន និងសកម្មភាពអាជីវកម្មកន្លងមក។

របាយការណ៍ហិរញ្ញវត្ថុ គឺជាទម្រង់ហិរញ្ញវត្ថុមួយដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្មរបស់កម្មរបស់ក្រុមហ៊ុន។ កម្មវត្ថុនៃរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់គោលបំណងទូទៅ អំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងចលនាលំហូរសាច់ប្រាក់របស់អង្គភាពដែលមានប្រយោជន៍សម្រាប់ការប្រើប្រាស់នានា និងសម្រាប់ការសម្រេចចិត្តក្នុងផ្នែកសេដ្ឋកិច្ច។ របាយការណ៍ហិរញ្ញវត្ថុ ក៏បង្ហាញផងដែរអំពីលទ្ធផលនៃការគ្រប់គ្រង ក៏ដូចជាចាត់ចែងធនធានរបស់អ្នកគ្រប់គ្រងដែលត្រូវផ្តល់ឲ្យពួកគេ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌មាន ដូចខាងក្រោម ៖

- ទ្រព្យសកម្ម
- ទ្រព្យអកម្ម

- មូលនិធិម្ចាស់មូលធន
- ចំណូល ចំណាញ រួមបញ្ចូលទាំងចំណេញ ខាតរបស់ក្រុមហ៊ុន
- លំហូរសាច់ប្រាក់

ព័ត៌មានទាំងអស់នេះភ្ជាប់ជាមួយនឹងព័ត៌មានដទៃទៀតនៅក្នុងកំណត់សម្គាល់នៃ របាយការណ៍ហិរញ្ញវត្ថុ នឹងជួយឲ្យអ្នកប្រើប្រាស់ ក្នុងការធ្វើការប៉ាន់ប្រមាណពីចលនាសាច់ប្រាក់ របស់ក្រុមហ៊ុននាពេលអនាគត ជាពិសេសការកំណត់អំពីពេលវេលា និងភាពច្បាស់លាស់ក្នុងការបង្កើតសាច់ប្រាក់ និងសាច់ប្រាក់សមមូល[4]។

### ១.២.២. ទម្រង់របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុគឺជាទម្រង់នៃការបង្ហាញពីស្ថានហិរញ្ញវត្ថុ និងការប្រើប្រាស់ហិរញ្ញវត្ថុនៃអង្គភាពមួយ។ របាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ ព្រោះវាបានរាយការណ៍អំពីព័ត៌មានហិរញ្ញវត្ថុ និងជាមធ្យោបាយក្នុងការបង្ហាញអំពីទំនាក់ទំនងដំណើរការអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពអាជីវកម្ម[5]។ ជាទូទៅរបាយការណ៍ហិរញ្ញវត្ថុចែកចេញជាបួនប្រភេទគឺៈ

១. របាយការណ៍លទ្ធផល (Income Statement)

២. របាយការណ៍មូលធន (Statement of Owner's Equity)

៣. តារាងតុល្យការ (Balance Sheet)

៤. របាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flow)

#### ១.២.២.១. របាយការណ៍លទ្ធផល (Income Statement)

❖ **និយមន័យ**

របាយការណ៍លទ្ធផល គឺជារបាយការណ៍ដែលបង្ហាញអំពី ចំណូល (Revenues) ចំណាយ (Expenses) ចំណេញសុទ្ធ (Net income) ឬខាតសុទ្ធ (Net Loss) របស់អង្គភាពនៅក្នុងកំឡុងកាលបរិច្ឆេទណាមួយដូចជាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។របាយការណ៍លទ្ធផលក៏ត្រូវបានគេឲ្យឈ្មោះថាជារបាយការណ៍ ចំណេញឬខាតពីព្រោះវាបង្ហាញពីកម្រិតចំណេញសុទ្ធ ឬខាតសុទ្ធ( Net Profit or Lose) របស់ក្រុមហ៊ុនទាំងមូល។ បន្ថែមពីនេះទៅទៀតរបាយការណ៍នេះក៏បានបង្ហាញឲ្យដឹងអំពីការបែងចែកប្រាក់ចំណេញសុទ្ធដែលនៅសល់ ក្រោយពីការបង់ពន្ធរបស់អង្គភាព

[4] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១ (CIAS1) ទំព័រ១៤

[5] accounting-simplified.com (ចូលទស្សនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩)

ថាតើ អង្គភាពបែងចែកប្រាក់ចំណេញទាំងអស់ទៅជាភាគលាភ (Dividends) និងប្រាក់ចំណេញរក្សាទុក (Retained Earnings ) បានប៉ុន្មាន[6]។

ខាងក្រោមនេះ គឺជាទម្រង់គំរូរបាយការណ៍លទ្ធផលសម្រាប់ក្រុមហ៊ុន ៖

Company Name

Income Statement

For the year ended, 20XX

| | | |
|---|---|---|
| Total Revenue | XXXX | |
| Cost of Revenue | (XXXX) | |
| **Gross Profit** | | XXXX |
| Research and Development | XXXX | |
| Sales, General and Admin. | XXXX | |
| Non-Recurring Items | XXXX | |
| Other Operating Items | XXXX | |
| **Operating Income** | | XXXX |
| Add'l income/expense items | XXXX | _ |
| Earnings Before Interest and Tax | XXXX | _ |
| Interest Expene | XXXX | _ |
| Earnings Before Tax | XXXX | _ |
| Income Tax | XXXX | _ |
| Minority Interest | XXXX | _ |
| Equity Earnings/Loss Unconsolidated Subsidiary | XXXX | _ |
| Net Income-Cont. Operations | XXXX | _ |
| **Net Income** | | **XXXX** |
| **Net Income Applicable to Common Shareholders** | | **XXXX** |

[6] Henry Dauderisn and David Annand., Introduction to Financial Accounting, បោះផ្សាយលើកទី២, ទំព័រ

### ១.២.២.២. របាយការណ៍បម្រែបម្រួលមូលធន ( Statement of Change in Equity )

❖ **និយមន័យ**

របាយការណ៍បម្រែបម្រួលមូលធន គឺជារបាយការណ៍មួយដែលសង្ខេបអំពីការប្រែប្រួលនៅក្នុងមូលធនរបស់ម្ចាស់ភាគហ៊ុនសម្រាប់កំឡុងពេលជាក់លាក់ណាមួយ។ជាទូទៅរបាយការណ៍បម្រែបម្រួលមូលធននេះបង្ហាញអំពីបង្ហាញអំពីសមតុល្យមូលធននៅដើមគ្រា បម្រែបម្រួលមូលធននៅក្នុងគ្រា និងសមតុល្យមូលធននៅចុងគ្រា។ របាយការណ៍មានសារៈសំខាន់សម្រាប់ភាគទុននិកក្នុងការតាមដានមូលធនរបស់ខ្លួន ដែលបានធ្វើប្រតិបត្តិការនៅក្នុងកាលបរិច្ឆេទជាក់លាក់ណាមួយ[7]។

ខាងក្រោមនេះ គឺជាទម្រង់គំរូរបាយការណ៍បម្រែបម្រួលមូលធនក្រុមហ៊ុន

Company Name

Statement of Changes in Equity

For the ended September, 20XX

(In USD)

| | Common Stock | | Additional Paid in Capital | Retained Earnings | Accumulated Other Comprehensive Income/Loss | Share-holders′ Equity | Non-controlling Interests | Total |
|---|---|---|---|---|---|---|---|---|
| | Share | Amount | | | | | | |
| **Balance , XX , (20XX-1)** | **XXXX** | **XXXX** | **XXXX** | **XXXX** | **XXXX** | **XXXX** | **XXXX** | **XXXX** |
| Net Earning/Loss | | | | XXXX | | XXXX | XXXX | XXXX |
| Other Conprehensive income/Loss | | | | | XXXX | XXXX | | XXXX |
| Stock-Based conpensation expense | | | XXXX | | | XXXX | | XXXX |
| Exercise of stock options/vesting of RSUs | XXXX | | XXXX | | XXXX | | | XXXX |
| Sale of commom stock | XXXX | | XXXX | | | XXXX | | XXXX |

7 ដកស្រង់ចេញពីគេហទំព័រ https://www.accountingtools.com/articles/statement-of-changes-in-equity.html (ចូល ទស្សនា ថ្ងៃទី ០២ ឧសភា ២០១៩)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Repurchase of common stock | (XXXX) | (XXXX) | (XXXX) | (XXXX) | | (XXXX) | | XXXX |
| Cash dividends declared, XX per share | | | | (XXXX) | | (XXXX) | | XXXX |
| Net distributions to noncontrolling interests | | | | | | (XXXX) | | XXXX |
| Balance , XX , 20XX | XXX | XXX | XXX | XXX | XXX | XXX | XXX | XXX |

❖ **សមាសធាតុសំខាន់ៗរបាយការណ៍បម្រែបម្រួលមូលធន**

របាយការណ៍បម្រែបម្រួលមូលធន មានធាតុសមាសធាតុសំខាន់ៗដូចជា ៖

Common Stock គឺជាភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនដែលបានបោះផ្សាយលក់ទៅឲ្យម្ចាស់ភាគហ៊ុន។ វាគឺជាមូលធនភាគហ៊ុនរបស់ភាគទុនិក។

Additional Paid in Capital គឺជាតម្លៃដែលវិនិយោគិនទិញភាគហ៊ុនក្នុងតម្លៃមួយលើសពីតម្លៃចារឹករបស់ភាគហ៊ុននោះ នៅពេលដែលក្រុមហ៊ុនបោះផ្សាយបានបោះផ្សាយភាគហ៊ុនរបស់ខ្លួនជាលើកដំបូង (IPO) ។

Retained Earning គឺប្រាក់ចំណេញរក្សាទុកសម្រាប់ប្រតិបត្តិការអាជីវកម្មក្នុងឆ្នាំថ្មី ហើយគេក៏អាចកាត់ផ្ទេរមួយចំនួនទៅជាដើមទុនផងដែរ។

Accumulated Other Comprehensive Income/Loss គឺជាគណនីទិន្នានុប្បវត្តិមួយដែលត្រូវបានកត់ចូលនៅក្នុង ផ្នែកមូលធននៃតារាងតុល្យការរបស់ក្រុមហ៊ុន។ ម៉្យាងវិញទៀតគណនីនេះគឺសម្រាប់កត់ត្រាប្រាក់ចំណេញមិនពិតប្រាកដ ឬការខាតទៅធាតុណាមួយ។

Shareholders' Equity គឺជាមូលធនទាំងមូលរបស់ភាគទុនិក។

Noncontrolling Interests គឺជាការប្រាក់ដែលបានមកពីភាពជាម្ចាស់មួយផ្នែកនៃក្រុមហ៊ុនមួយដែលខ្លួនបានវិនិយោគមូលធនចូលប៉ុន្តែមិនអាចលើសពី ៥០ ភាគរយ នៃមូលធនសរុបរបស់ក្រុមហ៊ុននោះទេ។

### ១.២.២.៣. តារាងតុល្យការ (Balance sheet)

❖ **និយមន័យ**

តារាងតុល្យការ គឺជារបាយការណ៍មួយដែលបង្ហាញពី តម្លៃគណនេយ្យរបស់ក្រុមហ៊ុននៅ

ក្នុងកាលបរិច្ឆេទជាកើតលាក់ណាមួយ។ តារាងតុល្យការមានធាតុបីសំខាន់ៗ គឺ នៅផ្នែកខាងឆ្វេង គឺទ្រព្យសកម្ម (Asset) នៅផ្នែកខាងស្តាំមានធាតុពីរគឺ ខាងលើបង្ហាញពីទ្រព្យអកម្ម ឬបំណុល (Liabilities) និងនៅខាងក្រោមបង្ហាញពីមូលធន (Equity) តាមរយៈទំនាក់ទំនងទាំងបីនេះ គេសរសេរសមីការគណនេយ្យបានដូចខាងក្រោម[8] ៖

| | | |
|---|---|---|
| ទ្រព្យសកម្ម = ទ្រព្យអកម្ម (បំណុល) + មូលនិធិម្ចាស់ទ្រព្យ | | |
| Assets | = Liabilities | + Owner's Equity |

ប៉ុន្តែធាតុនីមួយៗដែលមាននៅក្នុងតារាងតុល្យការហិរញ្ញវត្ថុ មានលក្ខណៈខុសគ្នារវាងក្រុមហ៊ុនភេសជ្ជៈ និងអារហារ ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ ក្រុមហ៊ុនបម្រើសេវាកម្ម ក្រុមហ៊ុនផលិតកម្ម និងធនាគារ។ ចំពោះក្រុមហ៊ុនភេសជ្ជៈ និងអាហារ នៅក្នុងរបាយការណ៍នេះមានធាតុសំខាន់ៗដូចខាងក្រោម ៖

ខាងក្រោមនេះ គឺជាទម្រង់គំរូតារាងតុល្យការរបស់ក្រុមហ៊ុន

Company Name

Balance sheet

For the year ended XXX, 20XX

| | | |
|---|---|---|
| **Current Assets** | | |
| Cash and Cash Equivalents | XXXX | |
| Short-Term Investments | XXXX | |
| Net Receivables | XXXX | |
| Inventory | XXXX | |
| Other Current Assets | XXXX | |
| **Total Current Assets** | | XXXX |
| **Long-Term Assets** | | |
| Long-Term Investments | XXXX | |
| Fixed Assets | XXXX | |
| Goodwill | XXXX | |

[8] Henry Dauderisn and David Annand., Introduction to Financial Accounting (បោះផ្សាយលើកទី២)

| | | |
|---|---|---|
| Intangible Assets | XXXX | |
| Other Assets | XXXX | |
| Deferred Asset Charges | XXXX | |
| **Total Long-Term Assets** | | XXXX |
| **Total Assets** | | XXXX |
| **Current Liabilities** | | |
| Accounts Payable | XXXX | |
| Short-Term Debt/Current Portion of Long-Term Debt | XXXX | |
| Other Current Liabilities | XXXX | |
| **Total Current Liabilities** | | XXXX |
| Long-Term debt | XXXX | |
| Other Liabilities | XXXX | |
| Deferred Liability Charges | XXXX | |
| Misc. Stocks | XXXX | |
| Minority Interest | XXXX | |
| **Total Liabilities** | | XXXX |
| Stockholders Equity | XXXX | |
| Common stocks | XXXX | |
| Capital Surplus | XXXX | |
| Retained Earnings | XXXX | |
| Treasury stock | XXXX | |
| Other Equity | XXXX | |
| **Total Equity** | | XXXX |
| **Total Liabilities & Equity** | | **XXXX** |

- **សមាសធាតុសំខាន់ៗនៅក្នុងតារាងតុល្យការ**

**ទ្រព្យសកម្ម (Assets)**

ទ្រព្យសកម្មគឺជាប្រភពធនធានរបស់អង្គភាពអាជីវកម្ម។ ដូច្នេះវាគឺជាសមាសធាតុដ៏មានតម្លៃអាចប្រើប្រាស់បាននៅក្នុងសកម្មភាពអនុវត្តសកម្មភាពអាជីកម្មជាច្រើនដូចជា កត្តាផលិតកម្ម ការប្រើប្រាស់ និងការជួញដូរផ្សេងៗ។ ទ្រព្យសកម្មមានតួនាទីសំខាន់នៅក្នុងការជំរុញការបង្កើតសាច់ប្រាក់។ទ្រព្យសកម្មចែកចេញជាពីរប្រភេទធំៗគឺ ទ្រព្យសកម្មរយៈពេលខ្លី ឬទ្រព្យសកម្មចរន្ត (Current Asset) និង ទ្រព្យសកម្មរយៈពេលវែង។ ដែលទ្រព្យសកម្មរយៈពេលខ្លីសំដៅលើទ្រព្យទាំងឡាយណាដែលអាច បំលែងជាសាច់ប្រាក់នៅក្នុងរយៈពេលតិចជាង ឬស្មើមួយឆ្នាំ។ ទ្រព្យសកម្មរយៈពេលខ្លីរួមមាន សាច់ប្រាក់ និងសមតុល្យសាច់ប្រាក់ (Cash and Cash Equivalents) ការវិនិយោគរយៈពេលខ្លី (Short-Term Investments) ឥណទេយ្យ (Net Receivables) សន្និធិ (Inventory) និងទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗទៀត (Other Current Assets)។ ចំណែកឯទ្រព្យសកម្មរយៈពេលវែង (Long-Term Assets) សំដៅទៅលើទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាសវែងជាងមួយឆ្នាំ ដោយវាចូលរួមនៅក្នុងការគាំទ្រ និងជំរុញក្នុងដំណើរការអាជីវកម្ម។ នៅក្នុង ទ្រព្យសកម្មរយៈពេលវែង(Long-Term Assets)មានធាតុដូចជា ការវិនិយោគរយៈពេលវែង (Long-Term Investments) ទ្រព្យសកម្មអរូបី (Intangible Asset) ទ្រព្យសកម្មដទៃៗទៀត (Other Assets) ទ្រព្យនៃប្រាក់ដែលបានទូទាត់មុន (Differed charge asset) ។

**ទ្រព្យអកម្ម ឬបំណុល (Liabilities)**

ជាទូទៅដើម្បីបើកដំណើរការអាជីវកម្ម ក៏ដូចជាធ្វើប្រតិបត្តិការអាជីវកម្មបានជោគជ័យ ស្ថាប័នអាជីវកម្មគ្រប់កម្រិតតែងតែមានការខ្ចីបំណុល ការទិញជឿពីស្ថាប័ន និងអ្នកវិនិយោគផ្សេងៗទៀត។ ចំពោះក្រុមហ៊ុនសាជីវកម្មក៏ដូច្នេះដែរ វាជាការចំបាច់ក្នុងការស្វែងរកប្រភពហិរញ្ញប្បទានពីសំណាក់អ្នកវិនិយោគខាងក្រៅ ដើម្បីបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនឲ្យកាន់តែរលូនទៅមុខ។ ប្រភពហិរញ្ញប្បទានទាំងនោះត្រូវបានគេឲ្យឈ្មោះថា ទ្រព្យអកម្ម ឬបំណុល។

ទ្រព្យអកម្មឬបំណុល គឺជាអ្នកកាត់បន្ថយទ្រព្យសកម្ម។ ទ្រព្យអកម្មរបស់ក្រុមហ៊ុនបានបែងចែកជាពីរគឺ បំណុលរយៈពេលខ្លី (Current Liabilities) និងបំណុលរយៈពេលវែង (Long-Term debt)។ បំណុលរយៈពេលខ្លី (Current Liabilities) មានដូចជា គណនីត្រូវសង (Account Payable ) បំណុលរយៈបេលវែងដែលត្រូវសង (Short-Term debt/Current Portion of Long-Term debt) និង បំណុលរយៈពេលខ្លីដទៃទៀត (Other Current Liabilities) ។ ចំណែកឯទ្រព្យអកម្មរយៈពេលវែង ឬ បំណុលរយៈពេលវែង មានដូចជា បំណុលរយៈពេលវែង (Long-Term debt) បំណុលផ្សេងៗទៀត

(Other Liabilities) បំណុលដែលត្រូវពន្យា (Differed Liabilities Charge) និងការប្រាក់នៃភាពជាម្ចាស់ (Minority Interest)។

**មូលនិធិម្ចាស់ទ្រព្យ (Owner's Equity)**

មូលនិធិម្ចាស់មូលទ្រព្យ គឺជាភាពខុសគ្នានៃតម្លៃទ្រព្យសកម្មសរុប និងទ្រព្យអកម្មសរុប។ ជាទូទៅ មូលនិធិម្ចាស់ទ្រព្យ (Owner's Equity) រួមមានដូចជា ភាគហ៊ុនធម្មតា (Common Stock) ប្រាក់ចំណេញមូលធន (Capital surplus) ប្រាក់ចំណេញរក្សាទុក (Retained Earnings) ភាគហ៊ុនស្តុកទុក (Treasury Stock) មូលធនដទៃទៀត (Other Equity)។

### ១.២.២.៤. របាយការណ៍ចលនាលំហូរសាច់ប្រាក់ (Statement of Cash Flow)

❖ **និយមន័យ**

របាយការណ៍ចលនាលំហូរសាច់ប្រាក់ គឺជារបាយការណ៍ហិរញ្ញវត្ថុមួយប្រភេទដែលសង្ខេបអំពីព័ត៌មានដែលទាក់ទងទៅនឹងចលនាលំហូរសាច់ប្រាក់ចូល (Cash inflow) និងលំហូរសាច់ប្រាក់ចេញ (Cash outflow) សម្រាប់កំឡុងពេលជាក់លាក់ណាមួយ[9]។

សាច់ប្រាក់ គឺជាទ្រព្យចរន្តដ៏សំខាន់មួយរបស់ក្រុមហ៊ុន។ ប្រសិនបើក្រុមហ៊ុនគ្រប់គ្រងលំហូរសាច់ប្រាក់មិនបានល្អ វាអាចធ្វើឲ្យក្រុមហ៊ុនមានផលប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ រហូតអាចធ្វើឲ្យមានវិបត្តិហិរញ្ញវត្ថុ ឬប្រឈមមុខនឹងភាពក្ស័យធនផងដែរ។ អាស្រ័យហេតុនេះហើយក្រុមហ៊ុនត្រូវតែតាមដាននិងត្រួតពិនិត្យនូវលំហូរសាច់ប្រាក់ចូលរបស់ខ្លួនឲ្យបានប្រុងប្រយ័ត្ន។ យោងតាមរបាយការណ៍លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនគេអាចដឹង ពីចំនួនសាច់ប្រាក់ដែលក្រុមហ៊ុនបង្កើតបាន និងការចំណាយសាច់ប្រាក់ក្នុងកំឡុងពេលជាក់លាក់ណាមួយ។

ខាងក្រោមនេះ គឺជាទម្រង់គំរូរបាយការណ៍ចលនាលំហូរសាច់ប្រាក់ក្រុមហ៊ុន

Company Name

Statement of Cash Flow

For the year ended XXX, 20XX

| | | |
|---|---|---|
| Net Income | XXXX | |
| **Cash Flows-Operating Activities** | | |
| Depreciation | (XXXX) | |
| Net Income Adjustments | (XXXX) | |

[9] Acc, April 2011, F7 INT Study Text Financial Reporting, ទំព័រ៤៨៥

| | | |
|---|---|---|
| **Changes in Operating Activities** | | |
| Accounts Receivable | (XXXX) | |
| Changes in Inventories | (XXXX) | |
| Other Operating Activities | (XXXX) | |
| Liabilities | (XXXX) | |
| **Net Cash Flow-Operating** | | **XXXX** |
| **Cash Flows-Investing Activities** | | |
| Capital Expenditures | (XXXX) | |
| Investments | XXXX | |
| Other Investing Activities | XXXX | |
| **Net Cash Flows-Investing** | | **XXXX** |
| **Cash Flows-Financing Activities** | | |
| Sale and Purchase of Stock | (XXXX) | |
| Net Borrowings | XXXX | |
| Other Financing Activities | (XXXX) | |
| **Net Cash Flows-Financing** | | **XXXX** |
| Effect of Exchange Rate | XXXX | |
| **Net Cash Flow** | | **XXXX** |

### ❖ សមាសធាតុសំខាន់ៗនៅក្នុងរបាយការណ៍ចលនាលំហូរសាច់ប្រាក់

អង្គភាពអាជីវកម្ម ទទួលបានសាច់ប្រាក់ និងចំណាយសាច់ប្រាក់តាមរយៈសកម្មភាពបី គឺ សកម្មភាពប្រតិបត្តិការ ការវិនិយោគ និងហិរញ្ញប្បទាន។

លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ (Cash flows - operating activities) គឺជាសាច់ប្រាក់ទាំងឡាយណាដែលបានមកពីប្រតិបត្តិការជួញដូរទូទៅរបស់អង្គភាព ទាំងលំហូរសាច់ប្រាក់ចូល និង លំហូរសាច់ប្រាក់ចេញ។ ចំពោះក្រុមហ៊ុនអាជីវកម្មជាទូទៅ លំហូរសាច់ប្រាក់បានមកពីការលក់ទំនិញ សេវាកម្ម និងចំណូលផ្សេងៗទៀតរបស់ក្រុមហ៊ុន។ រីឯលំហូរសាច់ប្រាក់ចេញត្រូវបានចំណាយទៅលើ ឥណទេយ្យ សកម្មភាពប្រតិបត្តិការអាជីវកម្មផ្សេងៗ និងបំណុលជាដើម។

លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ (Cash flow – investing activities) គឺជាសាច់ប្រាក់បានមកពីការទិញ ឬលក់ទ្រព្យរយៈពេលវែង។ លំហូរសាច់ប្រាក់ចូល ត្រូវបានកើតឡើងតាមរយៈ

ការទទួលបានភាគលាភ ឬការប្រាក់ពី ការវិនិយោគផ្សេង ឬប្រាក់ដែលបានមកពីការវិនិយោគលើប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុន។ ចំណែកឯលំហូរសាច់ប្រាក់ចេញមានដូចជា ការចំណាយដើមទុននៅក្នុងការវិនិយោគ ការវិនិយោគរយៈពេលវែង និងការវិនិយោគផ្សេងទៀត។

លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន(Cash flow – financing activities) គឺជាសាច់ប្រាក់ដែលបានមកពីសកម្មភាពដែលមានឥទ្ធិពលទៅលើសមាសធាតុមូលធន និងទ្រព្យអកម្មរបស់ក្រុមហ៊ុនជាដើម។ លំហូរសាច់ប្រាក់ចូលពីសកម្មភាពខាងលើរួមមាន ការបោះផ្សាយលក់ប័ណ្ណ ភាគហ៊ុន និងការទទួលបានឥណទានរយៈពេលវែង និងសកម្មភាពហិរញ្ញវត្ថុផ្សេងៗ។ ចំណែកឯចំណាយសាច់ប្រាក់ចេញវិញគឺ ការទិញការទិញភាគហ៊ុនចូលវិញ និងសកម្មភាពហិរញ្ញវត្ថុផ្សេងៗ។

## ១.៣. ប្រភេទនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

### ១.៣.១. ការវិភាគតាមជួរឈរ ( Vertical Analysis )

ការវិភាគតាមជួរឈរ (Vertical Analysis) គឺជាការវិភាគដោយគណនាភាគរយនៃធាតុនីមួយៗក្នុងរបាយការណ៍ហិរញ្ញវត្ថុធៀបនឹងលទ្ធផលសរុប។ការវិភាគនេះ ត្រូវបានគេហៅថាជាការវិភាគជួរឈរព្រោះដោយសារតែការតំរៀបនូវភាគរយនៃធាតុទាំងនោះជាជួរឈរលើរបាយការណ៍ហិរញ្ញវត្ថុ។

លទ្ធផលរួម ដែលប្រើជាភាគបែងក្នុងការវិភាគតាមជួរឈរលើរបាយការណ៍លទ្ធផល គឺប្រាក់ចំណូលសុទ្ធ (Net Sales)។ រីឯតារាងតុល្យការវិញ ការគណនា គឺផ្អែកលើទ្រព្យសកម្មសរុប។ វិធីសាស្ត្រនេះ គេអាចហៅម៉្យាងទៀតថាជា **ការវិភាគរបាយការណ៍ហិរញ្ញវត្ថុទំហំទូទៅ** (Common Size Financial Statements)។ តារាងតុល្យការ និងរបាយការណ៍លទ្ធផលបង្ហាញតាមទំហំទៅ ធ្វើឲ្យមានភាពងាយស្រួលក្នុងការប្រៀបធៀប បើទោះបីកំឡុងពេលច្រើនឆ្នាំសម្រាប់អង្គភាពតែមួយ ឬអង្គភាពច្រើន។ ខាងក្រោមនេះជារូបមន្តសម្រាប់ការវិភាគតាមជួរឈរ៖

$$\text{Income Statement Vertical Analysis \%} = \frac{\text{Each Income Statement Item}}{\text{Net Sales}}$$

$$\text{Balance Sheet Vertical Analysis \%} = \frac{\text{Each Balance Sheet Item}}{\text{Total Assets}}$$

ការវិភាគជួរឈរលើធាតុរបាយការណ៍លទ្ធផល អាចផ្តល់នូវព័ត៌មានសំខាន់ស្តីពីកម្រិតនៃការចូលរួមរបស់ប្រភពចំណូលដែលបានពីផលិតផល និងសេវានីមួយៗដែលអង្គភាពមាន។ ការវិភាគនេះ អាចឲ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដឹងពីប្រភពចំណូលចម្បងរបស់អង្គភាព និងអ្នកគ្រប់គ្រងអាចធ្វើការសម្រេចចិត្តលើផែនការលក់ និងផ្សព្វផ្សាយពាណិជ្ជកម្មលើផលិតផល ក៏ដូចជាសេវាកម្មដែលខ្លួនគិតថាមានសក្តានុពល និងផ្តល់ចំណេញខ្ពស់។ ចំណែកឯការវិភាគជួរឈរលើប្រភេទចំណាយផ្សេងៗ អាចឲ្យអ្នកប្រើប្រាស់ដឹងពីកម្រិតចំណាយ និងប្រភេទចំណាយដែលអង្គភាពបានចំណាយ។ ការវិភាគនេះនឹងធ្វើឲ្យអ្នកគ្រប់គ្រងកម្រិតចំណាយរបស់អង្គភាព និងចាត់វិធានការដោះស្រាយនៅពេលដែលចំណាយណាមួយមានភាគរយធៀបនឹងចំណូលសុទ្ធ កើនខ្លាំងលើសពីការគ្រោងទុក។

ការវិភាគតាមជួរឈរលើធាតុនៃរបាយការណ៍តុល្យការ អាចឲ្យអ្នកប្រើប្រាស់ដឹងពីទំហំ និងសារៈសំខាន់របស់ធាតុទាំងនោះក្នុងអាជីវកម្មរបស់អង្គភាព ព្រោះថាបើធាតុណាមួយធំជាងគេនោះមានន័យថាធាតុទាំងនោះ ត្រូវបានក្រុមហ៊ុនប្រើប្រាស់ញឹកញាប់ក្នុងអាជីវកម្ម ដើម្បីស្វែងរកចំណូល ឬផ្គត់ផ្គង់តម្រូវការធនធានសេដ្ឋកិច្ច[10]។

### ១.៣.២. **ការវិភាគតាមជួរដេក** (Horizontal Analysis)

ការវិភាគតាមជួរដេក (Horizontal Analysis) គឺជាការវិភាគទិន្នន័យនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីប្រៀបធៀបនូវកម្រិតប្រែប្រួលពីមួយឆ្នាំ ទៅមួយឆ្នាំ ដែលទាក់ទងទៅនឹងផ្នែកហិរញ្ញវត្ថុ។ ការវិភាគនេះ អាចបង្ហាញពីទិសដៅ ល្បឿន និងការពង្រីកនៃនិន្នាការ។ ការវិភាគតាមជួរដេក ត្រូវបានធ្វើការវិភាគពីឆ្វេងទៅស្តាំ ឬពីស្តាំទៅឆ្វេងនៃសមតុល្យរបស់គណនីនីមួយៗ លើរបាយការណ៍ហិរញ្ញវត្ថុ។ ជាទូទៅ ដើម្បីវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរដេក គេត្រូវការទិន្នន័យចាប់ពីពីរឆ្នាំឡើងទៅសម្រាប់ធ្វើការប្រៀបធៀបគ្នា និងធ្វើការគណនា។ ទិន្នន័យដែលមានរយៈពេលកាន់តែច្រើនឆ្នាំបន្តបន្ទាប់គ្នា គឺកាន់តែធ្វើឲ្យការវិភាគនេះមានភាពស្រួល និងច្បាស់លាស់[11]។

ក្នុងការគណនាភាគរយនៃបម្រែបម្រួលតម្រូវឲ្យមានដំណាក់កាលគឺៈ

១. គណនាចំនួននៃបម្រែបម្រួលពីកំឡុងពេលមួយ (កំឡុងពេលគោល) ទៅកំឡុងពេលមួយទៀត។

[10] Eugene F. Brigham, Michael C. Ehrhardt, Financial Management (២០០២), ទំព័រ ៩០

[11] Walter T.Harrison, Jr. and Charles T. Horngren, Financial Accounting (២០០៨), ទំព័រ៦៨៧-៦៨៨។

២. ចែកលទ្ធផលបម្រែបម្រួលនោះជាមួយនឹងចំនួននៅក្នុងកំឡុងពេលគោល។

$$\text{Percentage Change} = \frac{\text{Dollar Amount of Change}}{\text{Base-year Amount}}$$

**តារាងទី១** ការវិភាគតាមជួរដេកទៅលើ របាយការណ៍លទ្ធផល

| Income Statements | 20X1 | 20X2 | Increase (Decrease) | |
|---|---|---|---|---|
| | | | Amount | Percentage |
| Revenues | a | b | b-a | (b-a)/b |
| Expenses | c | d | d-c | (d-c)/d |

**តារាងទី២** ការវិភាគតាមជួរដេកទៅលើ តារាងតុល្យការ

| Balance Sheet | 20X1 | 20X2 | Increase (Decrease) | |
|---|---|---|---|---|
| | | | Amount | Percentage |
| Assets | a | b | b-a | (b-a)/b |
| Liabilities | c | d | d-c | (d-c)/c |
| Equity | e | f | f-e | (f-e)/f |

### ១.៣.៣. ការវិភាគដោយប្រើប្រាស់រូបមន្តអនុបាត (Ratio Analysis)

ការវិភាគអនុបាតហិរញ្ញវត្ថុ គឺជាការគណនានូវអនុបាតដោយប្រើទិន្នន័យពីរបាយការណ៍ហិរញ្ញវត្ថុ និងការបកស្រាយនូវលទ្ធផលដែលទទួលបានពីការគណនា ដើម្បីកំណត់នូវទំនោរ និងការប្រែប្រួលហើយត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការសម្រេចចិត្តរបស់អ្នកប្រើប្រាស់។

#### ១.៣.៣.១. អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី (Short-term Solvency Ratios)

អនុបាតសម្រាប់វាស់វែងពីលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងនូវកម្រិតសន្ទនីយភាពរបស់ក្រុមហ៊ុន។ អ្នកគ្រប់គ្រងយកចិត្តទុកដាក់ខ្លាំងលើកម្រិតសន្ទនី

យភាពរបស់ក្រុមហ៊ុន ព្រោះប្រសិនបើគ្មានសាច់ប្រាក់គ្រប់គាន់ទេនោះ នឹងអាចជួបប្រទះនឹងភាពរាំងស្ទះដល់ប្រតិបត្តិការ ឬឈានដល់បិទក្រុមហ៊ុនទៀតផង។

អនុបាតសម្រាប់វាស់វែងកម្រិតសន្ទនីយភាពរបស់អង្គភាពរួមមាន៖

**ក. អនុបាតចរន្ត (Current Ratio)**

អនុបាតចរន្ត គឺជាអនុបាតដែលត្រូវបានគេប្រើប្រាស់សម្រាប់វាស់វែងពីសាច់ប្រាក់របស់ក្រុមហ៊ុន និងសុវត្ថិភាពរបស់អាជីវកម្ម ហើយវាបានបង្ហាញនូវសមត្ថភាពរបស់ក្រុមហ៊ុនដើម្បីទូទាត់បំណុលរយៈពេលខ្លី។ បើលទ្ធផលនៃអនុបាតនេះមានទំហំធំជាង១ វាបញ្ជាក់ពីល្បឿនយ៉ាងលឿនរបស់ចលនាសាច់ប្រាក់នៅក្នុងក្រុមហ៊ុន។ ប្រសិនបើលទ្ធផលខាងលើមាន កម្រិតតូចជាង១ នោះបង្ហាញថាក្រុមហ៊ុននឹងជួបនូវបញ្ហាហិរញ្ញវត្ថុ។[12] អនុបាតចរន្តអាចគណនាតាមរូបមន្តដូចខាងក្រោម៖

$$\text{Current Ratio} = \frac{\text{Current Assets}}{\text{Current Liabilities}}$$

**ខ. អនុបាតរហ័ស (Quick Ratio)**

អនុបាតរហ័ស គឺជាអនុបាតដែលត្រូវបានប្រើដើម្បីវាស់វែងពីលទ្ធភាពរបស់អង្គភាពក្នុងការទូទាត់បំណុលរយៈពេលខ្លី ដោយមិនចាំបាច់លក់សន្និធិ ឬទទួលយកនូវហិរញ្ញប្បទានបន្ថែមពីខាងក្រៅ។កាលណាអនុបាតនេះមានកម្រិតខ្ពស់ អង្គភាពកាន់តែមានស្ថានភាពហិរញ្ញវត្ថុល្អ ប៉ុន្តែបើវាមានកម្រិតទាប នោះអង្គភាពនឹងមានការលំបាក ឬរាំងស្ទះសាច់ប្រាក់ក្នុងការទូទាត់បំណុល[12]។

$$\text{Quick Ratio} = \frac{\text{Current Assets - Inventory}}{\text{Current Liabilities}}$$

**គ. អនុបាតសាច់ប្រាក់ (Cash Ratio)**

អនុបាតសាច់ប្រាក់ គឺជាផលធៀបរវាងសាច់ប្រាក់ និងបំណុលរយៈពេលខ្លី។ កាលណាតួលេខរបស់អនុបាតនេះ កាន់តែធំវាមានលក្ខណៈល្អប្រសើរសម្រាប់ម្ចាស់បំណុលរយៈពេលខ្លី ប៉ុន្តែ

[12] Berk J., DeMarzo P. and Harford J, Fundamentals of Corporate Finance បោះពុម្ពលើកទី២, ទំព័រ៣២

សម្រាប់អង្គភាពវិញអាចត្រូវបានគេវាយតម្លៃថាមានសាច់ប្រាក់ច្រើនទុកចោល មិនបានយកទៅប្រើប្រាស់ក្នុងការរកចំណូល[13]។ អនុបាតសាច់ប្រាក់ មានរូបមន្តដូចខាងក្រោម៖

$$\text{Cash Ratio} = \frac{\text{Cash}}{\text{Current Liabilities}}$$

### ១.៣.៣.២. អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង (Long-term Solvency Ratios)

អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង គឺជាអនុបាតដែលត្រូវបានប្រើដើម្បីវាស់វែងនូវកម្រិតជាប់បំណុលរបស់អង្គភាព ជាពិសេសលទ្ធភាពរបស់អង្គភាពក្នុងការគោរពកាតព្វកិច្ចសងបំណុលដែលដល់កាលកំណត់សង។ អនុបាតនេះ រួមមាន៖

**ក. អនុបាតបំណុលសរុប (Total Debt Ratio)**

អនុបាតបំណុលសរុប គឺជាអនុបាតដែលវាស់វែងពីកម្រិតទ្រព្យសកម្មរបស់អង្គភាពដែលត្រូវបានផ្គត់ផ្គង់ដោយបំណុល។ បំណុលសរុបរួមបញ្ចូលទាំងបំណុលចរន្ត និងបំណុលរយៈពេល វែង។ ម្ចាស់បំណុលចង់ដឹងពីកម្រិតបំណុលរបស់អង្គភាព ព្រោះថាបើអនុបាតនេះកាន់តែទាបនោះ កម្រិតការពារនៃការខាតបង់របស់ម្ចាស់បំណុលនឹងកាន់តែខ្ពស់ ប្រសិនបើអង្គភាពត្រូវរំលាយ។ ចំណែកឯម្ចាស់ក្រុមហ៊ុនវិញ គឺចង់ឲ្យអង្គភាពប្រើបំណុលនេះកាន់តែច្រើន ព្រោះវាអាចបង្កើនប្រាក់ចំណេញរំពឹងទុករបស់ពួកគេ។ ដូចនេះ អ្នកគ្រប់គ្រងត្រូវសម្រេចចិត្តលើកម្រិតបំណុលដែលក្រុមហ៊ុនគួរប្រើប្រាស់ ដើម្បីកុំឲ្យបង្កើនហានិភ័យនៃការគ្មានលទ្ធភាពសងបំណុលវិញ[14]។ វាមានរូបមន្តដូចខាងក្រោម៖

$$\text{Total Debt Ratio} = \frac{\text{Total Liabilities}}{\text{Total Assets}}$$

**ខ. អនុបាតបំណុលធៀបនឹងមូលធន** (Debt to Equity Ratio)

អនុបាតបំណុលធៀបនឹងមូលធន គឺជាអនុបាតវាស់វែងពីភាគរយនៃបំណុលធៀបនឹងមូលធនរបស់អង្គភាព ដើម្បីដឹងពីលទ្ធភាពសងត្រលប់របស់មូលធន ប្រសិនបើអង្គភាពត្រូវបាន

[13] Berk J., DeMarzo P. and Harford J, Fundamentals of Corporate Finance បោះពុម្ពលើកទី២, ទំព័រ៣២

[14] Eugene F. Brigham, Michael C. Ehrhardt, Financial Management (២០០២), ទំព័រ ៨២។

រំលាយ។ អង្គភាពដែលមានបំណុលធៀបជាមួយនឹងមូលធនខ្ពស់ គឺទទួលបាននូវហានិភ័យខ្លាំង ប្រសិនបើមានវិបត្តិសេដ្ឋកិច្ច ព្រោះទោះជាចំណូលរបស់អង្គភាពធ្លាក់ចុះក៏ដោយ ក៏អង្គភាពនៅតែមានកាតព្វកិច្ចសងការប្រាក់ និងប្រាក់ដើមដែលជំពាក់។ ចំណែកឯមូលធនរបស់ម្ចាស់ភាគហ៊ុនវិញ អង្គភាពមិនមានកាតព្វកិច្ចសងប្រាក់វិនិយោគវិញឡើយ ហើយការបែងចែកភាគលាភអាចត្រូវបានពន្យា រហូតដល់ពេលដែលប្រាក់ចំណេញអង្គភាពងើបឡើងវិញ[15]។ ខាងក្រោមនេះ ជារូបមន្តរបស់បំណុលធៀបនឹងមូលធន៖

$$\text{Debt to Equity Ratio} = \frac{\text{Total Liabilities}}{\text{Total Equity}}$$

### គ .មេគុណមូលធន (Equity Multiplier)

មេគុណមូលធន គឺជាសមាមាត្រអានុភាពហិរញ្ញវត្ថុមួយ ដែលត្រូវបានគណនាដោយបែងចែកទ្រព្យសកម្មសរុបដោយមូលធនភាគទុនិក។ វានឹងបង្ហាញអំពី ទ្រព្យសកម្មប៉ុន្មានដុល្លារក្នុងមូលធនមួយដុល្លារ។ ករណីមេគុណនេះកាន់តែខ្ពស់មានន័យថាក្រុមហ៊ុនប្រើប្រាស់បំណុលកាន់តែច្រើនក្នុងការវិនិយោគលើទ្រព្យសកម្ម ប៉ុន្តែប្រសិនបើមេគុណនេះកាន់តែទាបមានន័យថាក្រុមហ៊ុនប្រើប្រាស់បំណុលកាន់តែតិចក្នុងការវិនិយោគលើទ្រព្យសកម្ម[16] ។

$$\text{Equity Multiplier} = \frac{\text{Total Assets}}{\text{Total Equity}}$$

### ឃ. អនុបាតចំនួនដងនៃការចំណាយការប្រាក់ (Times Interest Earned Ratio)

អនុបាតចំនួនដងនៃការចំណាយការប្រាក់ គឺប្រើសម្រាប់វាស់ពីលទ្ធភាពដែលប្រាក់ចំណេញពីប្រតិបត្តិការរបស់អង្គភាពអាចធ្លាក់ចុះ មុននឹងអង្គភាពមិនមានលទ្ធភាពសងការប្រាក់។ ការមិនសងការប្រាក់តាមកាលកំណត់ អាចនាំឲ្យមានការប្តឹងពីម្ចាស់បំណុល ហើយអាចឈានទៅដល់ការក្ស័យធនផងដែរ[17]។ អនុបាតនេះ ត្រូវបានគណនាដោយចែកប្រាក់ចំណេញមុនចំណាយការប្រាក់ និងពន្ធជាមួយនឹងចំណាយការប្រាក់។

---

[15] Belverd E. Needles and Marian Powersm, Financial Accounting (២០០៧), ទំព័រ ២៥២។

[16] ដកស្រង់ចេញពីគេហទំព័រ https://www.myaccountingcourse.com/financial-ratios/equity-multiplier (ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៩)

[17]Eugene F. Brigham, Michael C. Ehrhardt, Financial Management (២០០២), ទំព័រ ២៥២។

$$\text{Times Interest Earned Ratio} = \frac{\text{Earnings Before Interest and Tax}}{\text{Interest}}$$

### ១.៣.៣.៣. អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្ម ( Asset Utilization )

អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសកម្ម ក្នុងការស្វែងរកប្រាក់ចំណូលដល់ក្រុមហ៊ុន។ អនុបាតនៃលទ្ធភាពប្រើប្រាស់ទ្រព្យសកម្មរួមមាន៖

#### ក. អនុបាតបង្វិលជុំនៃសន្និធិ (Inventory Turnover)

អនុបាតបង្វិលជុំនៃសន្និធិ ជាអនុបាតដែលបង្ហាញពីចំនួនដងដែល អង្គភាពបញ្ចេញសន្និធិ ហើយទិញចូល ឬផលិតសន្និធិទាំងនោះឡើងវិញកំឡុងពេលណាមួយ។ អនុបាតនេះអាចជួយអ្នកគ្រប់គ្រងអង្គភាពធ្វើការសម្រេចចិត្តកាន់តែមានប្រសិទ្ធិភាពលើតម្លៃ ដំណើរការនៃការផលិត ការធ្វើទីផ្សារ និងនាំចូលនូវសន្និធិថ្មីផងដែរ។ កាលណាលទ្ធផលដែលទទួលបានពីការគណនាអនុបាតនេះកាន់តែទាប បង្ហាញពីការលក់ខ្សោយ និងសន្និធិមានចំនួនលើសពីតម្រូវការ ប៉ុន្តែបើលទ្ធផលវាកាន់តែខ្ពស់មានន័យថាការលក់មានភាពខ្លាំង និងសន្និធិអាចផ្គត់ផ្គង់ស្របតម្រូវការ[18]។ អនុបាតនេះមានរូបមន្តដូចខាងក្រោម៖

$$\text{Inventory Turnover} = \frac{\text{Cost of Goods Sold}}{\text{Inventory}}$$

#### ខ. អនុបាតចំនួនថ្ងៃនៃការលក់សន្និធិ (Day's Sale in Inventory)

អនុបាតចំនួនថ្ងៃនៃការលក់សន្ទធិ ជាអនុបាតដែលបង្ហាញពីចំនួនថ្ងៃជាមធ្យមដែលត្រូវបានចំណាយពេលសម្រាប់អង្គភាពមួយ ក្នុងការលក់ចេញនូវសន្និធិ។ អនុបាតនេះជាមូលដ្ឋានមួយសម្រាប់អ្នកគ្រប់គ្រង ប្រើប្រាស់ដើម្បីកំណត់នូវប្រសិទ្ធិភាពនៃការលក់ ហើយប្រសិនបើតួលេខអនុបាតនេះខ្ពស់ មានន័យថាអង្គភាពមួយនោះគ្រប់គ្រងសន្និធិមិនបានល្អ ឬអាចមានសន្និធិដែលពិបាកលក់ចេញ[19]។ អនុបាតនេះមានរូបមន្តដូចខាងក្រោម៖

---

[18] ដកស្រង់ចេញពីគេហទំព័រ https://www.investopedia.com/terms/i/inventoryturnover.asp (ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៩)

[19] ដកស្រង់ចេញពីគេហទំព័រ https://www.investopedia.com/terms/d/days-sales-inventory-dsi.asp(ចូលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៩)

$$\text{Days' Sales in Inventory} = \frac{\text{365 days}}{\text{Inventory Turnover}}$$

### គ. អនុបាតបង្វិលជុំនៃឥណទេយ្យ (Receivable Turnover)

អនុបាតបង្វិលជុំនៃឥណទេយ្យ គឺជាអនុបាតមួយដែលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងពីចំនួនដងដែលឥណទេយ្យត្រូវបានបង្វិលក្នុងមួយឆ្នាំ និងបង្ហាញពីកម្រិតប្រសិទ្ធិភាពរបស់អង្គភាពក្នុងការប្រមូលឥណទេយ្យ ឬប្រាក់ដែលអតិថិជនជំពាក់។ Receivables Turnover មានកម្រិតខ្ពស់បង្ហាញថាការប្រមូលឥណទេយ្យរបស់អង្គភាពមានប្រសិទ្ធិភាព និងមានចំនួនអតិថិជនច្រើនដែលសងបំណុលលឿន។ ផ្ទុយមកវិញ បើ Receivables Turnover មានកម្រិតទាប បង្ហាញថាការប្រមូលឥណទេយ្យរបស់អង្គភាពមានភាពខ្សោយ និងមានចំនួនអតិថិជនច្រើនដែលសងបំណុលមិនទាន់កាលកំណត់[20]។ អនុបាតនេះអាចគណនាដូចខាងក្រោម៖

$$\text{Receivables Turnover} = \frac{\text{Sales}}{\text{Accounts Receivable}}$$

### ឃ. អនុបាតចំនួនថ្ងៃដែលឥណទេយ្យសង (Days' Sale in Receivable)

អនុបាតចំនួនថ្ងៃដែលឥណទេយ្យសង គឺជាអនុបាតដែលបង្ហាញពីចំនួនថ្ងៃជាមធ្យមដែលត្រូវបានចំណាយពេលសម្រាប់អង្គភាពមួយ ក្នុងការប្រមូលប្រាក់ជំពាក់ពី អតិថិជន បន្ទាប់ពីការលក់បានកើតឡើង។ អនុបាតនេះ អាចវាស់វែងពីកម្រិតដែលអតិថិជនសងប្រាក់លឿន ឬ យឺត និងប្រសិទ្ធិភាពនៃការគ្រប់គ្រងឥណទេយ្យរបស់អង្គភាពមួយ [21] ។ អនុបាតនេះមានរូបមន្តដូចខាងក្រោម៖

$$\text{Days' Sales in Receivables} = \frac{\text{365 days}}{\text{Receivables Turnover}}$$

### ង. អនុបាតដើមទុនចរន្តសុទ្ធ (Net Working Capital Turnover)

[20] ដកស្រង់ចេញពីគេហទំព័រ https://www.investopedia.com/terms/r/receivableturnoverratio.asp (ចូលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៩)

[21] ដកស្រង់ចេញពីគេហទំព័រ https://www.investopedia.com/terms/d/dso.asp (ចូលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៩)

អនុបាតដើមទុនចរន្តសុទ្ធ ប្រើសម្រាប់វាស់វែងនូវប្រសិទ្ធិភាពរបស់អង្គភាព ក្នុងការស្វែងរកប្រាក់ចំណូលដោយប្រើប្រាស់ដើមទុនចរន្តសុទ្ធដែលខ្លួនមាន។ យើងអាចនិយាយម៉្យាងទៀតថាជាប្រាក់ចំណូលដែលទទួលបានពីទ្រព្យសកម្មរយៈពេលខ្លីសុទ្ធដែលត្រូវបានដកជាមួយបំណុលរយៈពេលខ្លីរួច។ អង្គភាពដែលមាន NWC Turnover ខ្ពស់មានន័យថាអង្គភាពនោះ បានប្រើប្រាស់ទ្រព្យសកម្មរយៈពេលខ្លីសុទ្ធបានល្អជាងក្រុមហ៊ុនដែលមាន NWC Turnover ទាបជាង[22]។ អនុបាតនេះគណនាតាម៖

$$\text{NWC Turnover} = \frac{\text{Sales}}{\text{NWC}}$$

### ច. អនុបាតបង្វិលជុំនៃទ្រព្យសកម្មរយៈពេលវែង (Fixed Asset Turnover)

អនុបាតបង្វិលជុំនៃទ្រព្យសកម្មរយៈពេលវែង បង្ហាញពីការវាស់វែងនូវប្រសិទ្ធិភាពក្នុងការប្រើប្រាស់ និងការគ្រប់គ្រងនូវទ្រព្យសកម្មរយៈពេលវែងដែលក្រុមហ៊ុនទទួលបានដោយការវិនិយោគលើទ្រព្យសកម្មរយៈពេលវែង។ បើលទ្ធផលដែលទទួលបានកាន់តែខ្ពស់មានន័យថា អង្គភាពមានសមត្ថភាពនៅក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសកម្មរយៈវែងឲ្យអស់លទ្ធភាព តែបើមានកម្រិតទាបវិញនោះ មានន័យថាការប្រើប្រាស់ និងការគ្រប់គ្រងទ្រព្យសកម្មរបស់អង្គភាពគឺមិនមានប្រសិទ្ធិភាព ឡើយ[23]។

$$\text{Fixed Asset Turnover} = \frac{\text{Sales}}{\text{Net Fixed Assets}}$$

### ឆ. អនុបាតការបង្វិលទ្រព្យសកម្មសរុប (Total Assets Turnover)

អនុបាតការបង្វិលទ្រព្យសកម្មសរុប ប្រើសម្រាប់វាស់វែងនូវប្រសិទ្ធិភាពរបស់អង្គភាព ក្នុងការស្វែងរកប្រាក់ចំណូលដោយប្រើប្រាស់ទ្រព្យសកម្មដែលខ្លួនមាន។ យើងអាចនិយាយម៉្យាងទៀតថាជាប្រាក់ចំណូលដែលទទួលបានពីទ្រព្យសកម្មមួយដុល្លារ។ អង្គភាពដែលមាន Total

[22] ដកស្រង់ចេញពីគេហទំព័រ https://www.investopedia.com/terms/w/workingcapitalturnover.asp (ចូលថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩)

[23] Ross Westerfield Jordan., Fundamentals Of Corporate Finance, បោះពុម្ពលើកទី៨, ទំព័រ ៦៣

Assets Turnover ខ្ពស់មានន័យថាអង្គភាពនោះ បានប្រើប្រាស់ទ្រព្យសកម្មបានល្អជាងក្រុមហ៊ុនដែលមាន Total Assets Turnover ទាបជាង[24]។ អនុបាតនេះ គណនាតាមៈ

$$\text{Total Asset Turnover} = \frac{\text{Sales}}{\text{Total Assets}}$$

### ១.៣.៣.៤. អនុបាតលទ្ធភាពស្វែងរកប្រាក់ចំណេញ ( Profitability ratios )

គ្រប់អង្គភាពអាជីវកម្មទាំងអស់ មានគោលដៅចម្បងមួយគឺប្រាក់ចំណេញ។អាស្រ័យហេតុនេះហើយទើបពួកគេខិតខំប្រឹងប្រែងធ្វើយ៉ាងណា ឲ្យអាជីវកម្មរបស់ពួកគេមានប្រាក់ចំណេញកាន់ខ្ពស់គឺកាន់តែប្រសើរ។ ដើម្បីឲ្យដឹងពីប្រសិទ្ធភាពនៃការបង្កើតប្រាក់ចមណេញបានលម្រិតណា គេប្រើប្រាស់មួយចំនួនដូចខាងក្រោម ៖

**ក. អនុបាតប្រាក់ចំណេញសុទ្ធ (Profit Margin ratio)**

អនុបាតប្រាក់ចំណេញសុទ្ធ គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធធៀប ជាមួយនឹងចំណូលនៃការលក់របស់ក្រុមហ៊ុនសរុប[25]។ អនុបាតនេះវាស់វែងពីលទ្ធភាពស្វែងរកប្រាក់ចំណេញសុទ្ធដែលក្រុមហ៊ុនទទួលបានរៀងរាល់មួយដុល្លារនៃប្រាក់ចំណូល។ ជាទូទៅរាល់អ្នកវិនិយោគទុននឹងម្ចាស់ភាគហ៊ុនគឺតែងតែមានការចាប់អារម្មណ៍ និងធ្វើការវាយតម្លៃពីប្រាក់ចំណេញរបស់ក្រុមហ៊ុន។ បើអនុបាតនេះកាន់តែធំ គឺកាន់តែល្អ ពីព្រោះបានបង្ហាញថាក្រុមហ៊ុនទទួលបានប្រាក់ចំណេញកាន់តែច្រើនពីប្រតិបត្តិការរបស់ខ្លួន។ វាត្រូវបានគេយកមកគណនាដោយផ្អែកលើរូបមន្តដូចខាងក្រោម ៖

$$\text{Profit Margin Ratio} = \frac{\text{Net Income}}{\text{Sales}}$$

**ខ. អនុបាតផលចំណេញពីមួយទ្រព្យសកម្ម (Return on Assets)**

អនុបាតផលចំណេញនៃទ្រព្យសកម្ម គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធ ជាមួយនឹងទ្រព្យសកម្មសរុបនៅក្នុងគ្រា ដើម្បីចង់ដឹងពីប្រាក់ចំណេញដែលអាជីវកម្មមានលទ្ធភាពបង្កើតដោយប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួន។ អនុបាតនេះមានតម្លៃកាន់តែធំ កាន់តែល្អប្រសើរ ព្រោះវា

[24] Belverd E. Needles and Marian powersm, Financial Accounting (២០០៧), ទំព័រ ២៤៩

[25] Peter S.Rose and Sylvia C. Hugin, 2010, Bank Management and Financial Service, Eight Edition, ទំព័រ ១៧៤

បង្ហាញពី ប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនក្នុងការបង្កើតប្រាក់ចំណេញកាន់តែប្រសើរ។ ក៏ប៉ុន្តែ បើអនុបាតនេះកាន់តែទាប មានន័យថាការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនគ្មានប្រសិទ្ធភាពក្នុងការបង្កើតប្រាក់ចំណេញ។

$$\text{Return on Assets} = \frac{\text{Net Income}}{\text{Total assets}}$$

### គ. អនុបាតផលចំណេញធៀបនឹងមូលធន (Return on Equity)

អនុបាតផលចំណេញធៀបនឹងមូលធន គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធ ធៀបជាមួយនឹងមូលធនសរុប ដើម្បីវាស់វែងប្រាក់ចំណេញដែលរកបានដោយអង្គភាព តាមរយៈការប្រើប្រាស់មូលធនដែលផ្តល់ឲ្យដោយម្ចាស់ភាគហ៊ុន។ វាបង្ហាញពីលទ្ធភាពស្វែងរកប្រាក់ចំណេញតាមរយៈការប្រើប្រាស់មូលធនមួយដុល្លារសម្រាប់វិនិយោគ គេអាចទទួលបានប្រាក់ចំណេញបានប៉ុន្មាន។ នៅក្នុងការគណនា ប្រសិនបើលទ្ធផលនៃអនុបាតកាន់តែធំ គឺកាន់តែល្អ ព្រោះមានន័យថាក្រុមហ៊ុនប្រើប្រាស់ មូលធនក្នុងការបង្កើតប្រាក់ចំណេញមានប្រសិទ្ធភាពខ្ពស់ ផ្ទុយមកវិញប្រសិនបើលទ្ធផលនៃអនុបាតកាន់តែតូចនោះ បញ្ជាក់ថាការប្រើប្រាស់មូលធនរបស់ក្រុមហ៊ុនគ្មានប្រសិទ្ធភាព។ ខាងក្រោមនេះជា រូបមន្តសម្រាប់គណនាអនុបាតប្រាក់ចំណេញធៀបនឹងមូលធន ៖

$$\text{Return on Equity} = \frac{\text{Net Income}}{\text{Total Equity}}$$

#### ១.៣.៣.៥. អនុបាតទីផ្សារ (Market Ratio)[26]

### ក. អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ (Price – Earnings Ratio)

អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ គឺជាផលធៀបតម្លៃទីផ្សារនៃភាគហ៊ុន ជាមួយនឹងប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ក្រុមហ៊ុន។ វាបង្ហាញ ពីតម្លៃទីផ្សារដែលអ្នកវិនិយោគត្រូវចំណាយក្នុងការទិញភាគហ៊ុនដើម្បីទទួលបានប្រាក់ចំណេញមួយដុល្លារ[27]។ ខាងក្រោមនេះ គឺជារូបមន្តដើម្បីចង់គណនាពីអនុបាតថ្លៃជាមួយប្រាក់ចំណេញ ៖

[26] ដកស្រង់ពីគេហទំព័រ https://www.readyratios.com/reference/profitability/return_on_assets.html (ចូលទស្សនា ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩)

$$\text{Price Earnings Ratio} = \frac{\text{Price Per share}}{\text{Earnings per Share}}$$

**ខ. អនុបាតទីផ្សារ (Market-to-book Ratio)**

អនុបាតទីផ្សារ គឺជាអនុបាតដែលត្រូវបានប្រើដើម្បីវាស់វែងពីតម្លៃភាគហ៊ុនរបស់អង្គភាពដោយប្រៀបធៀបតម្លៃទីផ្សាររបស់វាជាមួយនឹងតម្លៃដែលបានកត់ត្រាក្នុងបញ្ជី។ កាលណាអនុបាតនេះកាន់តែខ្ពស់ មានន័យថាតម្លៃទីផ្សារភាគហ៊ុនរបស់អង្គភាពមានតម្លៃខ្ពស់ជាងតម្លៃភាគហ៊ុនដែលបានកត់ត្រាក្នុងបញ្ជី។ អនុបាតនេះមានរូបមន្តដូចខាងក្រោម៖

$$\text{Market-to-book Ratio} = \frac{\text{Market Value per Share}}{\text{Book Value per Share}}$$

**១.៣.៤. ការវិភាគតាម Du Pont Identity**

ការវិភាគតាម Du Pont Identity ជាការវិភាគមួយដែលលម្អិតទៅលើកត្តាទាំងបីដែលមានឥទ្ធិពលទៅលើកម្រិតនៃប្រាក់ចំណេញពីមូលធនម្ចាស់ភាគហ៊ុន។ កត្តាទាំងនោះមានដូចជា៖ អត្រាប្រាក់ចំណេញ (Profit Margin) ប្រាក់ចំណូលពីការវិនិយោគលើទ្រព្យសកម្ម (Total Asset Turnover) និងអានុភាពហិរញ្ញវត្ថុ ឬមេគុណមូលធន (Financial Leverage/Equity Multiplier)។ អ្នកគ្រប់គ្រងអាចប្រើសមីការនៃ Du Pont Identity ដើម្បីវិភាគឲ្យកាន់តែស៊ីជម្រៅក្នុងការរកឲ្យឃើញនូវកត្តាចម្បងនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលអាចធ្វើឲ្យមូលធនម្ចាស់ភាគហ៊ុនទទួលបានប្រាក់ចំណេញខ្ពស់[28]។ ប្រសិនបើលទ្ធផលនៃ ROE ទទួលបានមិនល្អ ឬទាប ការវិភាគនេះអាចឲ្យអ្នកគ្រប់គ្រងក្រុមហ៊ុនដឹងពីចំណុចដែលត្រូវចាប់ផ្តើម ក្នុងការរកស្វែងមូលហេតុដែលប៉ះពាល់លើទិន្នផលរបស់ ROE ដែលវាអាចរងឥទ្ធិពលដោយកត្តា ៣ ខាងក្រោម៖

១. ប្រសិទ្ធិភាពនៃប្រតិបត្តិការ (Operating Efficiency វាស់វែងដោយ Profit Margin Ratio)

[27] ដកស្រង់ចេញពីគេហទំព័រ https://www.investopedia.com/terms/p/price-earningsratio.asp (ចូលទស្សនាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩)

[28] Ross Westerfield Jordan., Fundamentals Of Corporate Finance, បោះពុម្ពលើកទី៨, ទំព័រ ៦៧

២. ប្រសិទ្ធិភាពនៃការប្រើប្រាស់ទ្រព្យសកម្ម (Asset Use Efficiency វាស់វែងដោយ Total Asset Turnover)

៣. អនុភាពហិរញ្ញវត្ថុ (Financial Leverage វាស់វែងដោយ Equity Multiplier)

$$ROE = \text{Profit Margin} \times \text{Total Asset Turnover} \times \text{Equity Multiplier}$$

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុន Starbucks Corporation

## ២.១. ស្ថានភាពទូទៅ

### ២.១.១. ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Starbucks

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Starbucks មានទីតាំងនៅទីក្រុង Seattle រដ្ឋវ៉ាស៊ីនតោនសហរដ្ឋអាមេរិកដែលមានមនុស្សចំនួន ៣.៥០១ នាក់ធ្វើការនៅខែមករាឆ្នាំ ២០១៥។ អគារដ៏សំខាន់នៅក្នុងហាង Starbucks ពីមុនគឺជាមជ្ឈមណ្ឌលចែកចាយរបស់ Sears ។

រូបភាពទី៖ ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន Starbucks



### ២.១.២. ប្រវត្តិសង្ខេបក្រុមហ៊ុន Starbucks Corporation

ហាងកាហ្វេ Starbuck ត្រូវបានបើកដំណើរការជាលើកដំបូងនៅក្នុងទីក្រុង Seattle Washington ថ្ងៃទី៣១ ខែមីនា ឆ្នាំ ១៩៧១ ដោយមានដៃគូរសហការបីនាក់ដែលបានជួបគ្នាកំឡុងពេលជានិស្សិតនៅសាកល វិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ។ គ្រូបង្រៀនភាសាអង់គ្លេសលោក Jerry Baldwin គ្រូបង្រៀនប្រវត្តិសាស្រ្ត Zev Siegl និងអ្នកនិពន្ធហ្គរដុន (Gordon) ។ Bowker ត្រូវបានបំផុសគំនិតឱ្យលក់កាហ្វេ និងកាហ្វេដែលមានគុណភាពខ្ពស់ដោយសហគ្រិនដុតកាហ្វេឈ្មោះ Alfred Peet បន្ទាប់ពីគាត់បង្រៀនពួកគេនូវវិធីសាស្រ្តនៃការចម្អិនកាហ្វេ។ បានរំលឹកថា Terry Heckler ដែលលោក Terry Heckler ជាមួយលោក Bowker ដែលជាម្ចាស់ក្រុមហ៊ុនផ្សាយពាណិជ្ជកម្មមួយបានគិតថាពាក្យដែលចាប់ផ្តើមដោយ "st" គឺមានអំណាចខ្លាំង។ ស្ថាបនិកបាន

បំផុសគំនិតថ្មីជាមួយបញ្ជីពាក្យដែលចាប់ផ្តើមដោយ "st" ហើយទីបំផុតបានចុះចតនៅលើ "Starbo" ដែលជាទីក្រុងរ៉ែនៅក្នុងជួរ Cascade ។ ចាប់ពីពេលនោះមកក្រុមនេះបានចងចាំថា "Starbuck" ដែលជាឈ្មោះមេម៉ាយនៅក្នុងសៀវភៅ "Moby-Dick" ។ លោក Bowker បានមានប្រសាសន៍ថា "Moby-Dick" មិនមានអ្វីដែលត្រូវធ្វើជាមួយក្រុមហ៊ុន Starbucks ដោយផ្ទាល់នោះទេវាគ្រាន់តែជារឿងចៃដន្យប៉ុណ្ណោះដែលសម្លេងហាក់ដូចជាទាក់ទងគ្នា ។

ហាងលក់កាហ្វេ Starbucks ដំបូងគេមានទីតាំងនៅទីក្រុងស៊ីថលនៅឯខាងលិចរុក្ខវិថី ២០០០ ចាប់ពី១៩៧១-១៩៧៦។ ក្រោយមកហាងកាហ្វេនេះត្រូវបានគេផ្លាស់ប្តូរនៅ ឆ្នាំ១៩១២ ទៅនៅតំបន់ Pike Place។ ក្នុងអំឡុងពេលនេះក្រុមហ៊ុននេះបានលក់តែគ្រាប់កាហ្វេគ្រាប់ហើយមិនទាន់បានឆុងកាហ្វេដើម្បីលក់នៅឡើយទេ។ ក្នុងកំឡុងពេលប្រតិបត្តិការនៅក្នុងឆ្នាំដំបូងក្រុមហ៊ុន Starbucks បានទិញគ្រាប់កាហ្វេបៃតងពី Peet បន្ទាប់មកទៀតបានចាប់ផ្តើមទិញដោយផ្ទាល់ពីអ្នកដាំ។

ក្នុងឆ្នាំ ១៩៨៤ ម្ចាស់ដើមរបស់ហាង Starbucks ដែលដឹកនាំដោយលោក Jerry Baldwin បានទិញយកគ្រាប់កាហ្វេពី Peet។ ក្នុងកំឡុងទសវត្សឆ្នាំ១៩៨០ ការលក់កាហ្វេនៅសហរដ្ឋអាមេរិកបានធ្លាក់ចុះប៉ុន្តែការលក់កាហ្វេពិសេសបានកើនឡើងដែលបង្កើតបាន១០% នៃទីផ្សារ នៅក្នុងឆ្នាំ ១៩៨៩ បើប្រៀបធៀបទៅនឹង ៣% នៅឆ្នាំ១៩៨៣ ។ គិតមកត្រឹមឆ្នាំ ១៩៨៦ ក្រុមហ៊ុនបានបើកហាងចំនួនប្រាំមួយនៅទីក្រុងស៊ីថលហើយគ្រាន់តែចាប់ផ្តើមលក់កាហ្វេ espresso ។

ក្នុងឆ្នាំ ១៩៨៧ ម្ចាស់ដើមបានលក់ខ្សែសង្វាក់ Starbucks ទៅអតីតអ្នកគ្រប់គ្រង Howard Schultz ដែលបានប្តូរឈ្មោះហាងកាហ្វេ Il Giornale ជា Starbucks ហើយបានចាប់ផ្តើមពង្រីកខ្លួនយ៉ាងឆាប់រហ័សផងដែរ។ នៅក្នុងឆ្នាំដដែល Starbucks បានបើកទីតាំងដំបូងរបស់ខ្លួននៅខាងក្រៅទីក្រុង Seattle នៅឯស្ថានីយ៍ Waterfront នៅ Vancouver, British Columbia និង Chicago, Illinois ។ នៅក្នុងឆ្នាំ ១៩៨៩ Starbucks មានហាងចំនួន ៤៦ កន្លែងនៅទូទាំងភាគពាយ័ព្យ និងភាគខាងលិច ហើយជារៀងរាល់ឆ្នាំហាងកាហ្វេ Starbucks ត្រូវបានគេដុតកាហ្វេជាង ២.០០០.០០០ ផោន (៩០៧.១៨៥គីឡូ) នៃកាហ្វេ។

នៅក្នុងពេលនៃការផ្តល់ជូនជាសាធារណៈលើកដំបូងរបស់ខ្លួន (IPO) នៅលើទីផ្សារភាគហ៊ុននៅក្នុងខែ មិថុនា ឆ្នាំ ១៩៩២ ហាងកាហ្វេ Starbucks មានទីតាំង ១៤០ កន្លែងលក់ដោយមានប្រាក់ចំណូលចំនួន ៧៣.៥លានដុល្លារ មានការកើនឡើងពី ១.៣លានដុល្លារ ក្នុងឆ្នាំ ១៩៨៧តម្លៃទីផ្សាររបស់ក្រុមហ៊ុននេះគឺ ២៧១ លានដុល្លារមកត្រឹមពេលនោះ។ ភាគហ៊ុនចំនួន

១២% នៃក្រុមហ៊ុនដែលត្រូវបានលក់បានកើនឡើងប្រមាណជា ២៥លានដុល្លារសម្រាប់ក្រុមហ៊ុនដែលសម្របសម្រួលទ្វេដង នៃចំនួនហាងលក់ក្នុងរយៈពេលពីរឆ្នាំខាងមុខនេះ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៩២ តម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន Starbucks បានកើនឡើង ៧០% ដល់ជាង ១០០ដងនៃប្រាក់ចំណូលក្នុងមួយហ៊ុននៃឆ្នាំមុន។

នៅក្នុងខែកក្កដាឆ្នាំ ២០១៣ ការទិញទំនិញនៅក្នុងហាងលើសពី១០% ត្រូវបានធ្វើឡើងលើទូរស័ព្ទចល័តរបស់អតិថិជនដោយប្រើកម្មវិធី Starbucks ។ ក្រុមហ៊ុននេះបានប្រើប្រាស់វេទិការទូរស័ព្ទចល័តម្តងទៀតនៅពេលដែលខ្លួនបានចាប់ផ្តើមការផ្សព្វផ្សាយ "Tweet-a-Coffee" កាលពីខែតុលា ឆ្នាំ ២០១៣។ នៅក្នុងឱកាសនោះផងដែរការផ្តល់ជូននេះក៏ពាក់ព័ន្ធនឹង Twitter ផងដែរ ហើយអតិថិជនអាចទិញកាតបញ្ចុះតម្លៃ ៥ដុល្លារអាមេរិក សម្រាប់មិត្តភក្តិដោយបញ្ចូលទាំងពីរ "@ tweetacoffee" និងរបស់មិត្តម្នាក់ក្នុងការសរសេរក្នុង Tweet ។ ក្រុមហ៊ុនស្រាវជ្រាវ Keyhole បានគ្រប់គ្រងមើលលើដំណើរការនៃយុទ្ធនាការនេះ ហើយកាលពីថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០១៣ សារព័ត៌មានមួយបានរាយការណ៍ថា ក្រុមហ៊ុនបានរកឃើញថាមនុស្សចំនួន ២៧.000 នាក់បានចូលរួមហើយការទិញចំនួន ១៨០.០០០ដុល្លារ ត្រូវបានធ្វើឡើងរហូតមកដល់ពេលនេះ។គិតត្រឹមឆ្នាំ ២០១៨ ហាងកាហ្វេ Starbucks ជាប់ចំណាត់ថ្នាក់លេខ ១៣២ នៅលើបញ្ជីក្រុមហ៊ុន Fortune ៥០០ ដែលជាក្រុមហ៊ុនធំបំផុតរបស់សហរដ្ឋអាមេរិកតាមចំណូល[29]។

### ២.១.៣. និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks និងការវិវត្តន៍របស់និមិត្តសញ្ញា[30]

#### ២.១.៣.១. ប្រវត្តិនិមិត្តសញ្ញា

និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ដើមឡើយគឺជារូបភាពនៃ "មច្ឆា" ដែលមានសញ្ញាភ្លោះ។ ទេវកថា របស់ក្រិចមានន័យថាស៊ីរ៉ែនបានល្បួងពួកឈ្មួញឱ្យកប៉ាល់លិចនៅឯនាយឆ្នេរសមុទ្រនៃកោះមួយនៅប៉ាស៊ីហ្វិកខាងត្បូង ហើយជួនកាលគេសំដៅថា Starbuck ដូចជាកោះទាំង៥។ និមិត្តសញ្ញានេះត្រូវបានប្រើប្រាស់ដោយស្ថាបនិកដើមរបស់ក្រុមហ៊ុន Starbucks ដើម្បីទាក់ទាញអ្នកចូលចិត្តកាហ្វេពីគ្រប់ទីកន្លែង។

---

[29] ដកស្រង់ចេញពីគេហទំព័រ https://en.wikipedia.org/wiki/Starbucks#History (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៩)

[30] ដកស្រង់ចេញពីគេហទំព័រ https://www.designhill.com/design-blog/starbucks-logo-overview-of-design-history-and-evolution/ (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៩)

ចាប់តាំងពីការបង្កើតនិមិត្តសញ្ញាដើម Starbucks បានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន។ ការរចនាស្លាកសញ្ញាបានសង្កេតឃើញមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងឆ្នាំ ១៩៨៧ នៅពេលដែលក្រុមហ៊ុននេះត្រូវបានទិញដោយលោក Howard Schultz ។ កាហ្វេ Starbucks តែ និងSpice ក៏ត្រូវបានផ្លាស់ប្តូរទៅជាកាហ្វេ Starbucks ផងដែរ។ Schultz ជាអ្នកដែលទទួលបាននិមិត្តសញ្ញាដ៏ស្មុគស្មាញរបស់ Starbucks ដែលបានធ្វើការកែប្រែឡើងវិញបន្តិចហើយបានបន្ថែមរូបរាងបញ្ចូលគ្នាឲ្យប្រសើរជាងមុន និងការចាប់អារម្មណ៍បន្ថែមទៀតទៅនឹងការរចនានិមិត្តសញ្ញាអាជីវកម្មនេះ។ ថ្វីត្បិតតែមានការផ្លាស់ប្តូរយ៉ាងច្រើន ដែលបានធ្វើឡើងពីការរចនាក៏ដោយ ក៏និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks នៅតែរក្សារូបសញ្ញាដើម 'Mermaid' ដដែល។

និមិត្តសញ្ញាមានវិវត្តន៍ជាលំដាប់ជាយូរមកហើយ ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រជាប្រិយភាពរបស់ Starbucks ។ ជាក់ស្តែងនិមិត្តសញ្ញាបានក្លាយជារូបតំណាងមួយក្នុងចំណោមរូបតំណាងដែលអាចស្គាល់បានច្រើនបំផុតនៅទូទាំងពិភពលោក។

### ២.១.៣.២. ការវិវត្តន៍របស់និមិត្តសញ្ញា

មូលហេតុចម្បងមួយក្នុងចំណោមហេតុផលសំខាន់ៗ ជាច្រើនដែលមនុស្សទទួលបានពីស្លាកសញ្ញារបស់ហាង Starbucks គឺរូបរាង និងការប្រើប្រាស់ឆ្លាតវៃសាមញ្ញនិងស្រស់ស្អាត។ រូបនិមិត្តសញ្ញាបច្ចុប្បន្នមានទ្រង់ទ្រាយរាងជារង្វង់ ហើយបង្ហាញយ៉ាងល្អិតល្អន់នូវរូបភាពនៃ "Siren" នៅក្នុង ពណ៌ចម្រុះ ពណ៌បៃតង និងពណ៌ស។ ខាងក្រោមនេះជាការវិវត្តន៍ និងការរចនានិមិត្តសញ្ញារបស់ហាង Starbucks ប៉ុន្មានឆ្នាំមកនេះ៖

និមិត្តសញ្ញាដំបូងរបស់ Starbucks ដែលបានរចនាឡើងក្នុងឆ្នាំ១៩៧១ មានលក្ខណៈពិសេស "Siren" ជាមួយនឹងកន្ទុយពីររបស់នាង និងអាចមើលផ្ចិតឃើញយ៉ាងច្បាស់។ ការរចនានិមិត្តសញ្ញាដែលមានរាងជារង្វង់ព័ទ្ធជុំវិញរូបតុក្កតា រួមជាមួយនឹងអន្ទាក់ពីរដែលមានលក្ខណៈជាទេវកថានៅក្នុងការលាយពណ៌កាហ្វេ។



1971

**រូបភាពទី២** និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ឆ្នាំ១៩៧១ ដល់ ១៩៨៧

និមិត្តសញ្ញារបស់ហាង Starbucks លើកទីពីរត្រូវបានរចនាឡើងក្នុងឆ្នាំ១៩៨៧។ និមិត្តសញ្ញានេះបង្ហាញពីរូបភាពនៃការបញ្ចេញរូបរាងរបស់មច្ឆា ឬ "Siren" ដែលគ្របដណ្តប់ដោយសក់វែងទម្លាក់។ ទោះបីជាយ៉ាងណាក៏ដោយការរចនានិមិត្តសញ្ញានេះមានកងរបស់មច្ឆាដែលអាចមើលឃើញ។ ឈ្មោះរបស់ក្រុមហ៊ុននេះត្រូវបានបង្ហាញនៅក្នុងផ្លាកសញ្ញាក្នុងរង្វង់ដែលមានផ្កាយពីរនៅសងខាង។ លើសពីនេះទៀតផ្ទៃនៃរង្វង់ពណ៌បៃតងត្រូវបានប្រើ ដើម្បីតំណាងឱ្យកំណើននៃការលូតលាស់ ភាពស្រស់ស្អាត និងភាពរុងរឿងរបស់ហាងកាហ្វេ Starbucks ដែលត្រូវបានទិញដោយលោក Howard Schultz ។

**រូបភាពទី៣** និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ពីឆ្នាំ១៩៨៧ ដល់ ១៩៩២

1987

ការកែប្រែលើកទីបីនៅក្នុងឆ្នាំ១៩៩២ ការរចនានិមិត្តសញ្ញារបស់ហាង Starbucks បានវិវត្តន៍ទៅជាការរចនាស្អាតជាមួយនឹងទិដ្ឋភាពយ៉ាងជិតស្និទ្ធរបស់បច្ចុប្បន្ន។ ផ្កាស្តែមបានបាត់ពីការរចនា ហើយមានតែត្រីកន្ទុយពីរប៉ុណ្ណោះដែលអាចមើលឃើញ។ និមិត្តសញ្ញានេះមានពណ៌នៅកណ្តាលពណ៌បៃតង និងពណ៌សជាមួយ នឹងឈ្មោះក្រុមហ៊ុនដែលត្រូវបានគេដាក់នៅក្នុងផ្លាកសញ្ញានៅខាងក្នុងរង្វង់ដែលមានផ្កាយពីរនៅសងខាង។

**រូបភាពទី៤** និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ឆ្នាំ១៩៩២ ដល់ ២០១១

1992

និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ត្រូវបានរចនាឡើងជាថ្មីនៅក្នុងឆ្នាំ ២០១១ ដើម្បីប្រារព្ធខួបលើកទី៤០ឆ្នាំរបស់ក្រុមហ៊ុន។ ការកែលម្អនិងសម្របសម្រួលឲ្យកាន់តែប្រសើរឡើងក្នុងការរចនានិមិត្តសញ្ញាដែលបានបង្ហាញពីរូបភាពធំ "Siren" ដែលមានពណ៌បៃតង។ ពាក្យសម្គាល់និងផ្កាយបានបាត់ពីការរចនា។ ការរចនាមិនត្រូវបានទទួលដោយអ្នកគាំទ្រ និងអ្នកកោតសរសើរឡើយ ហើយត្រូវប្រឈមនឹងការរិះគន់យ៉ាងខ្លាំងពីអ្នកជំនាញខាងរចនា។

**រូបភាពទី៥** និមិត្តសញ្ញារបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១១ ដល់បច្ចុប្បន្ន

## ២.២. ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន

ចំណូលដែលបានមកពីប្រតិបត្តិការអាជីវកម្មរួមមាន ចំណូលពីការលក់ផលិតផលនៅក្នុងហាង ដែលគ្រប់គ្រងផ្ទាល់ដោយក្នុងក្រុមហ៊ុន និងកម្រៃដែលបានមកពីការចែកចាយ Franchising[31]។

### ២.២.១. ការលក់ផលិតផល

Starbucks លក់ផលិតផលកាហ្វេនិងតែតាមរយៈបណ្តាញផ្សេងៗទៀត និងតាមរយៈក្រុមហ៊ុនវិនិយោគមួយចំនួន។ ក្រុមហ៊ុន Starbucks ក៏ផលិតនិងលក់ភេសជ្ជៈកាហ្វេ Frappuccino®និង Starbucks DoubleShotTM និងការ៉េម។ បណ្តាញមិនលក់រាយទាំងនេះត្រូវបានគេស្គាល់ថាជាប្រតិបត្តិការពិសេស។ គោលដៅរបស់ Starbucks គឺដើម្បីបង្ហាញ Starbucks ជាម៉ាកដែលទទួលស្គាល់ និងគោរពបំផុតនៅក្នុងពិភពលោក។ ដើម្បី សម្រេចបាននូវគោលដៅ ក្រុមហ៊ុនមានផែនការបន្តការពង្រីកប្រតិបត្តិការលក់របស់ខ្លួនយ៉ាងឆាប់រហ័ស ដើម្បីពង្រីកប្រតិបត្តិការពិសេសរបស់ខ្លួន និងជ្រើសរើសយកឱកាសផ្សេងទៀតដើម្បីប្រើប្រាស់ម៉ាកសញ្ញារបស់ Starbucks តាមរយៈការ ណែនាំផលិតផលថ្មី និងការអភិវឌ្ឍន៍បណ្តាញចែកចាយថ្មី។

[31] Starbucks Fiscal 2018 Annual Report, ទំព័រ ៣

គោលដៅលក់រាយរបស់ក្រុមហ៊ុនគឺដើម្បីក្លាយជាអ្នកលក់រាយ និងកាហ្វេឈានមុខគេនៅតាមទីផ្សារគោលដៅនីមួយៗ ដោយលក់កាហ្វេគុណភាពខ្ពស់ និងផលិតផលដែលពាក់ព័ន្ធនិងផ្តល់ជូននូវសេវាកម្មល្អឥតខ្ចោះដោយបង្កើតឱ្យមានភាពស្មោះត្រង់ខ្ពស់ចំពោះអតិថិជន។ យុទ្ធសាស្ត្ររបស់ Starbucks សម្រាប់ពង្រីកអាជីវកម្មលក់រាយរបស់ខ្លួន គឺដើម្បីបង្កើនចំណែកទីផ្សាររបស់ខ្លួននៅក្នុងទីផ្សារដែលមានស្រាប់ជាលើកដំបូងដោយបើកហាងបន្ថែម និងបើកហាងនៅតាមទីផ្សារថ្មីៗដែលមានឱកាសដើម្បីក្លាយជាអ្នកលក់កាហ្វេឈានមុខគេ។

ហាងលក់រាយរបស់ហាងកាហ្វេ Starbucks មានទីតាំងស្ថិតនៅក្នុងផ្លូវដែលមានចរាចរណ៍ខ្ពស់ និងមានភាពមើលឃើញខ្ពស់។ ដោយសារតែក្រុមហ៊ុនអាចផ្លាស់ប្តូរទំហំ និងទ្រង់ទ្រាយក្នុងហាងរបស់ខ្លួនមានទីតាំងស្ថិតនៅក្នុងការកំណត់ផ្សេងៗគ្នា រាប់បញ្ចូលទាំងមជ្ឈមណ្ឌលលក់រាយទីប្រជុំជន និងជាយក្រុងអាគារ ការិយាល័យ និងសាកលវិទ្យាល័យ។ ខណៈពេលដែលក្រុមហ៊ុនមានទីតាំងជ្រើសរើសផ្សារទំនើបនៅក្នុងផ្សារទំនើបជាយក្រុង វាផ្តោតលើហាងដែលមានភាពងាយស្រួលសម្រាប់អ្នកថ្មើរជើងនិងអ្នកបើកបរ។

ហាងលក់កាហ្វេ Starbucks ទាំងអស់ផ្តល់ជូននូវជម្រើសភេសជ្ជៈកាហ្វេជាទៀងទាត់និងគ្មានជាតិកាហ្វេដែលជាជម្រើសយ៉ាងទូលំទូលាយនៃភេសជ្ជៈ Espresso អ៊ីតាលី ភេសជ្ជៈត្រជាក់ត្រជាក់ ភេសជ្ជៈស្រស់ស្រូបត្រជាក់ និងការជ្រើសរើសយកតែ និងកាហ្វេសណ្តែកទាំងមូល។ ហាងលក់កាហ្វេ Starbucks ក៏ផ្តល់ជូននូវជម្រើសនៃនំកុម្មង់ស្រស់ និងអាហារផ្សេងទៀតដូចជាស្ងួ ដាទឹកក្រឡុក គ្រឿងបរិក្ខាកាហ្វេ និងគ្រឿងបន្លាស់ ការជ្រើសរើសឌីសតូចៗ ល្បែងនិងធាតុថ្មីៗ។ ហាង Starbucks នីមួយៗផ្លាស់ប្តូរផលិតផលចម្រុះរបស់វាអាស្រ័យលើទំហំនៃហាងនិងទីតាំងរបស់វា។ ហាងធំៗផ្ទុកនូវកាហ្វេ សណ្តែកទាំងមូលរបស់ក្រុមហ៊ុននៅតាមទំហំ និងប្រភេទផ្សេងៗនៃការវេចខ្ចប់ ក៏ដូចជាគ្រឿងបរិក្ខា កាហ្វេ និងអេឡិចត្រូនិកនិងគ្រឿងបន្លាស់ផ្សេងៗ។ ហាងលក់កាហ្វេ Starbucks តូចៗ និងហាងលក់ទំនិញជាធម្មតាលក់ផលិតផលកាហ្វេពេញលេញ ការជ្រើសរើស កាហ្វេ សណ្តែកទាំងមូល និងគ្រឿងបន្លាស់មួយចំនួន និងចង់ផ្លាកសញ្ញា។

Starbucks ប្តេជ្ញាលក់តែកាហ្វេសណ្តែកនិងភេសជ្ជៈកាហ្វេតែប៉ុណ្ណោះ។ ដើម្បីធានានូវស្តង់ដារកាហ្វេយ៉ាងហ្មត់ចត់ក្រុមហ៊ុន Starbucks គ្រប់គ្រងការទិញកាហ្វេ ការវេចខ្ចប់កាហ្វេនិងចែកចាយកាហ្វេទៅកាន់ហាងលក់រាយរបស់ខ្លួន។ ក្រុមហ៊ុនបានទិញកាហ្វេបៃតងពីតំបន់ផលិត

កាហ្វេនៅជុំវិញពិភពលោកហើយការតុបតែងបែបនេះ ធ្វើឱ្យពួកគេមានស្តង់ដារច្បាស់លាស់សម្រាប់បញ្ចូលនំ និងប្រភពកាហ្វេតែមួយ[32]។

**២.២.២. ការចែកចាយ Franchising**

ហាងកាហ្វេ Starbucks គឺជាម៉ាកដ៏ល្បីល្បាញបំផុតមួយនៅលើពិភពលោកដែលមានទីតាំងរាប់ពាន់កន្លែងនៅ សហរដ្ឋអាមេរិក អាហ្វ្រិក អឺរ៉ុប និងអាស៊ី។ នេះធ្វើឱ្យពួកគេជាជម្រើសដ៏ល្អបំផុតសម្រាប់ការទិញសិទ្ធិធ្វើអាជីវកម្មពីក្រុមហ៊ុន Starbucks។ ក៏ប៉ុន្តែ Starbucks បានបញ្ឈប់ការលក់សិទ្ធធ្វើអាជីវកម្មក្នុងឆ្នាំ ២០១១។ ទោះបីជាយ៉ាងណាក៏ដោយក្រុមហ៊ុន Starbucks នៅតែផ្តល់នូវឱកាសពិសេសសម្រាប់ម្ចាស់អាជីវកម្មណាដែលចង់បើកហាង Starbucks នៅក្នុងហាងរបស់ខ្លួន ដែលបានបង្កើតឡើងរួចហើយ។ នេះគឺជាដំណើរការដ៏លំបាកមួយដែលត្រូវការ ការរៀបចំ និងមូលធនជាច្រើន។ ប្រសិនបើ សហគ្រិនដែលមានចំណាប់អារម្មណ៍ ក្នុងការបើកទីតាំងរបស់ហាងកាហ្វេ Starbucks នៅក្នុងកន្លែងរបស់ពួកគេកំពុងធ្វើអាជីកម្ម ពួកគេប្រហែលជាចង់ដឹងពីថ្លៃសេវាក្នុងទិញយកឈ្មោះប្រើប្រាស់របស់ហាង Starbucks ពិតប្រាកដ។ ចំណុចខាងក្រោមនេះ គឺជាការណែនាំមួយចំនួនសម្រាប់ថ្លៃសេវាទិញយកឈ្មោះប្រើប្រាស់របស់ហាង Starbucks និងព័ត៌មានមានប្រយោជន៍ផ្សេងៗទៀត។

**ក. ពិនិត្យមើលទីតាំង**

ហាងកាហ្វេ Starbucks មានជម្រើសច្រើនណាស់អំពីអាជីវកម្មដែលក្រុមហ៊ុនជ្រើសរើសយកលក់សិទ្ធិយកឈ្មោះប្រើប្រាស់ជាមួយ។ ពួកគេចូលចិត្តអាជីវកម្មដែលបានបង្កើតឡើងដែលស្ថិតនៅទីតាំងល្អបំផុត។តំបន់ដូចជាផ្សារទំនើបនិងកន្លែងសាធារណៈគឺល្អបំផុត។ ហាងកាហ្វេ Starbucks ក៏ស្វែងរកកន្លែងដែលមានចរាចរណ៍ជើងច្រើនផងដែរដូចជា និស្សិត និងកម្មករ ដែលជាអតិថិជនសាមញ្ញបំផុតរបស់ក្រុមហ៊ុន Starbucks ។ ការបង្កើតទីតាំងដែលមានប្រជាសាស្ត្រសំខាន់ៗជាច្រើនរបស់ពួកគេដើរគឺសំខាន់បំផុត។បន្ទាប់ពីការណែនាំ ប្រសិនបើអ្នកមានអារម្មណ៍ថាអាជីវកម្មរបស់អ្នកស្ថិតនៅក្នុងតំបន់បែបនេះ អ្នកអាចបន្តទៅជំហានបន្ទាប់ក្នុងការដាក់ពាក្យស្នើសុំសិទ្ធិរបស់ក្រុមហ៊ុន Starbucks ។

**ខ. តម្លៃសេវា Franchise របស់ Starbuck**

[32] ដកស្រង់ពីគេហទំព័រ https://csimarket.com/stocks/SBUX-Business-Description.html (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩)

ដោយសារតែការជ្រើសរើសរបស់ពួកគេ Starbucks មិនបានធ្វើឱ្យមានតម្លៃពិសេសឬតម្រូវការជាសាធារណៈរបស់ខ្លួនឡើយ។ ពួកគេគ្រាន់តែសម្លឹងមើលកម្មវិធីនិងជ្រើសរើសមួយដែលសមទៅនឹងទម្រង់របស់ពួកគេ។ ចំណុចនេះបង្កការលំបាកដល់អ្នកដាក់ពាក្យមានសក្តានុពលក្នុងការរៀបចំឱ្យបានគ្រប់គ្រាន់។ អ្វីដែលអ្នកដាក់ពាក្យស្នើសុំអាចធ្វើបានគឺការស្រាវជ្រាវពីដៃគូជំនួញផ្សេងទៀតរបស់ពួកគេ។ឧទាហរណ៍ កាហ្វេល្អបំផុតនៅទីក្រុងស៊ីថលគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ក្រុមហ៊ុន Starbucks ។ ពួកគេមានលក្ខណៈស្រដៀងគ្នាទៅនឹងសិទ្ធិទិញយកឈ្មោះរបស់កាហ្វេ។ ដូច្នេះអ្នកដាក់ពាក្យប្រើវាដើម្បីប៉ាន់ប្រមាណតម្លៃរបស់ខ្លួន។ អាស្រ័យលើទំហំហាងនិងទីតាំងរបស់ខ្លួនការចំណាយអាចមានចាប់ពី ២៦៥.០០០ ដុល្លារដល់ ៩៤០.០០០ ដុល្លារ។

### គ. ការដាក់ពាក្យសំរាប់ហាងដែលមានអាជ្ញាប័ណ្ណ

ព័ត៌មានទាំងអស់ដែលបេក្ខជនត្រូវការដើម្បីដាក់ពាក្យសុំទិញសិទ្ធយកឈ្មោះប្រើប្រាស់ គឺនៅលើគេហទំព័ររបស់ហាងកាហ្វេ Starbucks ។ ជម្រើសដែលអ្នកស្នើសុំកំពុងស្វែងរកគួរតែស្ថិតក្នុង "ការដាក់ពាក្យសម្រាប់ហាងមានអាជ្ញាប័ណ្ណ ហើយជ្រើសរើសការពណ៌នាដែលសមទៅនឹងសកម្មភាពអាជីវកម្មរបស់អ្នកស្នើសុំ។ សំណុំបែបបទកម្មវិធីនឹងត្រូវបានផ្ទុក នេះគឺជាកន្លែងដែលអ្នកស្នើសុំត្រូវមានព័ត៌មានហិរញ្ញវត្ថុសំខាន់របស់ខ្លួន ។ ព័ត៌មានដែលត្រូវការចាំបាច់រួមមានទីតាំងអាជីវកម្ម ទ្រព្យសកម្មសរុប បំណុល និងទ្រព្យសម្បត្តិសុទ្ធ។ អ្នកស្នើសុំក៏ត្រូវការ ការប៉ាន់ប្រមាណនូវមូលនិធិដែលមិនមែនជាបំណុលដែលអ្នកអាចរកបានសម្រាប់ការវិនិយោគ។ Starbucks រំពឹងថាហាងដែលមានអាជ្ញាប័ណ្ណនឹងមានចំនួនទឹកប្រាក់ជាក់លាក់ដែលអាចប្រើការបាន ដោយប៉ាន់ប្រមាណថាអ្នកស្នើសុំនឹងត្រូវការយ៉ាងហោចណាស់ ៧០០,០០០ ដុល្លារក្នុងទ្រព្យសម្បត្តិ។

### ឃ. ការសរសេរមតិ

មានផ្នែកយោបល់តិចតួចនៅចុងបញ្ចប់នៃសំណុំបែបបទ "ប័ណ្ណទទួលបានអាជ្ញាប័ណ្ណ" ។អ្នកដាក់ពាក្យស្នើសុំអាចប្រើឱកាសនេះ ដើម្បីបន្ថែមការមតិផ្ទាល់ខ្លួន។ ពន្យល់ពីមូលហេតុដែលអ្នកស្នើសុំគិតថាខ្លួននឹងក្លាយជាបេក្ខជនដ៏ល្អ សម្រាប់ការផ្តល់សិទ្ធិក្នុងការយកឈ្មោះប្រើប្រាស់ (franchise) ។ រួមទាំងព័ត៌មានណាមួយទាក់ទងនឹងផែនការរបស់ខ្លួនសម្រាប់ហាង។ អ្វីដែលនៅសល់ដើម្បីធ្វើបន្ទាប់ពីនេះគឺប្រគល់ពាក្យស្នើសុំ។ ប្រសិនបើអ្នកទទួលបានការឆ្លើយតបនៅប៉ុន្មាន

សប្តាហ៍ខាងមុខអ្នកនឹងត្រូវបានដាក់ពាក្យសុំដោយជោគជ័យសម្រាប់សិទ្ធិក្នុងការលក់របស់ហាង Starbucks [33]។

## ២.៣. ផលិតផល

### ២.៣.១. ផលិតផលរបស់ Starbucks[34]

Starbucks លក់កាហ្វេ តែនិងភេសជ្ជៈផ្សេងៗនិងអាហារជាច្រើនប្រភេទដែលរួមមានទាំងអាហារសម្រន់ផងដែរ។

- កាហ្វេ : More than 30 blends and single-origin premium coffees។
- ភេសជ្ជៈដែលផលិតដោយដៃ(Handcradted Beverages) : Fresh-brewed coffee, hot and iced espresso beverages, Frannuccino® coffee and non-coffee blended beverages, smoothies and Tazo® teas ។
- ទំនិញ (Merchandise) : Coffee and Tea brewing equipment, mugs and accessories, pachaged goods, music, books and gifts.
- អាហារស្រស់ (Fresh Food) : Baked pastries, sandwiches, salads, oatmeal, yogurt parfaits and fruit cups។

### ២.៣.២. ផលិតផលសម្រេចរបស់ Starbucks

- កាហ្វេ និងតែ (Coffee and Tea) ៖ Whole bean and ground coffee (Starbucks and Seattle's Best Coffee brands.), Starbucks VIA® Ready Brew, Starbucks®K-Cup® portion packs, Tazo® tea filterbags and tea latte concentrates។
- ភេសជ្ជៈសម្រេច (Ready-to-Drink)៖ Starbucks® bottled Frappuccino® coffee drinks, Starbucks Discoveries® chilled cup coffees, Starbucks Doubleshot® Energy+Coffee drinks; Seattle's Best Coffee® Iced Lattes, Starbucks Refrershers™ beverages, Tazo® bottled iced and juiced teas។

[33] ដកស្រង់ពីគេហទំព័រ https://businessfirstfamily.com/starbucks-franchise-fee-information-for-entrepreneurs (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩)

[34] ដកស្រង់ពីគេហទំព័រ https://sites.google.com/a/email.vccs.edu/starbucks-corporation/company-profile (ចូលទស្សនាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩)

- ការ៉េម Starbucks (Starbucks® Ice Cream): Super-premium coffee and coffee-free flavors។

### ២.៣.៣. ការផ្គត់ផ្គង់ផលិតផលរបស់ Starbucks

Starbucks បានប្តេជ្ញាចិត្តថាលក់កាហ្វេគ្រាប់និងភេសជ្ជៈកាហ្វេ ដើម្បីធានានូវការអនុលោមទៅតាមភាពម៉ត់ចត់នៃស្តង់ដារកាហ្វេក្រុមហ៊ុន ក្រុមហ៊ុនត្រួតពិនិត្យទៅលើការទិញកាហ្វេ ការគ្រងការវេចខ្ចប់ និងការបែងចែកកាហ្វេទូទាំងពិភពលោកដែលប្រើនៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុន ។ Starbucks ទិញគ្រាប់កាហ្វេបៃតងពីតំបន់ផលិតកាហ្វេច្រើនកន្លែងនៅជុំវិញពិភពលោកហើយដុតវាឱ្យទៅស្តង់ដារពិតប្រាកដរបស់ក្រុមហ៊ុន សម្រាប់ក្លិនជាច្រើន និងកាហ្វេដើមតែមួយ។

តម្លៃកាហ្វេអាចនឹងប្រែប្រួលខ្លាំង ទោះបីជាការធ្វើពាណិជ្ជកម្មកាហ្វេភាគច្រើននៅក្នុងទីផ្សារទំនិញ កម្ពស់ខ្ពស់កាហ្វេ Arabica ដែលមានគុណភាព ហើយបានស្វែងរកឃើញដោយក្រុមហ៊ុន Starbucks មាននិន្នាការដើម្បីធ្វើពាណិជ្ជកម្មនៅលើមូលដ្ឋាននៃចរចារមួយ នៅកាហ្វេខ្ពស់ជាងកាហ្វេ "C" តម្លៃទំនិញ។ ទាំងបុព្វលាភនិងតម្លៃទំនិញអាស្រ័យលើការផ្គត់ផ្គង់និងតម្រូវការនៅពេលដែលទិញ។ ការផ្គត់ផ្គង់ និងតម្លៃអាចរងផលប៉ះពាល់ដោយកត្តាជាច្រើនដល់ការផលិតក្នុងប្រទេសរួមមានអាកាសធាតុ គ្រោះមហន្តរាយធម្មជាតិ និងដំណាំមានជម្ងឺ ការកើនឡើងជាទូទៅនូវការនាំចូលទិន្នផលកសិកម្ម និងតម្លៃនៃការផលិត កម្រិតសារពើភ័ណ្ឌនិងស្ថានភាពនយោបាយនិងលក្ខខ័ណ្ឌសេដ្ឋកិច្ច។ តម្លៃក៏មានផលប៉ះពាល់ផងដែរដោយសកម្មភាពជួញដូរនៅទីផ្សារកាហ្វេ Arabica រួមទាំងមូលនិធិបណ្តាក់ទុន និងមូលនិធិសន្ទស្សន៍ទំនិញ។

Starbucks ប្តេជ្ញាទិញកាហ្វេដោយប្រើប្រាស់តម្លៃទិញទំនិញថេរ និងតម្លៃថេរ អាស្រ័យលើលក្ខខណ្ឌទីផ្សារដើម្បីធានាសុវត្ថិភាពការផ្គត់ផ្គង់នៃគុណភាពកាហ្វេបៃតង។ កិច្ចសន្យាតម្លៃថេរដែលត្រូវបានកំណត់ គឺការប្តេជ្ញាចិត្តក្នុងការទិញទៅលើគុណភាព បរិមាណ រយៈពេលនៃការដឹកជញ្ជូន និងលក្ខខណ្ឌផ្សេងៗដែលបានចរចារត្រូវបានព្រមព្រៀងគ្នាប៉ុន្តែកាលបរិច្ឆេទ និងតម្លៃដែលកាហ្វេមូលដ្ឋាន "C" សមាសភាគតម្លៃទំនិញនឹងត្រូវបានកែប្រែមិនទាន់ត្រូវបានបង្កើតឡើង។ ការប្តេជ្ញាចិត្តទិញកាហ្វេបៃតងសរុបគិតត្រឹមថ្ងៃទី៣០ ខែកញ្ញាឆ្នាំ ២០១៨ មានចំនួន ១,១ ពាន់លានដុល្លារ។មានចំនួន ៩៩៦ លានដុល្លារអាមេរិកក្រោមកិច្ចសន្យាតម្លៃថេរ និងការប៉ាន់ប្រមាណចំនួន ១៦៦ លានដុល្លារក្នុងកិច្ចសន្យាតម្លៃថេរ។ ភាគច្រើនកិច្ចសន្យាតម្លៃថេរចាប់ពីថ្ងៃទី ៣០ ខែកញ្ញាឆ្នាំ ២០១៨ ទៅតាមជំរើសរបស់ក្រុមហ៊ុនដើម្បីកែសម្រួលតម្លៃទំនិញកាហ្វេ "C" មូលដ្ឋានសមា សភាគ

។ ការប្តេជ្ញាចិត្តទិញសរុបរួមជាមួយនឹងសារពើភ័ណ្ឌដែលមានស្រាប់ត្រូវបានគេរំពឹងថា នឹងផ្តល់ការផ្គត់ផ្គង់ឱ្យកាហ្វេបៃតងឲ្យបានគ្រប់គ្រាន់តាមរយៈសារពើពន្ធនៅឆ្នាំ២០១៩ ។

Starbucks ពឹងផ្អែកលើទំនាក់ទំនងរបស់ខ្លួនជាមួយអ្នកផលិតកាហ្វេ ក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេសនិងអ្នកនាំចេញសម្រាប់ការផ្គត់ផ្គង់ពណ៌បៃតងរបស់ក្រុមហ៊ុន។ Starbuck ជឿជាក់ថាផ្អែកលើទំនាក់ទំនងដែលបានបង្កើតឡើងជាមួយអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុន ហានិភ័យនៃការមិនដឹកជញ្ជូន ឱ្យលើការទិញគឺស្ទើរតែមិនកើតមានឡើង។

ដើម្បីជួយធានានូវការផ្គត់ផ្គង់កាហ្វេបៃតងគុណភាពខ្ពស់នាពេលអនាគត និងដើម្បីពង្រឹងតួនាទីដឹកនាំរបស់ក្រុមហ៊ុននៅក្នុងឧស្សាហកម្មកាហ្វេ Starbucks ប្រតិបត្តិការមជ្ឈមណ្ឌលផ្តល់ជំនួយដល់កសិករប្រាំបួន។ មជ្ឈមណ្ឌលគាំទ្រកសិករមានបុគ្គលិកកសិកម្ម និងអ្នកជំនាញដែលធ្វើការជាមួយសហគមន៍កសិកម្មកាហ្វេ ដើម្បីលើកកម្ពស់ការអនុវត្តន៍ល្អបំផុតនៅក្នុងការផលិតកាហ្វេ ដែលត្រូវបានបង្កើតឡើង និងដើម្បីកែលម្អទាំងគុណភាពកាហ្វេ ទិន្នផលនិងការគាំទ្រផ្នែកក្សេត្រសាស្ត្រ ដើម្បីដោះស្រាយបញ្ហាអាកាសធាតុ និងផលប៉ះពាល់ផ្សេងៗទៀត។

បន្ថែមពីនេះទៅទៀតក្រុមហ៊ុន Starbuck ក៏ទិញបរិមាណផលិតផលទឹកដោះគោ ជាពិសេសទឹកដោះគោរាវ ដើម្បីទ្រទ្រង់តម្រូវការប្រតិបត្តិការលក់ក្នុងហាង។ Starbuck ជឿជាក់ថាផ្អែកលើទំនាក់ទំនងដែលបានបង្កើតឡើងជាមួយអ្នកផ្គត់ផ្គង់ទឹកដោះគោរបស់ក្រុមហ៊ុន ដែលគិតថាហានិភ័យនៃការមិនដឹកជញ្ជូន ទឹកដោះរាវក្នុងបរិមាណគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការលក់ក្នុងហាងគឺស្ទើរតែមិនអាចនឹងកើតមានឡើង។

ផលិតផលជាច្រើនផ្សេងៗទៀតដូចជាកាហ្វេគ្រាប់ទាំងមូល និងភេសជ្ជៈកាហ្វេដែលបានលក់នៅក្នុងហាង Starbucks® រួមមានតែ និងភេសជ្ជៈសម្រេច ដែលភេសជ្ជៈត្រូវបានទិញពីអ្នកផ្គត់ផ្គង់ជំនាញជាច្រើនដែលជាធម្មតាស្ថិតនៅក្រោមកិច្ចសន្យាផ្គត់ផ្គង់រយៈពេលវែង។ ផលិតផលអាហារដូចជា នំខេន(Pastries) សាំងវិច (sandwiches) និងអាហារថ្ងៃត្រង់ អាហារពេលព្រឹក ត្រូវបានទិញពីក្នុងប្រទេស តំបន់និងធនធាននៅក្នុងតំបន់។ ក្រុមហ៊ុនទិញផលិតផលក្រដាស និងផ្លាស្ទិចធំៗ ដូចជាពែង និងគ្រឿងតុបតែងផ្សេងៗពីក្រុមហ៊ុនជាច្រើនដើម្បីជួយផ្គត់ផ្គង់ដល់តម្រូវការរបស់ហាងលក់រាយរបស់ក្រុមហ៊ុន ក៏ដូចជាប្រតិបត្តិការផលិតនិងចែកចាយរបស់ក្រុមហ៊ុន[35]។

[35] Starbucks Fiscal 2018 Annual Report, ទំព័រ ១០

# ជំពូកទី៣

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks Corporation

## ៣.១. របាយការណ៍ហិរញ្ញវត្ថុ

### ៣.១.១. របាយការណ៍លទ្ធផល[36]

| Period Ending: | Trend | 9/30/2018 | 10/1/2017 |
|---|---|---|---|
| Total Revenue | | $24,719,500 | $22,386,800 |
| Cost of Revenue | | $10,174,500 | $9,034,300 |
| **Gross Profit** | | **$14,545,000** | **$13,352,500** |
| **Operating Expenses** | | | |
| Research and Development | | $0 | $0 |
| Sales, General and Admin. | | $9,491,500 | $8,444,300 |
| Non-Recurring Items | | $224,400 | $153,500 |
| Other Operating Items | | $1,247,000 | $1,011,400 |
| Operating Income | | **$3,883,300** | **$4,134,700** |
| Add'l income/expense items | | $2,067,000 | $275,300 |
| Earnings Before Interest and Tax | | $5,950,300 | $4,410,000 |
| Interest Expense | | $170,300 | $92,500 |
| Earnings Before Tax | | $5,780,000 | $4,317,500 |
| Income Tax | | $1,262,000 | $1,432,600 |
| Minority Interest | | $300 | ($200) |
| Equity Earnings/Loss Unconsolidated Subsidiary | | $301,200 | $391,400 |
| Net Income-Cont. Operations | | $4,819,500 | $3,276,100 |
| Net Income | | **$4,518,300** | **$2,884,700** |
| Net Income Applicable to Common Shareholders | | **$4,518,300** | **$2,884,700** |

36 https://www.nasdaq.com/symbol/sbux/financials?query=income-statement(ចូលទស្សនាថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០១៩)

❖ **សមាសធាតុនៅក្នុងរបាយការណ៍លទ្ធផល**

- ចំណូលសរុប(Total Revenue) គឺជាចំណូលសរុបដែលបានពីការលក់ទំនិញ សេវាកម្មនិង ចំណូលផ្សេងៗទៀតរបស់ក្រុមហ៊ុនដូចជា កាហ្វេ តែ នំ ម្ហូបអាហារ និង ចំណូលពីផ្តល់អជ្ញាប័ណ្ណនៃសិទ្ធិក្នុងការចែកចាយផលិតផលបន្ត (Franchise) ។
- ថ្លៃដើមនៃចំណូល (Cost of Revenue) ឬហៅថាថ្លៃដើមនៃការលក់ (Cost of goods sold) គឺជាថ្លៃដើមផ្ទាល់សរុបក្នុងការផលិតកាហ្វេ តែ នំ និងម្ហូបអាហារ។
- ប្រាក់ចំណេញដុល (Gross Profit) គឺប្រាក់ដែលនៅសល់បន្ទាប់ពីចំណូលសរុបត្រូវបានដកជាមួយថ្លៃដើមសរុប ហើយប្រាក់ចំណេញដុលនេះមិនទាន់បានដកជាមួយចំណាយប្រតិបត្តិការផ្សេងៗនៅឡើយ។
- ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍ (Research &Development) គឺជាចំណាយលើការបង្កើតច្នៃប្រឌិតថ្មីការណែនាំនិងការកែលម្អនៃផលិតផលនិងដំណើរការជាដើម។
- ចំណាយថ្លៃលក់ទូទៅនិងថ្លៃរដ្ឋបាល (Sales, General and Admin) គឺជាចំណាយដែលមានដូចជាការដឹកជញ្ជូន ការផ្សព្វផ្សាយអំពីការលក់ផលិតផល ប្រាក់ខែបុគ្គលិក ថ្លៃសេវាសវនកម្ម ការជួលអគារឬហាង ថ្លៃធានារ៉ាប់រង ចំណាយលើការប្រើប្រាស់ទឹកភ្លើង ថ្លៃជួសជុលថែទាំទៅលើទ្រព្យសកម្មផ្សេងៗ សេវាថ្លៃសេវាទូរស័ព្ទ ថ្លៃចំណាយលើការប្រជុំរបស់ម្ចាស់ភាគហ៊ុន និង ថ្លៃ ចំណាយផ្សេងៗដែលប្រើនៅក្នុងការិយាល័យប្រចាំថ្ងៃ។
- ចំណាយដែលមិនមានជាប្រចាំ (Non-Recurring Items) គឺជាការចំណេញឬខាតរបស់ក្រុមហ៊ុនដែលរំពឹងគិតថាវាមិនកើតឡើងទៀងទាត់នោះទេ។ វាមិនមែនជាផ្នែកមួយដែលទាក់ទងនៃដំណើរការអាជីវកម្មប្រចាំថ្ងៃរបស់ក្រុមហ៊ុននោះទេ តែវាទាក់ទងនឹងចំណាយដែលមានដូចជាសេវាការពារវិវាទ ការលុបចោលបំណុលអាក្រក់ និងទ្រព្យសកម្មដែលមិនមានតម្លៃ និងការជួសជុលដែលបានបំផ្លាញដោយសារគ្រោះធម្មជាតិ។
- ការចំណាយប្រតិបត្តការផ្សេងៗ (Other operating Items) គឺជាចំណាយទូទៅមិនអាស្រ័យលើបរិមាណនៃការលក់ឬបរិមាណផលិតផលរបស់ក្រុមហ៊ុន។ ចំណាយនេះរួមបញ្ចូលការចំណាយទីផ្សារ ការជួល និង ឧបករណ៍ប្រើប្រាស់ ការចំណាយផ្សេងៗនៅការិយាល័យ និងចំណាយថេរផ្សេងៗទៀត។

- ប្រាក់ចំណេញប្រតិបត្តិការ (Operating Income) គឺជាប្រាក់ចំណេញដែលនៅសល់បន្ទាប់ពីប្រាក់ចំណូលនៃការលក់សរុប ដកជាមួយនឹងថ្លៃចំណាយប្រតិបត្តិការទូទៅរបស់ក្រុមហ៊ុននិងថ្លៃដើមនៃការលក់របស់ក្រុមហ៊ុន។
- ប្រាក់ចំណូលមុនពេលបង់ការប្រាក់និងពន្ធ (Earnings Before Interest and Tax)គឺជាប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុនមុនពេលចំណាយលើបង់ការប្រាក់ និងការបង់ពន្ធលើប្រាក់។
- ចំណាយការប្រាក់ (Interest Expense) គឺការចំណាយការប្រាក់ទៅលើកម្ចីមួយចំនួនដូចជាប័ណ្ណបំណុល និងឥណទានរបស់ក្រុមហ៊ុនជាដើម។
- ពន្ធលើប្រាក់ចំណូល (Income Tax) គឺជាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុនអាជីវកម្មត្រូវតែកាត់ចំណែកណាមួយនៃប្រាក់ចំណេញរបស់ខ្លួនបង់ពន្ធជូនរដ្ឋដោយយោងទៅតាមអាត្រាពន្ធ ដែលបានកំណត់រួចហើយ។
- ប្រាក់ចំណូលមុនពេលបង់ពន្ធ (Earnings before Tax) គឺជាប្រាក់ចំណូលរបស់ក្រុមហ៊ុនមុនពេលការចំណាយលើការបង់ពន្ធជូនរដ្ឋ។
- ផលប្រយោជន៍អប្បរមា (Minority Interest) គឺជាការប្រាក់នៃភាពជាម្ចាស់ មួយផ្នែកនៃក្រុមហ៊ុនមួយដែលខ្លួនបានវិនិយោគមូលធនចូលដែលអាចមិនលើសពី ៥0% នៃមូលធនសរុបរបស់ក្រុមហ៊ុននោះទេ។
- ចំណូលមូលធនឬខាតរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ (Equity Earning/Loss Unconsolidated Subsidiary) គឺជាប្រាក់ចំណេញឬខាតពីការវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុនទៅលើក្រុមហ៊ុន ដទៃទៀត។
- ចំណេញប្រតិបត្តិការសុទ្ធ (Net Income-Cont. Operations) គឺប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបានពីសកម្មភាពប្រតិបត្តិការអាជីវកម្មរបស់ខ្លួនបន្ទាប់ពីបង់ពន្ធ លើប្រាក់ចំណូលរួចរាល់ហើយ។
- ប្រាក់ចំណេញសុទ្ធ (Net Income) គឺជាប្រាក់ចំណេញសុទ្ធដែលត្រូវបានដែលត្រូវបានគណនាដោយយកការលក់សរុបដក ជាមួយនឹងចំណាយប្រតិបត្តិការទូទៅ ចំណាយរដ្ឋបាល ចំណាយការប្រាក់ ចំណាយការបង់ពន្ធ និងការចំណាយផ្សេងៗទៀតរួចរាល់ហើយ។
- ប្រាក់ចំណេញសុទ្ធសម្រាប់អនុវត្តសម្រាប់ម្ចាស់ភាគហ៊ុនធម្មតា (Net Income Aplicable to Common Shareholders) គឺប្រាក់ចំណេញជារបស់ភាគទុននិក ដែលក្រុមហ៊ុនបានរាយការណ៍

នៅក្នុងកំឡុងពេលកំណត់មួយ។ ប្រាក់ចំណេញនេះគឺសម្រាប់យកទៅប្រើដើម្បីគណនាប្រាក់ចំណេញមូលដ្ឋាន និងការរកប្រាក់ចំណូលបានក្នុងមួយភាគហ៊ុន។

### ៣.១.២. តារាងតុល្យការ[37]

| Period Ending: | Trend | 9/30/2018 | 10/1/2017 |
|---|---|---|---|
| **Current Assets** | | | |
| Cash and Cash Equivalents | | $8,756,300 | $2,462,300 |
| Short-Term Investments | | $181,500 | $228,600 |
| Net Receivables | | $693,100 | $870,400 |
| Inventory | | $1,400,500 | $1,364,000 |
| Other Current Assets | | $1,462,800 | $358,100 |
| Total Current Assets | | **$12,494,200** | **$5,283,400** |
| **Long-Term Assets** | | | |
| Long-Term Investments | | $602,400 | $1,023,900 |
| Fixed Assets | | $5,929,100 | $4,919,500 |
| Goodwill | | $3,541,600 | $1,539,200 |
| Intangible Assets | | $1,042,200 | $441,400 |
| Other Assets | | $412,200 | $362,800 |
| Deferred Asset Charges | | $134,700 | $795,400 |
| Total Assets | | **$24,156,400** | **$14,365,600** |

[37] https://www.nasdaq.com/symbol/sbux/financials?query=balance-sheet(ចូលទស្សនាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩)

| | | |
|---|---|---|
| **Current Liabilities** | | |
| Accounts Payable | $3,691,400 | $2,932,200 |
| Short-Term Debt / Current Portion of Long-Term Debt | $349,900 | $0 |
| Other Current Liabilities | $1,642,900 | $1,288,500 |
| Total Current Liabilities | **$5,684,200** | **$4,220,700** |
| Long-Term Debt | $9,090,200 | $3,932,600 |
| Other Liabilities | $1,430,500 | $750,900 |
| Deferred Liability Charges | $6,775,700 | $4,400 |
| Misc. Stocks | $0 | $0 |
| Minority Interest | $6,300 | $6,900 |
| Total Liabilities | **$22,986,900** | **$8,915,500** |
| **Stock Holders Equity** | | |
| Common Stocks | $1,300 | $1,400 |
| Capital Surplus | $41,100 | $41,100 |
| Retained Earnings | $1,457,400 | $5,563,200 |
| Treasury Stock | $0 | $0 |
| Other Equity | ($330,300) | ($155,600) |
| Total Equity | **$1,169,500** | **$5,450,100** |
| Total Liabilities & Equity | **$24,156,400** | **$14,365,600** |

❖ សមាសធាតុនៅក្នុងតារាងតុល្យការ

- សាច់ប្រាក់ និង សមាសធាតុសមមូលនិងសាច់ប្រាក់ (Cash and Cash Equivalents) គឺជាសមាសធាតុដែលមានសន្ទីយភាពខ្ពស់ជាងគេបំផុតក្នុងចំណោមសមាសធាតុផ្សេងៗទៀតនៃទ្រព្យសកម្មទាំងអស់។ វារួមមានដូចជា សាច់ប្រាក់ សាច់ប្រាក់ក្នុងធនាគារ មូលប្បទានប័ត្រ និងសមាសធាតុដែលងាយបម្លែងទៅជាសាច់ប្រាក់ផ្សេងៗទៀត។
- ការវិនិយោគរយៈពេលខ្លី (Short term Investment) គឺជាការវិនិយោគទាំងឡាយណា ដែលមានរយៈពេលមិនលើសពី ១ ឆ្នាំ ឬជាឧបករណ៍ហិរញ្ញវត្ថុដែលក្រុមហ៊ុនបានធ្វើការវិនិយោគលើទីផ្សាររូបិយវត្ថុដែលមានដូចជា ប័ណ្ណរតនាគារជាតិ ផលបត្រពាណិជ្ជកម្ម ស្វីកាធនាគារ (Banker's Acceptance) លិខិតបញ្ជាក់ប្រាក់បញ្ញើ (Certificate of Deposit) និង កិច្ចសន្យាទិញត្រឡប់មកវិញ។
- ឥណទេយ្យសុទ្ធ (Net Receivable) គឺជាគណនីមួយដែលបង្ហាញពីសមតុល្យនៃប្រាក់ដែលអតិថិជនពុំទាន់បានទូទាត់តាមរយៈការលក់ ផលិតផល សេវាកម្ម អញ្ញាប័ណ្ណ និងថ្លៃផ្សេងៗទៅកាន់អតិថិជន ហើយគណនីនេះក៏បានដកចេញនូវរាល់ប្រាក់សម្រាប់បំណុល ដែលអតិថិជនពុំបានសងផងដែរ (Allowance for Doubtful Accounts) ។
- សន្និធិ (Inventory) សំដៅលើរូបធាតុដើមប្រើក្នុងការផលិត (Raw Material) ទំនិញដែលកំពុងដំណើរការក្នុងការធ្វើ (WIP) និងទំនិញសម្រេចរួច (Finished goods)។
- ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗទៀត (Other Current Assets) ជាសមាសធាតុដែល មានដូចជា ប្រាក់បង់មុនលើថ្លៃជួល (Prepaid Rent) ប្រាក់បង់មុនលើថ្លៃធានារ៉ាប់រង (Prepaid Insurance) ការប្រាក់ដែលគេពុំទាន់សង (Interest Receivable) ឥណទេយ្យបុគ្គលិក (Other Receivable Staff) ឥណទេយ្យផ្សេងៗទៀត (Miscellaneous Receivable) និង ពន្ធដែលបានបង់ទុកមុន (Prepayment Tax) ។
- ការវិនិយោគរយៈពេលវែង (Long-Term Investment) ជាគណនីមួយដែលបង្ហាញពីការវិនិយោគធំៗរបស់ក្រុមហ៊ុនដែលមានរយៈពេលលើសពី មួយ ឆ្នាំ មានដូចជា ភាគហ៊ុន សញ្ញាប័ណ្ណ និង អចលទ្រព្យផ្សេងៗទៀត។
- ទ្រព្យសកម្មរយៈពេលវែង (Fixed Asset) សំដៅលើទ្រព្យដែលមានអាយុកាលលើសពី ១ ឆ្នាំ និងមានភាពរូបី ដែលមានដូចជា អគារ ដី គ្រឿងបរិក្ខារ សម្ភារៈការិយាល័យ គ្រឿងសង្ហារឹម យានយន្ត ជាដើម។
- Goodwill គឺជាគណនីមួយដែលបង្ហាញនៅពេលដែលក្រុមហ៊ុនទិញយកក្រុមហ៊ុនមួយទៀតក្នុងតម្លៃមួយដែលលើសពីតម្លៃទីផ្សារនៃទ្រព្យសកម្មសរុប និងបំណុលសរុប។ តម្លៃនៃ Goodwill បង្ហាញពីអត្ថប្រយោជន៍មួយចំនួនដូចជា កេរ្តិ៍ឈ្មោះផលិតផល អតិថិជនសំខាន់ៗ ទំនាក់ទំនង

ល្អជាមួយអតិថិជន និងបុគ្គលិក និងអត្ថប្រយោជន៍សំខាន់ៗដទៃទៀត ដែលបានបន្សល់ទុកដោយក្រុមហ៊ុនដែលត្រូវបានទិញយកនោះ។

- ទ្រព្យសកម្មអរូបី (Intangible Asset) សំដៅទៅលើទ្រព្យសកម្មរយៈពេលវែង ប៉ុន្តែមានភាពអរូបី ដែលមានដូចជា ច្បាប់រក្សាសិទ្ធិ (Copyright) សិទ្ធិអនុញ្ញាតអោយលក់ដូរទំនិញ (Franchise) កេរ្តិ៍ឈ្មោះផលិតផល (Brand Name) និក្ខិត្តសញ្ញា (Trademark) និង កម្មវិធីកុំព្យូទ័រ (Computer Software) ជាដើម។
- ទ្រព្យសកម្មដទៃៗទៀត (Other Assets) គឺជាទ្រព្យសកម្មរយៈពេលវែងមួយចំនួនដែលមិនអាចចាត់ចូល Current assets Fixed assets ឬ Intangible assets។ ក្រុមទ្រព្យសកម្មទាំងនោះមានដូចជា ប្រាក់បង់មុនទៅអោយបុគ្គលិក (Staff Advance) ប្រាក់សោធនិវត្តរបង់ទុកមុន (Advanced Pension Fund) ប្រាក់កក់សម្រាប់មូលបត្ររយៈខ្លី (Sort-term Security Deposit) ប្រាក់កក់សម្រាប់មូលបត្ររយៈវែង (Long-term Security Deposit) និង ទ្រព្យសកម្មពន្ធពន្យា (Deferred Tax Assets) ។
- ទ្រព្យនៃប្រាក់ដែលបានទូទាត់មុន (Deferred Charge Asset) ជាគណនីមួយដែលត្រូវបានកត់ត្រាឡើង នៅពេលដែលចំណាយណាមួយពុំបានកើតឡើងជាក់ស្តែងក្នុងកំឡុងពេលនោះទេ ប៉ុន្តែសាច់ប្រាក់ត្រូវបានចេញ។ ឧទាហរណ៍៖ ដើម្បីទទួលបានការបញ្ចុះតម្លៃ ក្រុមហ៊ុនមួយត្រូវ ទូទាត់លើទំនិញមួយនោះជាមុនដោយមិនទាន់ទទួលបានទំនិញជាក់ស្តែងនៅឡើយ។ ដូច្នេះ ទឹក ប្រាក់ដែលបានទូទាត់នោះត្រូវបានកត់ត្រាចូល Deferred Asset Charge រហូតដល់ការចំណាយជាក់ស្តែងកើតឡើង។
- គណនីត្រូវសង (Accounts Payable) ជាគណនីមួយដែលបង្ហាញពីកាតព្វកិច្ចហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងការទូទាត់បំណុលរយៈពេលខ្លីទៅកាន់អ្នកផ្គត់ផ្គង់។
- បំណុលរយៈពេលវែងដែលត្រូវសង (Current Portion of Long-term Debt) សំដៅទៅលើទឹកប្រាក់មួយផ្នែកនៃបំណុលរយៈពេលវែង ដែលក្រុមហ៊ុនត្រូវទូទាត់ក្នុងពេលឆាប់ៗ។ ឧទាហរណ៍ ៖ បើក្រុមហ៊ុនមានបំណុលរយៈពេលវែងចំនួន ១០០.០០០ ដុល្លារ ហើយ ២០.០០០ ដុល្លារ នៃ ១០០.០០០ ដុល្លារនោះ ត្រូវសងក្នុងកំឡុងពេលណាមួយឆាប់ៗនោះ ២០.០០០ ដុល្លារ នោះត្រូវបានកត់ត្រាចូលគណនីនេះ។
- បំណុលរយៈពេលខ្លីផ្សេងៗទៀត (Other Current Liabilities) មានដូចជា ពន្ធលើប្រាក់ចំណេញដែលត្រូវបង់ (Income taxes payable) ការប្រាក់ដែលត្រូវទូទាត់ (Interest payable) ប្រាក់ជំពាក់ បង្គរទុក (Accrual payable) ប្រាក់ខែបុគ្គលិកដែលត្រូវបង់ (Salary payable) ជាដើម។

- បំណុលរយៈវែង (Long-term Debt) ជាគណនីមួយដែលបង្ហាញពីបំណុលទាំងឡាយណាដែលមានរយៈពេលលើសពីមួយឆ្នាំ ដែលមានដូចជា ហិរញ្ញប្បទានពីផ្នែកខាងក្រៅ (Loan) កាតព្វកិច្ចហិរញ្ញវត្ថុក្នុងការបង់រំលោះ (Lease Financing) ជាដើម។
- បំណុលដទៃៗទៀត (Other Liabilities) គឺសំដៅទៅលើបំណុលរយៈពេលវែងដទៃៗទៀតដែលមានដូចជា បំណុលលើប្រាក់សោធនិវត្តន៍ (Pension Fund Liabilities) ប្រាក់បង់ទុកមុនដោយអតិថិជន (Long-term Deposit from Customers) ពន្ធលើប្រាក់ចំណេញដែលត្រូវបង់ (Income Tax Payable) ជាដើម ។
- បំណុលដែលត្រូវបានពន្យា (Deferred Liability Charges) គណនីនេះប្រមូលផ្តុំនូវរាល់បំណុលរយៈពេលវែងដែលត្រូវទូទាត់ក្នុងពេលអនាគតដែលមានដូចជា ប្រាក់ចំណូលដែលមិនទាន់បានផ្តល់ទំនិញ ឬសេវាកម្ម (Unearned Revenue) សំណងដែលត្រូវសងទៅបុគ្គលិក (Compensation Liabilities) និងបំណុលផ្សេងៗ ទៀតដែលត្រូវទូទាត់នាថ្ងៃមុខ ។
- ការប្រាក់នៃភាពជាម្ចាស់ (Minority Interest) គឺជាការប្រាក់ដែលបានមកពីភាពជាម្ចាស់មួយផ្នែកនៃក្រុមហ៊ុនមួយដែលខ្លួនបានវិនិយោគមូលធនចូល ប៉ុន្តែមិនអាចលើសពី ៥០ ភាគរយ នៃមូលធនសរុបរបស់ក្រុមហ៊ុននោះទេ។
- ភាគហ៊ុនធម្មតា (Common Stock) ជាភាគហ៊ុនធម្មតាដែលក្រុមហ៊ុនបោះផ្សាយដើម្បីបង្កើនដើមទុន តាមរយៈការទទួលបានមូលធនពីវិនិយោគិន។
- ប្រាក់ចំណេញមូលធន (Capital Surplus) ជាគណនីមួយដែលជាទូទៅកើតឡើងនៅពេលដែលក្រុមហ៊ុនមួយបោះផ្សាយមូលបត្រជាលើកដំបូង (IPO) បន្ទាប់មកលក់វាក្នុងតម្លៃណាមួយខ្ពស់ជាងតម្លៃចារឹករបស់មូលបត្រនោះ។
- ប្រាក់ចំណេញរក្សាទុក (Retained Earnings) គឺជាប្រាក់បំរុងទុកដែលបានមកពីប្រាក់ចំណេញសុទ្ធដែលនៅសល់ បន្ទាប់ពីបានទូទាត់ភាគលាភទៅអោយម្ចាស់ភាគហ៊ុនទាំងអស់។
- ភាគហ៊ុនស្តុកទុក (Treasury Stock) សំដៅលើភាគហ៊ុនទាំងឡាយណាដែលក្រុមហ៊ុនបានបោះផ្សាយលក់លើទីផ្សារហើយ ប៉ុន្តែវាត្រូវបានទិញចូលមកវិញដោយមានការរំពឹងទុកថាតម្លៃរបស់ភាគហ៊ុននោះនឹងកើនឡើងខ្ពស់ជាងតម្លៃទីផ្សារបច្ចុប្បន្ន។
- មូលធនដទៃទៀត (Other Equity) សំដៅទៅលើចំណូល ឬចំណាយដ៏ទៃទៀតដែលធ្វើឲ្យមានការប្រែប្រួលក្នុងមូលធនរបស់ម្ចាស់ភាគហ៊ុន (Other Comprehensive Income) ដែលមានដូច

ជាផលចំណេញ ឬខាតទៅលើការវិនិយោគដែលពុំទាន់បានសម្រេច (Gain or Loss on Investment Available Sale) ផលចំណេញ ឬខាតលើរូបិយប័ណ្ណបរទេសដែលពុំទាន់បានលក់ចេញ (Gain or Loss on Foreign Currency Translation) និងផលចំណេញ ឬខាតលើគម្រោងវិនិយោគប្រាក់ចូលនិវត្សន៍ (Gain or Loss on Pension Plan)។ វាជាផលចំណេញ ឬខាតដែលត្រូវបានទទួលស្គាល់ជាបណ្តោះអាសន្នក្នុងតារាងតុល្យការ ប៉ុន្តែជាក់ស្តែងពុំទាន់បានទទួលស្គាល់ក្នុងរបាយការលទ្ធផលនៅឡើយទេ ព្រោះផលចំណេញ ឬខាតប្រភេទនេះស្ថិតក្រោមការវិនិយោគនៅឡើយ។ យ៉ាងណាមិញ វានឹងត្រូវបានទទួលស្គាល់ជាផលចំណេញ ឬខាតជាក់លាក់ក្នុងរបាយការលទ្ធផល នៅពេលដែលការវិនិយោគទាំងនេះត្រូវបានបញ្ចប់ ឬលក់ចេញ។

## ៣.២. **ភាវិភាគតាមអនុបាត** ( Ratio Analysis )

នៅក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks យើបានបែងចែកជា៥ផ្នែកសំខាន់ដូចតទៅៈ

- អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី
- អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង
- អនុបាតនៃប្រសិទ្ធភាពក្នុងការប្រើប្រាស់ទ្រព្យសកម្ម
- អនុបាតនៃលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញ
- អនុបាតនៃតម្លៃទីផ្សារភាគហ៊ុន

### ៣.២.១. **អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី**

- **អនុបាតចរន្ត** (Current ratio)

អនុបាតចរន្ត គឺជាផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លីសរុបជាមួយនឹងបំណុលរយៈពេលខ្លីសរុប។ អនុបាតមួយដែលប្រើសម្រាប់បង្ហាញអោយឃើញពីលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី និងកាតព្វកិច្ចផ្សេងៗ។ វាបង្ហាញអោយឃើញថាក្នុងរាល់ប្រាក់ដុល្លារនៃបំណុលរយៈពេលខ្លី តើក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីចំនួនប៉ុន្មានសំរាប់ទូទាត់បំណុលនឹងកាតព្វកិច្ចផ្សេងៗ ។ ផលធៀបកាន់តែធំ កាន់តែប្រសើរដោយវាបង្ហាញថាក្រុមហ៊ុនមានទ្រព្យសកម្មកាន់តែច្រើននោះក្រុមហ៊ុនមាន លទ្ធភាពខ្ពស់ស់សំរាប់ធានាលើការទូទាត់បំណុល និងនៅពេលជួបតម្រូវការផ្នែកហិរញ្ញវត្ថុផ្សេងៗទៀត។

**តារាងទី៣** អនុបាតចរន្តរបស់ក្រុមហ៊ុន Starbucks ឆ្នាំ ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Current Asset | 12,494,200 | 5,283,400 |
| B. Current Liabilities | 5,684,200 | 4,220,700 |
| (A/B). Current Ratio | 219.81% | 125.18% |

យោងតាមតារាងខាងលើបញ្ជាក់ថាអាត្រាផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លីជាមួយ និងបំណុលរយៈពេលខ្លីក្នុងឆ្នាំ២០១៧ ស្មើនឹង ១២៥,១៨% មានន័យថាក្នុង ១០០ដុល្លារ នៃបំណុល រយៈពេលខ្លីក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីចំនួន១២៥,១៨ដុល្លារសម្រាប់ទុកទូទាត់។ នៅក្នុងឆ្នាំ ២០១៨ អាត្រាផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លីនិងបំណុលរយៈពេលខ្លីមានកើនឡើងមកដល់ ២១៩,៨១% គឺមានការកើនឡើងចំនួន ៩៤,៦២% បើធៀបជាមួយនឹងឆ្នាំ ២០១៧ មានន័យថាក្នុង ១០០ដុល្លារ នៃបំណុលរយៈពេលខ្លីក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីចំនួន ២,១៩ដុល្លារសម្រាប់ទុកទូទាត់គឺមានការកើនឡើង ៩៣,៦២ដុល្លារ។ នេះបង្ហាញអោយឃើញថាលទ្ធភាពសងបំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុនកាន់តែប្រសើរបើធៀបនឹងឆ្នាំចាស់។

- **អនុបាតរហ័ស (Quick Ratio)**

អនុបាតរហ័ស គឺជាផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លីនិងសន្និធិជាមួយនឹងបំណុលរយៈពេលខ្លីវាបង្ហាញអោយឃើញថាក្នុងរាល់ដុល្លារនៃបំណុលរយៈពេលខ្លីមានទ្រព្យសកម្ម រហ័សចំនួនប៉ុន្មានសំរាប់ទូទាត់បំណុលរយៈពេលខ្លីនឹងកាតព្វកិច្ចផ្សេងៗ។ ផលធៀបកាន់តែធំកាន់តែប្រសើរដោយ វាបង្ហាញថាយើងមានទ្រព្យសកម្មរហ័សកាន់តែច្រើននោះយើងមានលទ្ធភាពខ្ពស់សំរាប់ធានាលើការទូទាត់បំណុលរយៈពេលខ្លីនិងនៅពេលជួបតម្រូវការផ្នែកហិរញ្ញវត្ថុផ្សេងៗ ទៀត។

**តារាងទី៤** អនុបាតរហ័សរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Current asset | 12,494,200 | 5,283,400 |

| | | |
|---|---|---|
| B. Inventory | 1,400,500 | 1,364,000 |
| C. Current Liability | 5,684,200 | 4,220,700 |
| [(A-B)/C]. Quick Ratio | 195.17% | 92.86% |

យោងតាមទិន្នន័យខាងបង្ហាញថា អាត្រាទ្រព្យសកម្មរយៈពេលខ្លីដកជាមួយសន្និធិធៀបជាមួយនឹងបំណុលរយៈពេលខ្លីក្នុងឆ្នាំ២០១៧ស្មើ ៩២,៨៦% មានន័យថាក្នុង ១០០ដុល្លារ នៃបំណុលរយៈពេលខ្លីក្រុមហ៊ុនមានទ្រព្យសកម្មរហ័សចំនួន៩២,៨៦ដុល្លារសម្រាប់ទុកទូទាត់។ នៅក្នុងឆ្នាំ២០១៨ អាត្រាទ្រព្យសកម្មរយៈពេលខ្លីដកជាមួយសន្និធិធៀបជាមួយនឹងបំណុលរយៈពេលខ្លីមានកើនឡើងមកដល់ ១៩៥,១៧% គឺមានការកើនឡើង ១០២,៣១% បើធៀបជាមួយនឹងឆ្នាំ ២០១៧ មានន័យថាក្នុង ១០០ដុល្លារ នៃបំណុលរយៈពេលខ្លី ក្រុមហ៊ុនមានទ្រព្យសកម្មចំនួន ១៩៥,១៧ដុល្លារសម្រាប់ទុកទូទាត់គឺមានការកើនឡើង១០២,៣១ដុល្លារ។ នេះបង្ហាញថាលទ្ធភាពសងបំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុនកាន់តែប្រសើរបើធៀបនឹងឆ្នាំចាស់។

- **អនុបាតសាច់ប្រាក់ (Cash Ratio)**

អនុបាតសាច់ប្រាក់ គឺជាផលធៀបរវាងសាច់ប្រាក់សរុបជាមួយនឹងបំណុលរយៈពេលខ្លីវាបង្ហាញអោយឃើញថាក្នុងរាល់ប្រាក់ដុល្លារនៃបំណុលរយៈពេលខ្លី មានសាច់ប្រាក់ ចំនួនប៉ុន្មានសំរាប់ទូទាត់បំណុលត្រលប់ទៅវិញ។ បើផលធៀបកាន់តែធំកាន់តែប្រសើរដោយវាបង្ហាញថាយើងមានសាច់ប្រាក់កាន់តែច្រើនសំរាប់ទូទាត់បំណុលត្រលប់ទៅវិញ ក៏ដូចជាពេលជួបតម្រូវការផ្នែកហិរញ្ញវត្ថុផ្សេងៗទៀត។

**តារាងទី៥** អនុបាតសាច់ប្រាក់របស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧ និង២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Cash | 8,756,300 | 2,462,300 |
| B. Current Liabilities | 5,684,200 | 4,220,700 |
| (A/B). Cash Ratio | 154.05% | 58.34% |

នៅក្នុងឆ្នាំ២០១៧ អត្រាផលធៀបរវាងសាច់ប្រាក់ជាមួយនឹងបំណុលរយៈពេលខ្លី ស្មើនិង ៥៨,៣៥% មានន័យថាក្នុង ១០០ដុល្លារ នៃបំណុលរយៈពេលខ្លីក្រុមហ៊ុនមានសាច់ប្រាក់ចំនួន ៥៨,៣៥ដុល្លារ សម្រាប់ទុកទូទាត់។ នៅក្នុងឆ្នាំ២០១៨អត្រាផលធៀបរវាងសាច់ប្រាក់ជាមួយនឹងបំណុលរយៈពេលខ្លីមានកើនឡើងមកដល់ ១៥៤,០៥% គឺមានការកើនឡើងរហូតដល់ចំនួន ៩៥,៦៦% បើធៀបជាមួយនឹងឆ្នាំ២០១៧។ មានន័យថាក្នុង ១០០ដុល្លារនៃបំណុលរយៈពេលខ្លីក្រុមហ៊ុនមានសាច់ប្រាក់ចំនួន ១៥៤,០៥ដុល្លារ សម្រាប់ទុកទូទាត់គឺមានការកើនឡើងចំនួន៩៥,៦៦ ដុល្លារ បើធៀបជាមួយឆ្នាំចាស់។

សរុបសេចក្តីមក អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុនរួមមាន អនុបាតចរន្ត (Current Ratio) អនុបាតរហ័ស (Quick Ratio) អនុបាតសាច់ប្រាក់ (Cash Ratio) មានការកើនឡើងគួឲ្យកត់សម្គាល់បើប្រៀបធៀបជាមួយនឹងឆ្នាំចាស់របស់ក្រុមហ៊ុន តាមរយៈនេះបង្ហាញឲ្យឃើញថាលទ្ធភាពនៃការទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុន ដោយមានទ្រព្យសកម្មរយៈពេលខ្លីកាន់តែល្អជាងឆ្នាំចាស់ ទោះបីជាក្រុមហ៊ុនប្រើប្រាស់បំណុលរយៈពេលខ្លីច្រើនជាងឆ្នាំ ចាស់ក៏ដោយ។

### ៣.២.២. អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង

- **អនុបាតបំណុលសរុប (Total Debt Ratio)**

អនុបាតបំណុលសរុប បង្ហាញពីភាគរយនៃបំណុលដែលខ្លួនប្រើនៅក្នុង ១០០ដុល្លារ នៃ ទ្រព្យសកម្មដែលក្រុមហ៊ុនមាន និងអាចបង្ហាញពីកម្រិតនៃការប្រើប្រាស់បំណុលថាខ្ពស់ឬទាប។ ក្រុមហ៊ុនក៏អាចដឹងផងដែរថាតើមានមូលធនប៉ុន្មានដែលបានប្រើក្នុង ១០០ ដុល្លារ នៃទ្រព្យសកម្ម នោះ។

**តារាងទី៦** អនុបាតបំណុលសរុបរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Total Debt | 22,986,900 | 8,915,500 |
| B. Total Assets | 24,156,400 | 14,365,600 |
| (A/B). Total Debt Ratio | 95.16% | 62.06% |

យោងលើតារាងទិន្នន័យខាងលើ បង្ហាញថានៅក្នុងឆ្នាំ២០១៧ អត្រាអនុបាតនៃបំណុលសរុបស្មើនិង ៦២,០៦% មានន័យថារាល់១០០ដុល្លារ នៃទ្រព្យសកម្មដែលក្រុមហ៊ុនមានក្រុមហ៊ុនមានប្រើប្រាស់បំណុលចំនួន ៦២,០៦ ដុល្លារ ហើយនៅក្នុងឆ្នាំ២០១៨ វិញផល ធៀបនេះ មានការស្ទុះឡើងយ៉ាងខ្លាំងមកដល់ ៩៥,១៦% ដែលមានន័យថារាល់ ១០០ដុល្លារ នៃទ្រព្យសកម្មដែលក្រុមហ៊ុនមានក្រុមហ៊ុនមានប្រើប្រាស់បំណុលអស់ដល់ទៅ ៩៥,១៦ ដុល្លារ គឺមានការកើនឡើងចំនួន ៣៣,១០ ដុល្លារ ។

- **បំណុលធៀបនឹងមូលធន (Debt/Equity Ratio)**

ផលធៀបបំណុលធៀបសរុបនឹងមូលធនរបស់ម្ចាស់ភាគហ៊ុន បង្ហាញពីការវាស់វែងភាគរយ នៃបំណុលសរុបរបស់ក្រុមហ៊ុនធៀបនឹងមូលធនដែលខ្លួនមានមានន័យថាក្នុង ១ដុល្លារ នៃមូលធនក្រុមហ៊ុនប្រើប្រាស់បំណុលប៉ុន្មានសម្រាប់មកវិនិយោគរួមគ្នា។ម៉្យាងវិញទៀតតាមរយៈអនុ-បាតនេះក្រុមហ៊ុន អាចដឹងពីបំណុលដែលមានជំពាក់និងមធ្យោបាយប្រមើលមើលពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការសងបំណុលទាំងនោះតាមរយៈទ្រព្យម្ចាស់ភាគហ៊ុនដែលមាននៅក្នុងក្រុមហ៊ុន។

**តារាងទី៧** បំណុលធៀបនឹងមូលធនរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Total Debt | 22,986,900 | 8,915,500 |
| B. Total Equity | 1,169,500 | 5,450,100 |
| (A/B). Debt/Equity Ratio | 19.66 | 1.64 |

យោងលើតារាងទិន្នន័យខាងលើ បង្ហាញថាបំណុលសរុបធៀបនឹងមូលធនសរុបនៅក្នុង ឆ្នាំ ២០១៧ ស្មើនឹង ១,៦៤ មានន័យថារាល់មូលធន ១ដុល្លារ ក្រុមហ៊ុនប្រើប្រាស់បំណុល ១,៦៤ ដុល្លាររួមជាមួយ។ ប៉ុន្តែទិន្នន័យនេះមានការកើនឡើងគួរអោយកត់សម្គាល់រហូតមកដល់ ១៩,៦៦ ក្នុងឆ្នាំ២០១៨ ដែលមានន័យថាបំណុលសរុបស្មើរហូតដល់ទៅ ១៩,៦៦ ដង នៃមូលធនសរុបគឺកើនឡើង ១៨,០២ ដង បើធៀបនឹងឆ្នាំ ២០១៧។

- **មេគុណមូលធន (Equity Multiplier)**

មេគុណមូលធន គឺជាអនុបាតនៃអនុភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (Financial Leverage) ដែលអាចវាស់វែងពីចំនួននៃទ្រព្យសកម្មដែលទទួលបានតាមរយៈការផ្តល់មូលធនដោយម្ចាស់ភាគ

ហ៊ុន។ ផលធៀបនេះថែមទាំងបង្ហាញពី កម្រិតនៃបំណុលដែលត្រូវបានប្រើដើម្បីទទួលបានទ្រព្យសកម្មទាំងនោះផងដែរ។

**តារាងទី៨** មេគុណមូលធនរបស់ក្រុមហ៊ុន Starbuck ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Total Assets | 24,156,400 | 14,365,600 |
| B. Total Equity | 1,169,500 | 5,450,100 |
| (A/B). Equity Multiplier | 20.66 | 2.64 |

តាមរយៈផលធៀបនេះយើងឃើញថានៅក្នុងឆ្នាំ២០១៧ មានផលធៀបស្មើនឹង ២,៦៤មានន័យថាទ្រព្យសកម្មសរុបស្មើត្រឹមតែ ២,៦៤ដង នៃមូលធនសរុបតែប៉ុណ្ណោះ។ទោះបីជាយ៉ាងណាក៏ដោយផលធៀបនេះមានការកើនឡើងយ៉ាងខ្លាំងមកដល់ ២០,៦៦ ក្នុងឆ្នាំ២០១៨ ដែលមានន័យថាទ្រព្យសកម្មសរុបស្មើរហូតដល់ទៅ ២០,៦៦ ដង នៃមូលធនសរុប គឺកើនឡើង ១៨,០២ ដង ធៀបនឹងឆ្នាំ ២០១៧។

- **អនុបាតនៃសមត្ថភាពទូទាត់ការប្រាក់** (Times Interest Earned Ratio)

គឺជាផលធៀបរវាងចំណូលមុនបង់ការប្រាក់ទៅម្ចាស់បំណុលនិងទូទាត់ពន្ធ នឹងការប្រាក់ ឬត្រូវបានហៅម៉្យាងទៀតថាជាអនុបាតនៃសមត្ថភាពក្នុងការទូទាត់ការប្រាក់ ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងពីសមត្ថភាពដែលក្រុមហ៊ុនអាចគ្រប់គ្រងកាតព្វកិច្ចក្នុងការទូទាត់ការប្រាក់បានល្អ ឬ យ៉ាងណាទៅកាន់ម្ចាស់បំណុល។

**តារាងទី៩** អនុបាតនៃសមត្ថភាពទូទាត់ការប្រាក់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. EBIT | 5,950,300 | 4,410,000 |
| B. Interest | 170,300 | 92,500 |
| (A/B). Times Interest Earned Ratio | 35 | 47.68 |

តាមរយៈតារាងខាងលើនេះ យើងឃើញថា នៅក្នុងឆ្នាំ២០១៧ មានផលធៀបស្មើនិង ៤៧,៦៨ មានន័យថាប្រាក់ចំណេញប្រតិបត្តិការរបស់ក្រុមហ៊ុននេះ អាចទូទាត់ការប្រាក់បាន ៤៧,៦៨ ដង។ យ៉ាងណាមិញផលធៀបនេះមានការថយចុះបន្តិច ក្នុងឆ្នាំ ២០១៨ ដែលស្មើនិង ៣៥ ដង នោះមានន័យថាប្រាក់ចំណេញប្រតិបត្តិការរបស់ក្រុមហ៊ុន អាចទូទាត់ការប្រាក់បានតែ ៣៥ ដង ប៉ុណ្ណោះ គឺតិចជាងឆ្នាំមុន ១២,៦៨ ដង ។

យោងតាមទិន្នន័យនៃការវិភាគខាងលើ យើងឃើញថានៅឆ្នាំ ២០១៨ អនុបាតបំណុលសរុបអនុបាតបំណុលធៀបនឹងមូលធន និងមេគុណមូលធនមានការកើនឡើង មានន័យថាក្រុមហ៊ុនប្រើប្រាស់បំណុលកាន់តែច្រើន រីឯអនុបាតទូទាត់ការប្រាក់ឬអនុបាតគ្របដណ្តប់សាច់ប្រាក់មានការធ្លាក់ចុះបើធៀបនឹងឆ្នាំ២០១៧ ដូច្នេះយើងអាចសន្និដ្ឋានបានថាលទ្ធភាពនៃការទូទាត់បំណុលរយៈពេលវែងរបស់ Starbucks ក្នុងឆ្នាំ ២០១៨ មានការថយចុះជាងឆ្នាំ ២០១៧។

### ៣.២.៣. អនុបាតនៃប្រសិទ្ធិភាពក្នុងការប្រើប្រាស់ទ្រព្យសកម្ម

នៅក្នុងចំណុចនេះ គឺយើងសិក្សាលើប្រសិទ្ធភាពដែលក្រុមហ៊ុនប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួន។ ហើយការវ៉ាស់វែងនៅក្នុងចំណុចនេះជួនកាលត្រូវបានគេហៅថាសមាមាត្រ របស់ទ្រព្យសកម្ម។ ហើយអ្វីដែលចង់បកស្រាយនៅក្នុងចំណុចនេះគឺតើក្រុមហ៊ុនប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពឬស៊ីជម្រៅយ៉ាងណាដើម្បីបង្កើនការលក់។ហើយនៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើចំណុចមួយចំនួនគឺៈ

- **ការបង្វិលសន្និធិ ( Inventory Turnover )**

ចំណូលការបង្វិលសន្និធិ (Inventory Turnover) គឺជាផលធៀបរវាងថ្លៃដើមនៃការលក់ទំនិញសរុបជាមួយនឹងសន្និធិដើម្បីអោយដឹងថាលទ្ធភាពបង្វិលសន្និធិរបស់ក្រុមហ៊ុនក្នុងមួយឆ្នាំ ថាតើក្រុមហ៊ុនអាចបង្វិលសន្និធិបានប៉ុន្មានដងក្នុងមួយឆ្នាំ។

**តារាងទី១០** ចំណូលសន្និធិរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---:|---:|
| A. Cost of Revenue | 10,174,500 | 9,034,300 |
| B. Inventory | 1,400,500 | 1,364,000 |

| | | |
|---|---|---|
| (A/B). Inventory Turnover | 7.26 | 6.62 |

យោងតាមទិន្នន័យនៅក្នុងតារាងខាងលើបានបង្ហាញថា អាត្រាផលធៀបរវាងចំណាយថ្លៃដើមជាមួយនឹងសន្និធិនៅក្នុងក្រុមហ៊ុននៅក្នុងឆ្នាំ ២០១៧ ស្មើនឹង៦,៦២ មានន័យថានៅក្នុងឆ្នាំ ២០១៧ ជាមធ្យមក្រុមហ៊ុនអាចបង្វិលសន្និធិបាន ៦,៦២ដងក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០១៨អាត្រាផលធៀបរវាងចំណាយថ្លៃដើមជាមួយនិងសន្និធិស្មើនឹង ៧,២៦ មានន័យថា នៅក្នុងឆ្នាំ២០១៧ ជាមធ្យមក្រុមហ៊ុនអាចបង្វិលសន្និធិបាន ៧,២៦ដងក្នុងមួយឆ្នាំវាមានការកើនឡើងចំនួន ០,៦៥ដងបើធៀបជាមួយឆ្នាំចាស់។

- **រយៈពេលចំនួនថ្ងៃនៃការបង្វិលសន្និធិ (Day's sales in inventory)**

រយៈពេលនៃការបង្វិលសន្និធិ គឺការផលធៀបរវាងរយៈពេលថ្ងៃក្នុងមួយឆ្នាំជាមួយនឹងចំនួនដងក្នុងការបង្វិលសន្និធិក្នុងមួយឆ្នាំ (Inventory Turnover) ហើយការគណនានេះធ្វើឡើងដើម្បីចង់ដឹងពីចំនួនថ្ងៃក្នុងការបង្វិលសន្និធិម្តងៗរបស់ក្រុមហ៊ុន។

**តារាងទី១១** ចំនួនថ្ងៃក្នុងការបង្វិលសន្និធិរបស់ក្រុមហ៊ុន Starbuck ឆ្នាំ២០១៧-២០១៨

| | 2018 | 2017 |
|---|---|---|
| A. Days | 365 | 365 |
| B. Inventory Turnover | 7,26 | 6,62 |
| (A/B). Day's Sales in Inventory | 50.27 | 55.13 |

យោងតាមតារាងខាងលើបានបង្ហាញនៅក្នុងឆ្នាំ២០១៧ អាត្រាផលធៀបរវាងចំនួនថ្ងៃក្នុងមួយឆ្នាំជាមួយនឹងចំនួនដងនៃការបង្វិលសន្និធិក្នុងមួយឆ្នាំស្មើនឹង ៥៥,១៣ មានន័យថាជាមធ្យមក្រុមហ៊ុនប្រើប្រាស់រយៈចំនួន ៥៥,១៣ថ្ងៃនៅក្នុងការបង្វិលសន្និធិម្តងៗ។ នៅក្នុងឆ្នាំ២០១៨ អាត្រាផលធៀបរវាងចំនួនថ្ងៃក្នុងមួយឆ្នាំជាមួយនឹងចំនួនដងនៃការបង្វិលសន្និធិក្នុងមួយឆ្នាំ ស្មើនឹង ៥០,២៧ ជាមធ្យមក្រុមហ៊ុនប្រើប្រាស់រយៈពេល ៥០,២៧ថ្ងៃនៅក្នុងការបង្វិលសន្និធិម្តងៗ។ យើងសង្កេតឃើញថា វាការថយចុះចំនួន៤,៨៦ថ្ងៃ បើធៀបជាមួយឆ្នាំចាស់។

- **ការបង្វិលឥណទេយ្យ (Receivable turnover)**

ការបង្វិលឥណទេយ្យ (Receivable turnover) ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងថាការប្រមូលការលក់ទំនិញដោយជំពាក់របស់របស់ក្រុមហ៊ុនមានរយៈពេលលឿនយ៉ាងណា។

**តារាងទី១២** ការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុន Starbuck ក្នុងឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Sale | 24,719,500 | 22,386,800 |
| B. Net Receivable | 693,100 | 870,400 |
| (A/B) Receivable turnover | 35.66 | 25.72 |

នៅក្នុងឆ្នាំ២០១៧ អត្រាផលធៀបរវាងការលក់សរុបជាមួយនឹងឥណទេយ្យរបស់ក្រុមហ៊ុនស្មើនិង ២៥,៧២ មានន័យថានៅក្នុងឆ្នាំ២០១៧ក្រុមហ៊ុនអាចបង្វិល ឥណទេយ្យបានចំនួន២៥,៧២ដង នៅក្នុងមួយឆ្នាំ។នៅក្នុងឆ្នាំ២០១៨ អត្រាផលធៀបរវាងការលក់សរុបជាមួយនឹង ឥណទេយ្យរបស់ក្រុមហ៊ុនក្នុងស្មើនិង៣៥,៦៦ មានន័យថានៅក្នុងឆ្នាំ២០១៨ក្រុមហ៊ុនអាចបង្វិលឥណទេយ្យបានចំនួន ៣៥,៦៦ដង នៅក្នុងមួយឆ្នាំហើយបើប្រៀបធៀបទៅនឹងឆ្នាំចាស់ការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុនមាន ការកើនឡើងបានច្រើនជាងឆ្នាំចាស់ចំនួន៩,៩៤ដង។ វាក៏បង្ហាញឲ្យឃើញថាប្រសិទ្ធភាពនៃគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុនមានកាកើនឡើងច្រើនផងដែរ។

- **ចំនួនថ្ងៃក្នុងការបង្វិលឥណទេយ្យ (Day's sales in Receivable)**

ចំនួនថ្ងៃក្នុងការបង្វិលឥណទេយ្យ (Day's sales in Receivable) ត្រូវបាន ប្រើប្រាស់ដើម្បីវាស់វែងអំពីចំនួនថ្ងៃនៃការប្រមូលការលក់ទំនិញដោយជំពាក់របស់របស់ក្រុមហ៊ុនមាន រយៈ-ពេលយ៉ាងណាដែរ។

**តារាងទី១៣** ចំនួនថ្ងៃក្នុងការបង្វិលឥណទេយ្យក្រុមហ៊ុនStrabucksឆ្នាំ២០១៧-២០១៨

| | 2018 | 2017 |
|---|---|---|
| A. Days in year | 365 | 365 |
| B. Receivable turnover | 35,66 | 25,72 |

| | | |
|---|---|---|
| (A/B). Day's Sales in Recievables | 10,24 | 14,19 |

យោងតាមតារាងនៃទិន្នន័យខាងលើបានបង្ហាញថា ផលធៀបនៃចំនួនថ្ងៃក្នុងមួយឆ្នាំនិងចំនួនដងនៃការបង្វិលឥណទេយ្យក្នុងមួយឆ្នាំរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ២០១៧ ស្មើនិង ១៤,១៩ មានន័យថាក្រុមហ៊ុនចំណាយពេលជាមធ្យម ១៤,១៩ថ្ងៃ នៅក្នុងការបង្វិលឥណទេយ្យម្តងៗ។ ហើយនៅ ក្នុងឆ្នាំ២០១៨ ផលធៀបនៃចំនួនថ្ងៃក្នុងមួយឆ្នាំនិងចំនួនដងនៃការបង្វិល ឥណទេយ្យក្នុងមួយឆ្នាំ ស្មើនឹង១០,២៤ មានន័យថានៅក្នុងឆ្នាំ២០១៨ក្រុមហ៊ុនប្រើរយៈពេលជាមធ្យមចំនួន ១០,២៤ថ្ងៃ ក្នុង ការបង្វិលឥណទេយ្យម្តងៗ បើប្រៀបធៀបទៅនឹងឆ្នាំចាស់ចំនួនថ្ងៃមានការថយចុះចំនួន៣,៩៥ថ្ងៃ មានន័យថាការគ្រប់គ្រងទឹកប្រាក់អតិថិជនជំពាក់ក្រុមហ៊ុនមានប្រសិទ្ធភាពជាងឆ្នាំចាស់។

- **ការប្រើប្រាស់ទុនបង្វិល (Net Working Capital Turnover)**

ការប្រើប្រាស់ទុនបង្វិល (Net Working Capital Turnover) សមាមាត្រប្រើប្រាស់ដើម្បីនេះវាស់ពីចំនួនការងារដែលយើងទទួលបានក្រោយពីការប្រើប្រាស់ទុនបង្វិលរបស់យើង។

**តារាងទី១៤** តារាងប្រើប្រាស់ទុនបង្វិលរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Sales | 24,719,500 | 22,386,800 |
| B. Net working capital | 6,810,000 | 1,062,700 |
| (A/B). NWC Turnover | 363% | 2107% |

តាមតារាងទិន្នន័យខាងលើបង្ហាញថា អាត្រាផលធៀបរវាងការលក់សរុបធៀបនឹងទុនបង្វិលនៅក្នុងឆ្នាំ២០១៧ ស្មើនិង២១០៧% មានន័យថារាល់ការប្រើប្រាស់ទុនបង្វិល 100ដុល្លារ ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូល ២១០៧ដុល្លារ។ ហើយនៅក្នុងឆ្នាំ២០១៨ អាត្រាផលធៀបរវាងការលក់សរុបជាមួយនឹងទុនបង្វិលស្មើនិង ៣៦៣% មានន័យថារាល់ការប្រើប្រាស់ទុនបង្វិល ១០០

ដុល្លារក្រុមហ៊ុនទទួលបានប្រាក់ចំណូលត្រឹមតែ ៣៦៣ដុល្លារប៉ុណ្ណោះ ឃើញថាមានការថយចុះចំនួន ១៧៤៤ ដុល្លារ បើប្រៀបធៀបជាមួយឆ្នាំ ២០១៧។

- **ការបង្វិលទ្រព្យសកម្មរយៈពេលវែង(Fixed asset turnover)**

ការបង្វិលទ្រព្យសកម្មរយៈពេលវែង(Fixed asset turnover) ត្រូវបានប្រើប្រាស់ដើម្បីចង់ដឹងថារាល់ប្រាក់ដុល្លារនៃទ្រព្យសកម្មរយៈពេលវែងរបស់ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូលចំនួនប៉ុន្មានដល់ក្រុមហ៊ុន។

**តារាងទី១៥** ការបង្វិលទ្រព្យសកម្មរយៈពេលវែងរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Sales | 24,719,500 | 22,386,800 |
| B. Net Fixed assets | 5,929,100 | 4,919,500 |
| (A/B). FA Turnover | 416.92% | 455.06% |

យោងតាមតារាងខាងលើបង្ហាញថា អាត្រាផលធៀបរវាងការលក់សរុបជាមួយនឹងទ្រព្យសកម្មរយៈពេលវែងសរុបរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ២០១៧ ស្មើនិង ៤៥៥,០៦% មានន័យថារាល់ទ្រព្យសកម្មរយៈពេលវែងរបស់ក្រុមហ៊ុន ១០០ដុល្លារ ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូលបាន ៤៥៥,០៦ដុល្លារ។ ហើយនៅក្នុងឆ្នាំ២០១៨ អាត្រាផលធៀបរវាងការលក់សរុបជាមួយនឹងទ្រព្យសកម្មរយៈពេលវែងសរុបរបស់ក្រុមហ៊ុន ស្មើនិង៤១៧,៩២% មានន័យថារាល់ទ្រព្យសកម្ម រយៈពេលវែង១០០ដុល្លារ ក្រុមហ៊ុនអាចបង្កើតចំណូលបាន ៤១៦,៩២ដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំចាស់វាមានការថយចុះចំនួន ៣៨,១៤ដុល្លារ។

- **ចំណូលពីការប្រើប្រាស់ទ្រព្យសកម្មសរុប(Total asset Turnover)**

ចំណូលពីការប្រើប្រាស់ទ្រព្យសកម្មសរុប(Total asset Turnover)ត្រូវបានប្រើប្រាស់ដើម្បីចង់ដឹងអំពីរាល់ប្រាក់ដុល្លារ នៃការប្រើប្រាស់ទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូលបានប៉ុន្មានមកវិញ។

**តារាងទី១៦** ចំណូលពីការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Sales | 24,719,500 | 22,386,800 |
| B. Tatal Asset | 24,156,400 | 14,365,600 |
| (A/B). Total Asset Turnover | 102.33% | 155.83% |

តាមតារាងនៃទិន្នន័យខាងលើបានបង្ហាញថា អាត្រាផលធៀបរវាងការលក់សរុបធៀបនឹងទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ២០១៧ ស្មើនិង១៥៥,៨៣%មានន័យថារាល់ការវិនិយោគ១០០ដុល្លារទៅលើទ្រព្យសកម្មសរុបក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូលបានចំនួន១៥៥,៨៣ដុល្លារ។ នៅក្នុងឆ្នាំ២០១៨ អាត្រាផលធៀបរវាងការលក់សរុបធៀបទៅនឹងទ្រព្យសកម្មសរុប ស្មើនិង ១០២,៣៣% មានន័យថារាល់ការវិនិយោគ ១០០ដុល្លារ ទៅលើទ្រព្យសកម្មសរុបក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូលបាន ១០២,៣៣ដុល្លារ គឺមានការថយចុះ ៥៣,៥០ដុល្លារបើប្រៀបធៀបទៅនឹងឆ្នាំមុន។

សរុបមក ក្រុមហ៊ុនគ្រប់គ្រងសន្និធិនិងឥណទេយ្យនៅឆ្នាំ ២០១៨ បានល្អបើធៀបនឹងឆ្នាំ២០១៧។ដោយឡែកប្រសិទ្ធិភាពក្នុងការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនដូចជា ការប្រើប្រាស់ទុនបង្វិល (Net working capital turnover) ការបង្វិលទ្រព្យសកម្មរយៈពេលវែង (Fixed assets turnover) និងការប្រើប្រាស់ទ្រព្យសកម្មសរុប (Total assets turnover) មានការធ្លាក់ចុះគួឲ្យកត់សម្គាល់ផងដែរ។

### ៣.២.៤. អនុបាតនៃលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញ

- **អនុបាតប្រាក់ចំណេញសុទ្ធ (Profit Margin Ratio)**

អនុបាតប្រាក់ចំណេញសុទ្ធជាអនុបាតមួយដែលវាស់វែងពីភាគរយនៃប្រាក់ចំណេញដែលទទួលបានតាមរយៈរាល់ ១០០ ដុល្លារ នៃការលក់ ដោយបានមកពីការប្រៀបធៀប ប្រាក់ចំណេញសុទ្ធ និង ប្រាក់ចំណូលពីការលក់របស់ក្រុមហ៊ុន។ ម៉្យាងវិញទៀតអនុបាតនេះថែមទាំងអាចប្រាប់ពីប្រសិទ្ធភាពគ្រប់គ្រងចំណាយផងដែរ។

**តារាងទី១៧** អនុបាតប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Net Income | 4,518,300 | 2,884,700 |
| B. Sales | 24,719,500 | 22,386,800 |
| (A/B). Profit Margin | 18.28% | 12.89% |

តាមរយៈតារាងខាងលើបានបង្ហាញថា អនុបាតប្រាក់ចំណេញ នៅក្នុងឆ្នាំ២០១៧ ស្មើ ១២,៨៩% មានន័យថា ក្នុង ១០០ ដុល្លារ នៃចំណូល ក្រុមហ៊ុនបានបង្កើតប្រាក់ចំណេញ ១២,៨៩ ដុល្លារ។ ប៉ុន្តែក្នុងឆ្នាំ២០១៨ ផលធៀបនេះមានការកើនឡើងច្រើនគួរអោយកត់សម្គាល់រហូតមក ដល់ ១៨,២៨% ដែលមានន័យថាក្នុង ១០០ ដុល្លារ នៃចំណូល ក្រុមហ៊ុនបានបង្កើតប្រាក់ចំណេញ ១៨,២៨ ដុល្លារ គឺច្រើនជាងឆ្នាំ ២០១៧ ចំនួន ៥,៣៩ ដុល្លារ។ អាចនិយាយម្យ៉ាងទៀតថា នៅឆ្នាំ ២០១៨ ក្រុមហ៊ុនគ្រប់គ្រងចំណាយមានប្រសិទ្ធភាពជាងឆ្នាំ ២០១៧។

- **អនុបាតផលចំណេញពីទ្រព្យសកម្ម (Return on Asset)**

អនុបាតនៃប្រាក់ចំណេញតាមរយៈទ្រព្យសកម្មបង្ហាញពីការវាស់វែងនៃប្រាក់ចំណេញថា តើប្រាក់ចំណេញប៉ុន្មានដុល្លារដែលទទួលបានរៀងរាល់១ដុល្លារនៃការប្រើប្រាស់ទ្រព្យសកម្មនោះ។

**តារាងទី១៨** អនុបាតផលចំណេញពីទ្រព្យសកម្មរបស់ Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Net Income | 4,518,300 | 2,884,700 |
| B. Total Assets | 24,156,400 | 14,365,600 |
| (A/B). Return on Asset (ROA) | 18.70% | 20.10% |

តាមរយៈតារាងខាងលើបានបង្ហាញថា នៅក្នុង ឆ្នាំ២០១៧ មានផលធៀបស្មើនឹង ២០,១០% មានន័យថារាល់ ១០០ ដុល្លារ នៃការវិនិយោគលើទ្រព្យសកម្មសរុបក្រុមហ៊ុនអាចបង្កើតប្រាក់ ចំណេញបានដល់ទៅ ២០,១០ ដុល្លារ ។ ទោះជាយ៉ាងណាក៏ដោយក្នុងឆ្នាំ ២០១៨ ផលធៀប

នេះ មានការថយចុះបន្តិចមក ១៨,៧០% ដែលមានន័យថា រាល់ ១០០ ដុល្លារ នៃការវិនិយោគទៅលើ ទ្រព្យសកម្មសរុបក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបានត្រឹមតែ ១,៨០ដុល្លារ គឺមានការថយចុះ ១,៨០ ដុល្លារ ។

- **អនុបាតផលចំណេញពីមូលធនម្ចាស់ភាគហ៊ុន (Return on Equity)**

ផលធៀបរវាងប្រាក់ចំណេញសុទ្ធ និងមូលធនម្ចាស់ភាគហ៊ុនជាអនុបាតមួយដែលប្រាប់ពីប្រាក់ចំណេញដែលកើតឡើងតាមរយៈ ១ ដុល្លារ នៃមូលធនដែលក្រុមហ៊ុនមាន។

**តារាងទី១៩** អនុបាតផលចំណេញពីមូលធនម្ចាស់ភាគហ៊ុនរបស់ Starbuck ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Net Income | 4,518,300 | 2,884,700 |
| B. Total Equity | 1,169,500 | 5,450,100 |
| (A/B). Return on Equity (ROE) | 386.34% | 52.93% |

តាមរយៈទិន្នន័យខាងលើបានបង្ហាញថានៅក្នុង ឆ្នាំ២០១៧ ក្រុមហ៊ុននេះ មានផលធៀបនៃផលចំណេញពីមូលធន ស្មើនិង ៥២,៩៣% មានន័យថារាល់ ១០០ ដុល្លារ នៃការដាក់មូលធនសរុប ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបានតែ ៥២,៩៣ ដុល្លារប៉ុណ្ណោះ។ ប៉ុន្តែក្នុងឆ្នាំ ២០១៨ ផលធៀបនេះមានការស្ទុះឡើងយ៉ាងខ្លាំងរហូតមកដល់ ៣៨៦,៣៤% ដែលមានន័យថា រាល់១០០ ដុល្លារ នៃការដាក់មូលធនសរុបក្រុមហ៊ុនបានបង្កើតប្រាក់ចំណេញដល់ទៅ ៣៨៦,៣៤ដុល្លារ គឺមានការកើនឡើងយ៉ាងច្រើនរហូតដល់ ចំនួន ៣៣៣,៤១ ដុល្លារ បើធៀបទៅនឹង ឆ្នាំ ២០១៧។

យោងតាមទិន្នន័យនៃការវិភាគលើអនុបាតនៃលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញ ខាងលើ យើងឃើញថានៅឆ្នាំ ២០១៨ ប្រាក់ចំណេញរបស់ក្រុមហ៊ុនដែលបានពីការវិនិយោគលើទ្រព្យសកម្ម (ROA) មានការថយចុះតែបន្តិចប៉ុណ្ណោះ ដោយឡែកយើងសង្កេតឃើញថា ចំណូលរបស់ក្រុមហ៊ុនបានបង្កើតប្រាក់ចំណេញ (Profit Margin) និងប្រាក់ចំណេញរបស់ក្រុមហ៊ុនដែលបានពីមូលធនម្ចាស់ភាគហ៊ុន (ROE) បានស្ទុះឡើងច្រើនជាងឆ្នាំមុនគួរឲ្យកត់សម្គាល់។ ដោយផ្អែកលើ

ការបកស្រាយខាងលើ ដូច្នេះយើងអាចសន្និដ្ឋានបានថាលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញរបស់ Starbucks ក្នុងឆ្នាំ ២០១៨ មានភាពល្អប្រសើរច្រើនជាងឆ្នាំ ២០១៧។

**៣.២.៥. អនុបាតនៃតម្លៃទីផ្សារភាគហ៊ុន**(Market Value Measure)

នៅក្នុងចំណុចនេះយើង នឹងសិក្សាទៅលើអនុបាតនៃតម្លៃទីផ្សារភាគហ៊ុនដែលហើយការគណនានេះសម្រាប់តែក្រុមហ៊ុនដែលជួញដូរជាសាធារណៈតែប៉ុណ្ណោះ។

នៅក្នុងឆ្នាំ២០១៧ ក្រុមហ៊ុនStarbucks បោះផ្សាយភាគហ៊ុនចំនួន ១.៤៦២.០០០ ហ៊ុន និង តម្លៃនៃការលក់គឺ ៥៥,៨៣ ដុល្លារក្នុងមួយហ៊ុននៅចុងឆ្នាំ ហើយប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុនគឺ ២.៨៨៤.៧០០ដុល្លារ។ ហើយនៅក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនបោះផ្សាយភាគហ៊ុនចំនួន ១.៣៩៥.០០០ ហ៊ុន និងតម្លៃនៃការលក់គឺ៦៤,០៦ដុល្លារ ក្នុងមួយហ៊ុន ហើយប្រាក់ចំណេញស្មើនឹង ៤.៥១៨.៣០០ដុល្លារ។ ចំណែកឯមូលធនសរុបរបស់ក្រុមហ៊ុននៅក្នុងឆ្នាំក្នុងឆ្នាំ២០១៧ មានចំនួន ៥.៤៥០.១០០ដុល្លារ និងនៅក្នុងឆ្នាំ២០១៨ មានចំនួន ១.១៦៩.៥០០ដុល្លារ។

- **អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ (Price Earnings ratio)**

អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ (Price Earnings ratio) ប្រើប្រាស់ដើម្បីវាស់វែងថាតើវិនិយោគទុននឹងត្រូវចំណាយប្រាក់ប៉ុន្មានក្នុងមួយហ៊ុន ដើម្បីទទួលបានប្រាក់ចំណេញ ១ដុល្លារក្នុងមួយហ៊ុន។

**តារាងទី២០**ប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Net Income | 4,518,300 | 2,884,700 |
| B. Share | 1,395,000 | 1,462,000 |
| (A/B). Earnings per share | 3.24 | 1.97 |

**តារាងទី២១** អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញរបស់ក្រុមហ៊ុនឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|

| | | |
|---|---|---|
| A. Price Per share | 64.06 | 55.83 |
| B. Earnings per share | 3.24 | 1.97 |
| (A/B). Price Earnings Ratio | 19.77 | 28.34 |

យោងតាមទិន្នន័យនៅក្នុងតារាងខាងលើបានបង្ហាញថា នៅក្នុងឆ្នាំ២០១៧ ដើម្បីទទួលបាន ប្រាក់ចំណេញក្នុងមួយហ៊ុន ១ដុល្លារ អ្នកវិនិយោគទុនហ៊ានចំណាយក្នុងមួយហ៊ុន ២៨,៣៤ ដុល្លារ ហើយនៅក្នុងឆ្នាំ២០១៨ អ្នកវិនិយោគហ៊ានចំណាយត្រឹមតែ ១៩,៧៧ដុល្លារ។ បើប្រៀបឆ្នាំទាំងពីរនេះការចំណាយទៅលើការវិនិយោគរបស់អ្នកវិនិយោគទុនមានការថយចុះចំនួន ៨,៥៧ ដុល្លារ បើធៀបឆ្នាំ ២០១៧។

- **អនុបាតតម្លៃទីផ្សារធៀបនឹងតម្លៃក្នុងបញ្ជី (Market to Book Ratio)**

អនុបាតទីផ្សារ គឺជាការប្រៀបធៀបតម្លៃទីផ្សារទៅនឹងតម្លៃនៅក្នុងបញ្ជីរបស់ក្រុមហ៊ុនដែលបានផ្ដល់ឲ្យដើម្បីចង់ដឹងពីភាពខុសគ្នារវាងតម្លៃភាគហ៊ុននៅលើទីផ្សារ ជាមួយនឹងតម្លៃនៅក្នុងបញ្ជី។

**តារាងទី២២** តម្លៃភាគហ៊ុននៅក្នុងបញ្ជីរបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Total Equity | 1,169,500 | 5,450,100 |
| B. Share | 1,395,000 | 1,462,000 |
| (A/B). Book Value Per share | 0.84 | 3.73 |

**តារាងទី២៣** អនុបាតទីផ្សាររបស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 (USD) | 2017 (USD) |
|---|---|---|
| A. Market Price Per share | 64.06 | 55.83 |
| B. Book Value Per share | 0.84 | 3.73 |

| | | |
|---|---|---|
| (A/B). Market to book Ratio | 76.26 | 14.97 |

តាមទិន្នន័យខាងលើបង្ហាញថា អនុបាតទីផ្សាររបស់ក្រុមហ៊ុននៅក្នុង ឆ្នាំ២០១៧ ស្មើនិង ១៤,៩៧ដង នៃតម្លៃនៅក្នុងបញ្ជី និងនៅក្នុងឆ្នាំ២០១៨ អនុបាតទីផ្សាររបស់ក្រុមហ៊ុន ស្មើនិង ៧៦,២៦ដង ទៅនឹងតម្លៃនៅក្នុងបញ្ជី។

សរុបមកមក តម្លៃទីផ្សារធៀបនឹងតម្លៃក្នុងបញ្ជី (Market to Book Ratio) ក្នុង ឆ្នាំ២០១៨ មានភាពកាន់តែល្អប្រសើរជាងឆ្នាំ២០១៧
នេះបញ្ជាក់ថាអ្នកគ្រប់គ្រងអាចបង្កើតម្លៃទីផ្សារដល់ទ្រព្យ អ្នកវិនិយោគ។ ក្នុងនោះផងដែរអនុបាតថ្លៃភាគហ៊ុនជាមួយនឹងប្រាក់ចំណេញ(Price Earnings ratio) មានការថយចុះជាងឆ្នាំចាស់ មានន័យថាអ្នកវិនិយោគហ៊ានចំណាយប្រាក់ក្នុងការទិញភាគហ៊ុនក្នុងមួយហ៊ុនតិចជាងឆ្នាំ ២០១៧។

## ៣.៣. ការវិភាគតាម Du Pont Identity

ក្នុងការវិភាគប្រាក់ចំណេញពីមូលធនរបស់ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន តាមរយៈអនុបាត ឬផលធៀបរវាង ប្រាក់ចំណេញសរុប នឹងមូលធនសរុប យើងក៏អាចវិភាគតាមវិធីសាស្ត្រមួយទៀត ហៅថា Du Pont Identity ដែលការវិភាគនេះ អាចចង្អុលបង្ហាញក្រុមហ៊ុនអោយបានដឹងពី កត្តាចំនួន ៣ ដែលនាំអាចអោយប្រាក់ចំណេញតាមរយៈមូលធនរបស់ក្រុមហ៊ុន ថយចុះ ឬ កើនឡើង។ កត្តាទាំង ៣ នោះមានដូចជា៖

១. ប្រសិទ្ធិភាពនៃប្រតិបត្តិការ (Operating Efficiency វាស់ដោយ Profit Margin Ratio)

២. ប្រសិទ្ធិភាពនៃការប្រើប្រាស់ទ្រព្យសកម្ម (Asset Use Efficiency វាស់ដោយTotal Asset Turnover)

៣. អនុភាពហិរញ្ញវត្ថុ (Financial Leverage វាស់ដោយ Equity Multiplier)

**តារាងទី២៤** ការវិភាគតាម Du Pont Identify របស់ក្រុមហ៊ុន Starbucks ឆ្នាំ២០១៧-២០១៨

| | 2018 | 2017 |
|---|---|---|
| A. Profit Margin | 18.28% | 12.89% |
| B. Total Asset Turnover | 1.02 | 1.56 |

| | | |
|---|---|---|
| C. Equity Multiplier | 20.66 | 2.64 |
| (A x B x C). ROE | 386.34% | 52.93% |

តាមរយៈតារាងខាងលើបានបង្ហាញថា នៅក្នុង ឆ្នាំ២០១៧ ផលចំណេញពីមូលធនស្មើត្រឹមតែ ៥២,៩៣% ប៉ុណ្ណោះ ដែលបណ្តាលមកពី កម្រិតនៃប្រាក់ចំណេញដែលមានតែ ១២,៨៩% និង មេគុណមូលធនដែលទាបខ្លាំងត្រឹមតែ ២,៦៤ ដង ប៉ុណ្ណោះនៃមូលធន។ យ៉ាងណាមិញ យើងឃើញថានៅក្នុង ឆ្នាំ២០១៨ ផលចំណេញពីមូលធនមានការកើនឡើងមកដល់ ៣៨៦,៣៥% ឯណោះ ដែលបណ្តាលមកពីកម្រិតនៃប្រាក់ចំណេញមានដល់ទៅ ១៨,២៨% និង មេគុណមូលធនមានការស្ទុះខ្លាំងរហូតមកដល់ ២០,៦៦ ដង ឯណោះនៃមូលធន។ ទាំងនេះសបញ្ជាក់អោយឃើញថា ក្នុងឆ្នាំ ២០១៧ ប្រសិទ្ធិភាពនៃប្របត្តិការ (Operating efficiency) និង អនុភាពហិរញ្ញវត្ថុ (Financial Leverage) របស់ Starbuck Corporation នៅមានភាពខ្សោយនៅឡើយ។ ប៉ុន្តែក្នុងឆ្នាំ ២០១៨ ប្រសិទ្ធិភាពនៃប្របត្តិការ (Operating efficiency) និង អនុភាពហិរញ្ញវត្ថុ (Financial Leverage) របស់ក្រុមហ៊ុននេះ មានភាពខ្លាំងជាងឆ្នាំ ២០១៧។

### ៣.៤. លទ្ធផលនៃការវិភាគ

ក្រោយពីធ្វើការសិក្សា និងវិភាគទៅលើទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks នោក្នុងឆ្នាំ ២០១៨ ដោយប្រៀបធៀបនឹងឆ្នាំ ២០១៧ តាមរយៈការប្រើប្រាស់អនុបាតរួចមកយើងសង្កេតឃើញមានចំណុចខ្លាំងនិងចំណុចខ្សោយមួយចំនួនដូចខាងក្រោម៖

**ចំណុចខ្លាំង**

- បើយើងសង្កេតមើលទៅលើលទ្ធភាពទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុន គឺមានការកើនឡើងខ្លាំងបើប្រៀបធៀបទៅនឹងឆ្នាំ២០១៧។
- ការគ្រប់គ្រងសន្និធិ និងឥណទេយ្យរបស់ក្រុមហ៊ុនមានកាន់តែមានប្រសិទ្ធិភាពជាងមុន។
- ការគ្រប់គ្រងចំណាយប្រតិបត្តិការ (PM) កាន់តែមានប្រសិទ្ធិភាពជាងឆ្នាំ ២០១៧។
- លទ្ធភាពស្វែងរកប្រាក់ចំណេញនៃមូលធនអ្នកវិនិយោគ (ROE) គឺមានការកើនឡើងខ្ពស់។
- ថ្វីត្បិតតែក្រុមហ៊ុនប្រើប្រាស់បំណុលច្រើន និងការគ្រប់គ្រងទ្រព្យសកម្មក្នុងការបង្កើតចំណូលធ្លាក់ចុះបន្តិចក្តីនៅឆ្នាំ ២០១៨ ប៉ុន្តែក្រុមហ៊ុនបានគ្រប់គ្រងចំណាយប្រតិបត្តិការ

មានប្រសិទ្ធិភាពជាង ដែលធ្វើអោយប្រាក់ចំណេញនៃមូលធនអ្នកវិនិយោគ (ROE) មានការកើនឡើងខ្ពស់។

- ក្រុមហ៊ុនបង្កើនតម្លៃទីផ្សារនៃទ្រព្យម្ចាស់ភាគហ៊ុន (Market-to-book ratio) បានខ្ពស់ជាងឆ្នាំចាស់។
- ទោះបីជាអនុបាតថ្លៃភាគហ៊ុនជាមួយនឹងប្រាក់ចំណេញ (Price Earnings ratio) មានការថយចុះ ដែលវាឆ្លុះបញ្ចាំងថាអ្នកវិនិយោគហ៊ានចំណាយក្នុងការទិញភាគហ៊ុនក្នុងមួយហ៊ុនទាបជាងឆ្នាំចាស់ ប៉ុន្តែយើងសង្កេតឃើញថាថ្លៃភាគហ៊ុន និងប្រាក់ចំណេញក្នុងមួយហ៊ុនមានការកើនឡើងផងដែរ។

**ចំណុចខ្សោយ**

- សមត្ថភាពទូទាត់ការប្រាក់មានការថយចុះបន្តិចក្នុងឆ្នាំ ២០១៨។
- ការគ្រប់គ្រងទុនបង្វិលសរុប ទ្រព្យសកម្មរយៈពេលវែង និងទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុន ក្នុងការស្វែងរកចំណូលមានការថយចុះជាងឆ្នាំចាស់។
- សមត្ថភាពស្វែងរកប្រាក់ចំណេញពីការប្រើប្រាស់ទ្រព្យសកម្មក៏មានការធ្លាក់ចុះបន្តិចដែរ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការសិក្សាទៅលើស្ថានភាពទូទៅ និង ការសិក្សាវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks Corporation ទីស្នាក់ការកណ្តាលនៅឆ្នាំ២០១៧ និង២០១៨ ដោយប្រើប្រាស់វិធីសាស្ត្រតាមអនុបាតរួចមក លទ្ធផលនេះបានផ្តល់នូវចំណេះដឹង ក៏ដូចជាឆ្លើយតបទៅនឹងតថភាពស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុនផងដែរ។ ដោយយោងទៅតាមការសិក្សា និងការវិភាគទៅលើស្ថានភាពហិរញ្ញវត្ថុរួចមក យើងខ្ញុំអាចធ្វើការសន្និដ្ឋាន និង មើលឃើញពីចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានរបស់ក្រុមហ៊ុនមួយចំនួនដែលមាននៅក្នុងប្រតិបត្តិការ និង ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុននេះ។

Starbucks គឺជាក្រុមហ៊ុនកាហ្វេមួយដែលឈានមុខគេ និងមានសក្តានុពល។ ផ្អែកលើការសិក្សាវិភាគលើទិន្នន័យ តារាងតុល្យការ របាយការណ៍លទ្ធផល និងរបាយការណ៍ដែលពាក់ព័ន្ធមួយចំនួនរួចមក វាស្តែងឲ្យឃើញថាដំណើរការអាជីវកម្មមានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយចំពោះចំណុចខ្លាំងរបស់ក្រុមហ៊ុនក៏មានច្រើនផងដែរ។ ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនកំពុងមានការរីកចម្រើនជាច្រើនគួរអោយកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០១៨ យើងសង្កេតឃើញថា លទ្ធភាពទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុន គឺមានការកើនឡើងខ្លាំងបើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ ដោយសារក្រុមហ៊ុនបានធ្វើការវិនិយោគច្រើនក្នុងទ្រព្យសកម្មរយៈពេលខ្លី។ ម៉្យាងវិញទៀត លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនក៏មានកើនឡើងជាងឆ្នាំ២០១៧ ផងដែរ ដោយអនុបាតប្រាក់ចំណេញ (PM) មានការកើនឡើងជាងឆ្នាំចាស់។ លើសពីនេះទៅទៀត ថ្វីត្បិតតែក្រុមហ៊ុនប្រើប្រាស់បំណុលច្រើន និងការគ្រប់គ្រងទ្រព្យសកម្មក្នុងការបង្កើតចំណូលធ្លាក់ចុះបន្តិចក្តីនៅឆ្នាំ ២០១៨ ប៉ុន្តែក្រុមហ៊ុនបានគ្រប់គ្រងចំណាយប្រតិបត្តិការមានប្រសិទ្ធិភាពជាងឆ្នាំមុន ដែលធ្វើអោយប្រាក់ចំណេញនៃមូលធនអ្នកវិនិយោគ (ROE) មានការកើនឡើងខ្ពស់ក្នុងឆ្នាំ២០១៨។

ទន្ទឹមនឹងការរីកចម្រើននោះផងដែរ ក្រុមហ៊ុន Starbucks ក៏មានចំណុចខ្វះខាតមួយចំនួនគួរឲ្យកត់សម្គាល់ផងដែរ។ បើយើងក្រឡេកមើលទៅលើលទ្ធភាពទូទាត់បំណុលរយៈពេលវែងរបស់ក្រុមហ៊ុនវិញ យើងឃើញថាសមត្ថភាពទូទាត់ការប្រាក់មានការថយចុះបន្តិចក្នុងឆ្នាំ ២០១៨ ដោយសារតែការចំណាយការប្រាក់មានការកើនឡើងខ្ពស់។ ចំពោះលទ្ធភាពប្រើប្រាស់ទ្រព្យសកម្មវិញ យើងសង្កេតឃើញថាប្រសិទ្ធិភាពរបស់វាមានភាពធ្លាក់ចុះជាងឆ្នាំមុន ដោយសារការគ្រប់គ្រង

ទុនបង្វិលសរុប ទ្រព្យសកម្មរយៈពេលវែង និងទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុន ក្នុងការស្វែងរកចំណូលមានការថយចុះជាងឆ្នាំចាស់។ មួយវិញទៀត បើទោះបីជាទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនមានការកើនឡើងក៏ពិតមែន ប៉ុន្តែសមត្ថភាពស្វែងរកប្រាក់ចំណេញពីការប្រើប្រាស់ទ្រព្យសកម្មទាំងនេះ មានការធ្លាក់ចុះជាងឆ្នាំ២០១៧ បន្តិចផងដែរ។

## ២. ការផ្តល់អនុសាសន៍

ក្រោយពីការធ្វើសេចក្តីសន្និដ្ឋាន និងការសិក្សាពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុន Starbucks រួចមកឃើញមានថា ក្រុមហ៊ុនមានចំណុចខ្លាំងមួយចំនួនគួរតែរក្សាទុក និងមានចំនួនទៀតគួរពិចារណា និងបង្រឹងបន្ថែមទៀតដើម្បីភាពរីកចម្រើនរបស់ខ្លួន និងដើម្បីធ្វើជាគំរូដល់បណ្តាសាខានានាទូទាំងពិភពលោក និងហាងកាហ្វេផ្សេងៗទៀត។ ដូចនេះ ដើម្បីរួមចំណែកដល់ការរីកចម្រើន និងដើម្បីជាអនុសាសន៍រួមចំណែកក្នុងការកែលំអនូវចំណុចខ្វះខាតទាំងនោះ៖

- ក្រុមហ៊ុនគួរពិចារណាលើការបង្កើនការលក់ឲ្យបានកាន់តែច្រើនជាងនេះទៀត ដើម្បីសមាមាត្រទៅនឹងកំណើននៃការវិនិយោគលើទ្រព្យសកម្ម ពីព្រោះតាមការវិភាគខាងលើបង្ហាញថា ចំណូលដែលទទួលបានតាមរយៈទ្រព្យសកម្ម នៅក្នុងឆ្នាំ២០១៨ទាបជាងឆ្នាំ២០១៧។ ដូចនេះក្រុមហ៊ុនចាំបាច់ធ្វើការបង្កើតផលិតផលថ្មីៗបន្ថែមទៀត និងបន្ថែមចំនួនសាខា ដើម្បីបង្កើនប្រាក់ចំណូលដែលបានពីការប្រើប្រាស់ទ្រព្យសកម្ម។
- ក្រុមហ៊ុនគួរតែកាត់បន្ថយទ្រព្យសកម្មរយៈពេលខ្លី ដោយយកប្រាក់មួយចំនួនទៅវិនិយោគក្នុងទ្រព្យសកម្មរយៈពេលវែងវិញ ទើបការគ្រប់គ្រងទុនបង្វិលមានភាពល្អប្រសើរជាងនេះ ព្រោះដោយយោងតាមការវិភាគខាងលើ ចំណូលដែលទទួលបានពីទុនបង្វិលនៅក្នុងឆ្នាំ២០១៨ មានកម្រិតទាបជាងឆ្នាំ ២០១៧ ស្ទើរតែ ៦ដង។
- ក្រុមហ៊ុនគួរតែពង្រឹងប្រសិទ្ធភាពក្នុងការប្រើប្រាស់ទ្រព្យសកម្ម ឲ្យអស់ពីលទ្ធភាពជាងនេះ ព្រោះប្រាក់ចំណេញដែលបានពីការប្រើទ្រព្យសកម្ម (ROA) មានការកើនឡើងទាបជាងការកើនឡើងនៃទ្រព្យសកម្មសរុប។

# ឯកសារយោង

❖ **ឯកសារយោងជាភាសាខ្មែរ**


- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១ (CIAS1) ទំព័រ


❖ **ឯកសារយោងជាភាសាអង់គ្លេស**


- Martin G.Jagels et al.,Economic and Finance Analysis (ការវិភាគពីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ), បោះពុម្ពលើកទី៣ (២០០៤)
- Ross Westerfield Jordan., Fundamentals Of Corporate Finance, បោះពុម្ពលើកទី៨
- Henry Dauderisn and David Annand., Introduction to Financial Accounting, បោះពុម្ពលើកទី២
- Acc, April 2011, F7 INT Study Text Financial Reporting
- Eugene F. Brigham, Michael C. Ehrhardt, Financial Management (២០០២)
- Walter T.Harrison, Jr. and Charles T. Horngren, Financial Accounting (២០០៨)
- Berk J., DeMarzo P. and Harford J, Fundamentals of Corporate Finance បោះពុម្ពលើកទី២
- Berk J., DeMarzo P. and Harford J, Fundamentals of Corporate Finance បោះពុម្ពលើកទី២
- Belverd E. Needles and Marian Powersm, Financial Accounting (២០០៧)
- Peter S.Rose and Sylvia C. Hugin, 2010, Bank Management and Financial Service, បោះពុម្ពលើកទី៨
- Starbucks Fiscal 2018 Annual Report


❖ **ឯកសារយោងយកចេញពីគេហទំព័រ**


- https://is.mendelu.cz/eknihovna/opory/zobraz_cast.pl?cast=59743,
- accounting-simplified.com,
- https://www.accountingtools.com/articles/statement-of-changes-in-equity.html,
- https://www.myaccountingcourse.com/financial-ratios/equity-multiplier,
- https://www.investopedia.com/terms/i/inventoryturnover.asp,
- https://www.investopedia.com/terms/d/days-sales-inventory-dsi.asp,

- https://www.investopedia.com/terms/r/receivableturnoverratio.asp
- https://www.investopedia.com/terms/d/dso.asp ,
- https://www.investopedia.com/terms/w/workingcapitalturnover.asp,
- https://www.readyratios.com/reference/profitability/return_on_assets.html,
- https://www.investopedia.com/terms/p/price-earningsratio.asp,
- https://en.wikipedia.org/wiki/Starbucks#History,
- https://www.designhill.com/design-blog/starbucks-logo-overview-of-design-history-and-evolution,
- https://csimarket.com/stocks/SBUX-Business-Description.html,
- https://businessfirstfamily.com/starbucks-franchise-fee-information-for-entrepreneurs,
- https://sites.google.com/a/email.vccs.edu/starbucks-corporation/company-profile
- https://www.nasdaq.com/symbol/sbux/financials?query=income-statement
- https://www.nasdaq.com/symbol/sbux/financials?query=balance-sheet

## ឧបសម្ព័ន្ធទី១៖ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Starbucks

Starbucks Corporation

Income Statement

For the year ended 01 October 2017 and 30 September 2018

| Period Ending: | Trend | 9/30/2018 | 10/1/2017 |
|---|---|---|---|
| Total Revenue | | $24,719,500 | $22,386,800 |
| Cost of Revenue | | $10,174,500 | $9,034,300 |
| Gross Profit | | **$14,545,000** | **$13,352,500** |
| **Operating Expenses** | | | |
| Research and Development | | $0 | $0 |
| Sales, General and Admin. | | $9,491,500 | $8,444,300 |
| Non-Recurring Items | | $224,400 | $153,500 |
| Other Operating Items | | $1,247,000 | $1,011,400 |
| Operating Income | | **$3,883,300** | **$4,134,700** |
| Add'l income/expense items | | $2,067,000 | $275,300 |
| Earnings Before Interest and Tax | | $5,950,300 | $4,410,000 |
| Interest Expense | | $170,300 | $92,500 |
| Earnings Before Tax | | $5,780,000 | $4,317,500 |
| Income Tax | | $1,262,000 | $1,432,600 |
| Minority Interest | | $300 | ($200) |
| Equity Earnings/Loss Unconsolidated Subsidiary | | $301,200 | $391,400 |
| Net Income-Cont. Operations | | $4,819,500 | $3,276,100 |
| Net Income | | **$4,518,300** | **$2,884,700** |
| Net Income Applicable to Common Shareholders | | **$4,518,300** | **$2,884,700** |

Starbucks Corporation

Balance Sheet

As at 01 October 2017 and 30 September 2018

| Period Ending: | Trend | 9/30/2018 | 10/1/2017 |
|---|---|---|---|
| **Current Assets** | | | |
| Cash and Cash Equivalents | | $8,756,300 | $2,462,300 |
| Short-Term Investments | | $181,500 | $228,600 |
| Net Receivables | | $693,100 | $870,400 |
| Inventory | | $1,400,500 | $1,364,000 |
| Other Current Assets | | $1,462,800 | $358,100 |
| Total Current Assets | | **$12,494,200** | **$5,283,400** |
| **Long-Term Assets** | | | |
| Long-Term Investments | | $602,400 | $1,023,900 |
| Fixed Assets | | $5,929,100 | $4,919,500 |
| Goodwill | | $3,541,600 | $1,539,200 |
| Intangible Assets | | $1,042,200 | $441,400 |
| Other Assets | | $412,200 | $362,800 |
| Deferred Asset Charges | | $134,700 | $795,400 |
| Total Assets | | **$24,156,400** | **$14,365,600** |

| Current Liabilities | | |
|---|---|---|
| Accounts Payable | $3,691,400 | $2,932,200 |
| Short-Term Debt / Current Portion of Long-Term Debt | $349,900 | $0 |
| Other Current Liabilities | $1,642,900 | $1,288,500 |
| **Total Current Liabilities** | **$5,684,200** | **$4,220,700** |
| Long-Term Debt | $9,090,200 | $3,932,600 |
| Other Liabilities | $1,430,500 | $750,900 |
| Deferred Liability Charges | $6,775,700 | $4,400 |
| Misc. Stocks | $0 | $0 |
| Minority Interest | $6,300 | $6,900 |
| **Total Liabilities** | **$22,986,900** | **$8,915,500** |
| **Stock Holders Equity** | | |
| Common Stocks | $1,300 | $1,400 |
| Capital Surplus | $41,100 | $41,100 |
| Retained Earnings | $1,457,400 | $5,563,200 |
| Treasury Stock | $0 | $0 |
| Other Equity | ($330,300) | ($155,600) |
| **Total Equity** | **$1,169,500** | **$5,450,100** |
| **Total Liabilities & Equity** | **$24,156,400** | **$14,365,600** |

# ឧបសម្ព័ន្ធទី២

ចំនួនភាគហ៊ុនដែលបានបោះផ្សាយពីឆ្នាំ ២០០៦ ដល់ ២០១៨

| Starbucks Annual Shares Outstanding (Millions of Shares) | |
|---|---|
| 2018 | 1,395 |
| 2017 | 1,462 |
| 2016 | 1,487 |
| 2015 | 1,513 |
| 2014 | 1,526 |
| 2013 | 1,525 |
| 2012 | 1,546 |
| 2011 | 1,539 |
| 2010 | 1,528 |
| 2009 | 1,492 |
| 2008 | 1,483 |
| 2007 | 1,540 |
| 2006 | 1,585 |

តម្លៃភាគហ៊ុនពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨

| Year | Average Stock Price | Year Open | Year High | Year Low | Year Close | Annual % Change |
|---|---|---|---|---|---|---|
| 2018 | 56.5724 | 56.0237 | 67.9974 | 47.6965 | 64.0650 | 14.75% |
| 2017 | 55.1595 | 52.8231 | 62.1548 | 50.9614 | 55.8292 | 5.37% |
| 2016 | 53.6006 | 54.7764 | 57.7287 | 49.1813 | 52.9853 | -6.12% |
| 2015 | 49.8031 | 37.7975 | 59.5185 | 36.7718 | 56.4406 | 48.2 |